# មាតាបិតា

វត្តនិគ្រោធវ័ន


រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ



ពុទ្ធសករាជ ២៥៥៥

(សម្រាប់ជាធម្មទាន)

-សៀវភៅ **មាតាបិតា**

-រៀបរៀងដោយភិក្ខុ **សុវណ្ណជោតោ គួង-សុវណ្ណ**

**ជាអាចារ្យបង្រៀនព្រះវិន័យ**

**ឧត្តមសិក្សានៃវត្តនិគ្រោធវ័ន**

-**ស្ថានទីធ្វើ** វត្តនិគ្រោធវ័ន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-**ការីកំព្យូទ័រ** ភិក្ខុ គង់ សុមិត្ត

សាមណេរ ជ័យ សុហុន

-**ពុទ្ធសករាជ** ២៥៥៥

-**ធម្មទានដោយ** ពុទ្ធបរិស័ទទូទៅ ។

# អារម្ភកថា

**មាតាបិតា** ញុំាងបុត្រឱ្យកើត ជាអ្នកធ្វើកិច្ចការដែលគេធ្វើបានដោយកម្រចំពោះកូន ។ លោកមានដួងហឫទ័យល្អ (សុហទា) ជាអ្នកបង្កើតកូន (ជនយន្តី ឬ ជនេត្តី) ជាអ្នកញុំាងកូនឱ្យត្រេកអរ (តោសេន្តី) ជាអ្នកចិញ្ចឹមកូន (បោសេន្តី) ។ មាតាបិតា ស្វែងរកទ្រព្យ និងគ្រប់គ្រងទ្រព្យដើម្បីកូន រមែងលំបាកដោយការបង្ហាត់បង្រៀនកូន ។ ព្រោះហេតុនោះ កូនទាំងឡាយ ចូរដើរតាមផ្លូវដែលបណ្ឌិតដើរហើយ ទើបជាផ្លូវនៃការសម្រេចប្រយោជន៍គ្រប់យ៉ាង ។

សត្វដែលមាតាបិតា ចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើមាតាបិតា ប្រព្រឹត្តខុសក្នុងមាតាបិតានោះ តែងទៅកើតក្នុងនរក ។ សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាក ព្រោះមិនបម្រើមាតាបិតា ។ បណ្ឌិតបម្រើមាតាបិតា គប្បីបាននូវសុខនុ៎ះ គឺសេចក្ដីត្រេកអររីករាយ ការសើចលេងសព្វៗ កាល ។ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តិជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ក្នុងជេដ្ឋាបចាយនធម៌នោះៗ តាមសមគួរ ១ ។ សង្គហធម៌ទាំងនុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាភ្លៅនៃ

កង់រថដែលវិលទៅ បើសង្គហធម៌ទាំងនុ៎ះមិនមានទេ មាតាមិនត្រូវបានសេចក្ដីរាប់អាន និងការបូជាព្រោះហេតុនៃកូន ទាំងបិតាក៏មិនត្រូវបាននូវសេចក្ដីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ។ ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ទាំងនុ៎ះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វ គឺបុត្រ បណ្ឌិតហៅថាព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិត គប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូត និងការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបម្រើចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

សូមឱ្យកូនទាំងឡាយ សិក្សាឱ្យបានយល់ច្បាស់ពីមាតាបិតា ហើយត្រូវតែបម្រើចំពោះមាតាបិតានោះ ឱ្យបានល្អ ដើម្បីប្រយោជន៍ដល់មាតាបិតាផង ដើម្បីប្រយោជន៍ដល់ខ្លួនឯងផង ។

ថ្ងៃ ០៦ កើត ខែជេស្ឋ ព.ស.២៥៥៥

**ភិក្ខុ ភួង-សុវណ្ណ**

# សន្លឹកប្រាប់មាតិកា

**មាតិកាធម៌** **ទំព័រ**


អារម្ភកថា ........................................................ ក

សន្លឹកប្រាប់មាតិកា ............................................ គ

## ១ / សិក្សាពីមាតាបិតា

១.១ ឈ្មោះថាមាតាបិតា .................................. ១

១.២ ព្រហ្មសូត្រ ............................................... ៣

ក-មាតាបិតាជាព្រហ្ម ...................................... ៦

ខ-មាតាបិតាជាទេវតា ...................................... ៨

គ-មាតាបិតាជាបុព្វាចារ្យ ................................ ១០

ឃ-មាតាបិតាជាអាហុនេយ្យបុគ្គល .................. ១០

១.៣-ការទំនុកបម្រុងមាតាបិតា .......................... ១៧

១.៤-បណ្ឌិតបញ្ញត្តសូត្រ .................................... ១៨

១.៥-មេត្តសូត្រ ................................................ ១៩

១.៦-ការបម្រើមាតាបិតាជាមង្គល ...................... ២១

១.៧-មាតាបិតាឃើញហេតុ៥យ៉ាងទើបចង់បានបុត្រ .. ២៣

១.៨-មាតាបិតាសង្គ្រោះបុត្រដោយស្ថាន ៥ យ៉ាង .... ២៤

១.៩-បុត្រសង្គ្រោះមាតាបិតាដោយស្ថាន ៥ យ៉ាង ...... ២៧
១.១០-ភ្លើង ៧ ប្រការ ........................ ............ ៣០
១.១១-សេចក្ដីវិនាសព្រោះមិនចិញ្ចឹមមាតាបិតា ....... ៣៥
១.១២-ការប្រតិបត្តិខុសក្នុងមាតាបិតា .................. ៣៧
១.១៣-អនន្តរិយកម្ម ៥ យ៉ាង ............................ ៤១
១.១៤-ព្រះបាទអជាតសត្តុ ................................ ៤៣
១.១៥-ទោសព្រោះការសម្លាប់បិតាមាតា ............. ៤៤
១.១៦-កូនជាអសប្បុរស .............. .................. ៤៦
១.១៧-រឿងរាមៈ អ្នកចិញ្ចឹមមាតា .................... ៥០
១.១៨-សោណនន្ទជាតក ................................. ៥៧

## ២ / អត្ថបទកំណាព្យ

២.១-កតញ្ញូតា (ភារៈនៃអ្នកដឹងគុណ) ................ ១១៥
២.២-អកតញ្ញូឥតមានគ្រូប្រដៅកើត .................... ១១៨
២.៣-នាមជាប់ដោយគុណ ................................ ១២១
២.៤-ផលតបស្នងសងគុណ ................................ ១២២
២.៥-កូនត្រូវចិញ្ចឹកមាតាបិតា ........................... ១២៣

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
សូមនមស្ការ ចំពោះព្រះមានព្រះភាគ
ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

# មាតាបិតា

## ១_សិក្សាពីមាតាបិតា

### ១.១ ឈ្មោះថាមាតាបិតា

*ស្ត្រីដែលញុំាងបុត្រឲ្យកើត ឈ្មោះថា មាតា ។ បុរសដែលញុំាងបុត្រឲ្យកើត ឈ្មោះថា បិតា ។ បណ្ដាមាតានិងបិតាទាំងនោះ មាតាប៉ុណ្ណោះ ជាអ្នកធ្វើកិច្ចការដែលគេធ្វើបានដោយកម្រ, ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលកើតជាតាបសឈ្មោះសោណបណ្ឌិត កាលទ្រង់ប្រកាសភាវៈនៃមាតាជាអ្នកធ្វើកិច្ចការដែលគេធ្វើបានដោយកម្រ ថ្វាយដល់ព្រះ-រាជាក្នុងជម្ពូទ្វីបទាំងមូល ទើបពោលគាថាទាំងនេះ ក្នុងសោណនន្ទជាតក ក្នុងសត្តតិនិបាត ថា ៖*

*មាតាកាលប្រាថ្នាចង់បានផ្លែ គឺកូន តែងនមស្ការទេវតា*

សួរនក្ខត្តឫក្សទាំងឡាយផង សួររដូវនិងឆ្នាំទាំងឡាយផង ។ កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌សិប ដោយហេតុនោះ មាតាជាស្ត្រីមានសេចក្ដីចាញ់ផ្ទៃ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **សុហទា** (មានដួងហឫទ័យល្អ) ។ មាតារក្សា (ផ្ទៃ) អស់មួយឆ្នាំ ឬថយពីមួយឆ្នាំ ហើយទើបប្រសូតបុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា **ជនយន្តី ផង ជនេត្តី ផង** (អ្នកបង្កើតកូន) ។ មាតាញុាំងកូនដែលកំពុងយំ ឱ្យត្រេកអរដោយទឹកក្សីរផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **តោសេន្តី** (អ្នកញុាំងកូនឱ្យត្រេកអរ) ។ តអំពីនោះមក មាតាធ្វើនូវសេចក្ដីស្រឡាញ់រាប់អានហើយ ក្រឡេកមើលទារកដែលនៅពុំទាន់ដឹងក្ដី ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិត ហៅថា **បោសេន្តី** (អ្នកចិញ្ចឹមកូន) ។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាគ្រប់គ្រងទ្រព្យទាំងពីរចំណែកនុ៎ះ ដើម្បីកូននោះ (ដោយបំណងថា) ទ្រព្យនេះត្រូវមានដល់បុត្ររបស់យើង ។ មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូន ដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាទក្នុងរាជត្រកូល

ជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ) ឯណោះ ។ កាលបើកូនមានវ័យចម្រើនឡើងហើយ មាតាបានដឹងថា កូនប្រមាទក្នុងប្រពន្ធនៃអ្នកដទៃ ក្នុងពេលអាធ្រាត្រហើយមិនត្រឡប់មក ក្នុងពេលល្ងាច ក៏រមែងលំបាកចិត្ត ដូច្នេះ ។

## ២-ព្រហ្មសូត្រ

(សុត្តន្តបិដក លេខ៥៣ ទំព័រ១៤២)

ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណាដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វទេវតា (ទេវតាដើម) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វាចារ្យ (អាចារ្យដើម) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន

*ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងអាហុ-នេយ្យបុគ្គល (បុគ្គលគួរបូជា) ។*

*ម្នាលភិក្ខុទាំងឡាយ ពាក្យថា* ***ព្រហ្មនុ៎ះ*** *ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា* ***បុព្វទេវានុ៎ះ*** *ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា* ***អាហុនេយ្យនុ៎ះ*** *ជាឈ្មោះរបស់មាតាបិតា ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) មាតាបិតាមានឧបការៈច្រើន ជាអ្នកបីបាច់ (ឲ្យគង់ជីវិត) ជាអ្នកចិញ្ចឹម (ឲ្យបៅទឹកដោះ) ទាំងជាអ្នកបង្ហាញនូវលោកនេះដល់កូនទាំងឡាយ ។*

ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ។
តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យ ច បណ្ឌិតោ
អន្នេន អថ បានេន វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហាបនេន បាទានំ ធោវនេន ច ។
តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្តី បុព្វាចារ្យក្តី អាហុនេយ្យក្តី (សុទ្ធតែ) ជាអ្នកអនុគ្រោះដល់ពួកសត្វគឺកូន ។ ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរនមស្ការ គួរធ្វើសក្ការៈដល់មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿងផ្ងូតទឹក និងទឹកសម្រាប់លាងជើង ។ ព្រោះការដែលបានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយសរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង បុគ្គលនោះលុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌ ។

## អដ្ឋកថាព្រហ្មសូត្រ ៥៥,៦៧១

ពាក្យថា **សព្រហ្មកានិ** សេចក្តីថា ឈ្មោះថា ជាត្រកូលមានអ្នកប្រសើរបំផុត ។ បទថា **អជ្ឈាគារេ** សេចក្តីថា ក្នុងផ្ទះរបស់ខ្លួន ។ បទថា **បូជិតា ហោន្តិ** សេចក្តីថា ជាអ្នកដែលបុត្តទាំងឡាយ បដិបត្តិហើយដោយវត្ថុដែលគប្បីពេញចិត្ត គឺដោយវត្ថុដែលជាប្រយោជន៍ដល់រាងកាយ និងជាប្រយោជន៍ដល់ការនិយាយស្តី ព្រះមានព្រះភាគ កាលទ្រង់សរសើរ ។ ត្រកូលដែលបុត្តបូជាមាតាបិតា ឈ្មោះថា ជាត្រកូលដែលមានព្រហ្មយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងការៈដែលត្រកូលពួក

នោះ ជាត្រកូលដែលគួរសរសើរ ។ ទើបបានត្រាស់ពាក្យមានជាដើមទុកថា ឈ្មោះថា មានបុព្វទេព ។

បណ្ដាបទទាំងនោះ បទថា **ព្រហ្មជាដើម** ព្រះមានព្រះ-ភាគ ត្រាស់ទុកដើម្បីទ្រង់ឲ្យមាតាបិតាទាំងឡាយនោះ សម្រេចសេចក្ដីជាព្រហ្មជាដើម ក្នុងពាក្យនោះ មានអធិប្បាយជាក់ច្បាស់ដូចតទៅនេះ ៖

## ក-មាតាបិតាជាព្រហ្ម

ពាក្យថា **ព្រហ្ម** ជាឈ្មោះរបស់អ្នកដ៏ប្រសើរបំផុត អធិប្បាយថា មាតានិងបិតាទាំងឡាយ មិនបានលះបង់ភាវនា ៤ យ៉ាង គឺមេត្តា ករុណា មុទិតា ឧបេក្ខា ក្នុងបុត្រទាំងឡាយ ប្រៀបដូចជាមហាព្រហ្ម មិនលះបង់ភាវនា ៤ យ៉ាងដូច្នោះដែរ, ភាវនា ៤ យ៉ាងនោះ គប្បីជ្រាបក្នុងកាលនោះៗ ពិតមែន កាលបុត្រនៅក្នុងផ្ទៃ មាតានិងបិតាកើតមេត្តាចិត្តឡើងថា កាលណាហ្ន៎ យើងនឹងបានឃើញបុត្តតូចមិនមានរោគ មានអវយវៈតូចធំគ្រប់បរិបូរណ៍; តែកាលបុត្រតូចនោះ នៅក្មេងខ្ចី ដេកផ្ងារត្រូវសត្វទាំងឡាយមានចៃជាដើមខាំ ស្រែកយំខ្សឹកខ្សួល ឬ

ត្រូវសេចក្តីមិនសប្បាយបៀតបៀនក្នុងកាលនោះ មាតាបិតាបានឮសំឡេងបុត្រហើយ កើតសេចក្តីករុណាឡើង ។

តែវេលាបុត្តនោះ ចេះរត់លេងទៅមក ឬវេលាស្ថិតនៅក្នុងវ័យដែលស្អាត (គួរជាទីស្រឡាញ់) មាតាបិតាទាំងពីរនោះសំឡឹងមើលកូនតូចដោយចិត្តរីករាយទន់ក្នុងកាលនោះ មាតាបិតាទាំងនោះ មានចិត្តមុទិតា (មានចិត្តទន់ភ្លន់)។

តែកាលបុត្ររបស់មាតាបិតាពួកនោះ ទទួលភារកិច្ចចិញ្ចឹមករិយា នៅគ្រប់គ្រងផ្ទះដោយឡែក ក្នុងកាលនោះ មាតាបិតាទាំងពីរនោះ មានចិត្តជាកណ្តាលឡើងថា ពេលនោះបុត្តតូចរបស់យើង អាចចិញ្ចឹមជីវិតបានតាមធម្មតារបស់ខ្លួនហើយ ក្នុងកាលនោះ (មាតាបិតា) នឹងមានឧបេក្ខា (ការតាំងចិត្តជាកណ្តាលៗ )

ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មន៍ះ ជាឈ្មោះរបស់មាតាបិតា ព្រះមានព្រះភាគ ទ្រង់បានត្រាស់ទុក ព្រោះមាតាបិតាទាំងឡាយ ប្រព្រឹត្តដូចជាព្រហ្ម ដោយហេតុបានព្រហ្មវិហារធម៌ទាំង ៤ យ៉ាង ក្នុងបុត្រទាំងឡាយ តាមកាលដូចដែលបានពណ៌នាមកនេះឯង ។

## ២-មាតាបិតាជាទេវតា

*ទេវតាមាន ៣ ពួកគឺ សម្មតិទេព (ទេវតាសម្មតិ) ១ ឧប្បត្តិទេព (ទេវតាដោយកំណើត) ១ វិសុទ្ធិទេព (ទេវតាដោយសេចក្តីបរិសុទ្ធិ) ១ ឈ្មោះទេវតា ក្នុងពាក្យថា បុព្វទេវា នេះ បណ្តាទេវតា ៣ ពួកនោះ ក្សត្រដែលជាព្រះរាជា ឈ្មោះថា សម្មតិទេព ព្រោះថា ក្សត្រដែលជាព្រះរាជាពួកនោះ ដែលប្រជាពលរដ្ឋហៅថា ទេព និង ទេពី ទ្រង់ជាអ្នកអនុគ្រោះប្រជាពលរដ្ឋណាៗ ប្រៀបដូចទេវតា ។ ពួកសត្វដែលឧប្បត្តិឡើងក្នុងទេវលោក តាំងពីទេវតាជាន់ចាតុម្មហារាជ រហូតដល់ភវគ្គព្រហ្ម ឈ្មោះថា ឧប្បត្តិទេព, ព្រះខីណាស្រព ឈ្មោះថា វិសុទ្ធិទេព ព្រោះរួចចាកកិលេស ។*

*វិសុទ្ធិទេពពួកនោះ ប្រាថ្នាតែសេចក្តីអស់ទៅនៃវត្ថុមិនជាប្រយោជន៍ និងការកើតឡើងនៃប្រយោជន៍ ដល់ជនពួកនោះ ដោយចំណែកមួយ មិនគិតដល់សេចក្តីខុសឆ្គងរបស់ជនពាលធ្វើឡើយ បដិបត្តិដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដោយការប្រកបព្រហ្មវិហារធម៌ ដែលពោលហើយ និងនាំមកនូវការៈនៃសក្ការៈមានផលានិសង្សច្រើនមកឲ្យ ព្រោះជា*

ទក្ខិណេយ្យបុគ្គល ដូច្នោះ សូម្បីមាតាបិតាទាំងឡាយក៏ដូច្នោះដូចគ្នា ប្រាថ្នាតែសេចក្តីអស់ទៅនៃវត្ថុមិនជាប្រយោជន៍ និងការកើតឡើងនៃប្រយោជន៍ ដល់បុត្រពួកនោះ ដោយចំណែក-មួយ មិនគិតដល់សេចក្តីខុសឆ្គងរបស់បុត្រទាំងឡាយ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរបំផុត បដិបត្តិដើម្បីប្រយោជន៍សេចក្តីសុខ ព្រោះមានព្រហ្មវិហារទាំង ៤ យ៉ាង ដោយន័យដែលពោលមកហើយ នាំមកនូវឧបការៈដែលបុត្រធ្វើហើយដល់ខ្លួន ឲ្យជាឧបការៈមានផល មានអានិសង្សច្រើន និងមាតាបិតាទាំងនោះជាទេវតាដើម ។ ព្រោះមានឧបការៈដល់បុត្រពួកនោះ ជាងទេវតាទាំងពួង ព្រោះហេតុនោះ បុត្រពួកនោះ ស្គាល់ទេវតាពួកដទៃថាជាទេវតា ឲ្យទេវតាពួកនោះពេញចិត្ត ចូលទៅអង្គុយជិតទេវតាពួកនោះ កាលដឹងវិធីដែលធ្វើឲ្យទេវតាពួកនោះពេញចិត្តហើយ បដិបត្តិយ៉ាងនោះ ដោយអំណាចមាតាបិតានោះមុន ដូច្នោះ ទេវតាពួកដទៃ ទើបឈ្មោះថាបច្ឆាទេព , ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថាម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេវានេះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ។

## គ-មាតាបិតាជាបុព្វាចារ្យ

បទថា **បុព្វាចរិយា** បានដល់ អាចារ្យដំបូង អធិប្បាយថា មាតាបិតា កាលនឹងឲ្យកូនកាន់យកការសិក្សា ចាប់ផ្ដើមតាំងអំពីបុត្រកើតមក ដោយន័យជាដើមថា ចូរអង្គុយយ៉ាងនេះ ចូរដើរយ៉ាងនេះ អ្នកនេះកូនឯង ចូរហៅថា បិតា ដូច្នោះ វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ ដូចនេះ ក្រោយមកអាចារ្យពួកដទៃៗ ទើបឲ្យសិក្សាសិល្បៈមានជាដើមយ៉ាងនេះ ការរាប់ម្រាមដៃ ព្រោះដំរីជាដើម អាចារ្យពួកដទៃឲ្យសរណៈ ឲ្យតាំងនៅក្នុងសីល ឲ្យបព្វជ្ជា ឲ្យរៀនធម៌ ឲ្យឧបសម្បទា និងឲ្យសម្រេចសោតាបត្តិមគ្គជាដើម ដូច្នេះ អាចារ្យពួកនោះទាំងអស់ ឈ្មោះថា ជាអាចារ្យខាងក្រោយបង្អស់ ដោយហេតុនោះព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វាចរិយា នេះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ។

## ឃ-មាតាបិតាជាអាហុនេយ្យបុគ្គល

បទថា អាហុនេយ្យា សេចក្ដីថា វត្ថុឈ្មោះថា អាហុនៈ ព្រោះត្រូវនាំមកបូជា គឺអ្នកប្រាថ្នាផលពិសេស ត្រូវនាំមកអំពីទីឆ្ងាយហើយ ទើបថ្វាយក្នុងលោកអ្នកមានគុណទាំងឡាយ

ពាក្យថា **អាហុនះ** ជាឈ្មោះរបស់បាយ ទឹក និងសំពត់ជាដើម មាតាបិតារមែងគួរដល់ការបូជានោះ ព្រោះជាអ្នកបង្កើតឧបការគុណ ព្រោះដូច្នោះទើបឈ្មោះថា **អាហុនេយ្យ** ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកថា ម្នាលភិក្ខុ ពាក្យថា **អាហុនេយ្យ** នេះ ជាឈ្មោះរបស់មាតាបិតា ទាំងឡាយ ។

ឈ្មោះទាំង ៣ នេះ កាលទឹងទ្រង់សម្តែងហេតុ ក្នុងភាវៈដែលមាតាបិតាពួកនោះ ជាព្រហ្មជាដើម ព្រះមានព្រះភាគ ទើបត្រាស់ពាក្យមានជាដើមថា តំ កិស្ស ហេតុ ពហុការា សេចក្តីនោះ ព្រោះហេតុអ្វី មានសេចក្តីថា ព្រោះមានឧបការគុណច្រើន ។

បទថា តំ កិស្ស ហេតុ មានអធិប្បាយថា បើមានពាក្យសួរថា ព្រោះហេតុអ្វី ពាក្យថា **ព្រហ្ម** ជាដើម ជាឈ្មោះរបស់មាតាបិតា, បទថា ពហុការា បានដល់ មានឧបការៈគុណច្រើន, បទថា អាបាទកា បានដល់ អ្នកថ្នមរក្សា គឺរក្សាជីវិត អធិប្បាយថា ជីវិតរបស់បុត្រទាំងឡាយ មាតាបិតាថ្នម

គឺរក្សាបុត្រ ឲ្យប្រព្រឹត្តគឺ ឲ្យដល់ព្រមដោយការពាក់ព័ន្ធគ្នា រឿយៗ, បទថា ទោសាទកា សេចក្តីថា ចិញ្ចឹមកូនដោយឲ្យ ផឹកទឹកដោះ ក្នុងហឫទ័យ ឲ្យដៃជើងចម្រើន ។ បទថា ឥមស្ស លោកស្ស ទស្សេតារោ សេចក្តីថា ដែលឈ្មោះថា ការ ឃើញឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងលោកនេះ កើតមានដល់ បុត្រទាំងឡាយបាន ព្រោះអាស្រ័យមាតាបិតា ព្រោះដូច្នោះ មាតាបិតាទាំងនោះ ទើបឈ្មោះថា អ្នកបង្ហាញនូវលោកនេះ ដល់បុត្រទាំងនោះ ។

ក្នុងមង្គលត្ថទីបនី លោកពោលថា បទថា ទស្សេតារោ មានសេចក្តីថា ក៏ប្រសិនបើថា មាតាគប្បីចាប់បុត្រត្រង់ជើង ទាំងពីរ ហើយបោះចោលទៅក្នុងព្រៃ ក្នុងទឹក ឬក្នុងជ្រោះជ្រៅ ក្នុងថ្ងៃដែលបុត្រកើតហើយនោះឯង បុត្រទាំងនោះ ក៏មិនគប្បី ឃើញអារម្មណ៍ដែលជាទីប្រាថ្នា និងមិនជាទីប្រាថ្នា ក្នុងលោក នេះបានឡើយ ។

អដ្ឋកថា ព្រះមានព្រះភាគ សម្តែងសេចក្តីដែលមាតា បិតា ជាអ្នកមានឧបការច្រើន និងហេតុនៃសេចក្តីជាព្រហ្ម ជាដើម ដោយប្រការដូចនេះ ដែលជាហេតុគឺបុត្រ មិនអាច

នឹងតបស្នងគុណឲ្យដល់ទីបំផុតបាន ដោយលោកិយឧបការៈ ដោយបរិយាយណាៗឡើយ ព្រោះថា ប្រសិនបើបុត្រតាំងចិត្ត ថា យើងនឹងធ្វើការតបស្នងឧបការគុណរបស់មាតាបិតា ហើយ ព្យាយាមក្រោកឡើយរៀបរយស្រេចហើយ ឲ្យមាតាស្ថិតនៅ ចុងស្មាខាងស្តាំ ឲ្យបិតាស្ថិតនៅចុងស្មាខាងឆ្វេង មានអាយុវែង ១០០ ឆ្នាំ ក៏ប្រកបបំណងប្រាថ្នារបស់លោកអស់ទាំងរយឆ្នាំ ទំនុកបម្រុងលោកដោយបច្ច័យ ៤ និងដោយគ្រឿងអប់ ការគក់ ប្របាច់ ធ្វើសរសៃ ការផ្ងូតទឹកជាដើម តាមដែលលោក ពេញចិត្ត មិនឲ្យរង្កៀសសូម្បីត្រឹមតែមូត្រនិងករីស (ឧច្ចារៈ) របស់លោកនោះពិត ។

ការប្រតិបត្តិសូម្បីត្រឹមប៉ុណ្ណោះ ក៏មិនទាន់ឈ្មោះថា ធ្វើ ការតបស្នងដល់មាតាបិតា វៀរលែងតែញ៉ាំងលោកឲ្យតាំងនៅ ក្នុងគុណ សេចក្តីពិសេស មានសទ្ធាជាដើម ។

ពិតដូចព្រះមានព្រះភាគបានត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កុលបុត្ត មិន ងាយនឹងធ្វើការតបគុណ ដល់បុគ្គលពីរពួកបានទេ ។ បុគ្គល ពីរពួកតើនរណាខ្លះ ។ គឺ មាតា ១ បិតា ១ ។

ម្នាលភិក្ខុទាំងឡាយ កុលបុត្តមានអាយុ ១០០ ឆ្នាំ រស់នៅអស់រវាង ១០០ ឆ្នាំ គប្បីបញ្ចិះមាតា ដោយស្មាម្ខាង បញ្ចិះបិតា ដោយស្មាម្ខាង កុលបុត្តនោះ បម្រើមាតាបិតាទាំងពីរនោះ ដោយការដុសជម្រះបំបាត់ក្លិនអាក្រក់ រិតនួតដៃ ងូតទឹក គក់ប្របាច់ដៃជើង ឯមាតាបិតាទាំងពីរនោះ ក៏បន្ទោបង់មូត្រករីសលើស្មាកុលបុត្តនោះឯង ម្នាលភិក្ខុទាំងឡាយ (ហេតុមានប្រមាណប៉ុណ្ណេះ) គង់មិនទាន់ហៅថាធ្វើ ឬថា ធ្វើតបដល់មាតានិងបិតាឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តតម្កើងមាតានិងបិតា ឲ្យតាំងនៅក្នុងរាជសម្បត្តិ មានឥស្សរភាពជាអធិបតីលើផែនដីធំ ដែលមានកែវទាំង ៧ ប្រការ ច្រើនរនេះ ម្នាលភិក្ខុទាំងឡាយ (ហេតុមានប្រមាណប៉ុណ្ណេះ) គង់មិនទាន់ហៅថាធ្វើ ឬថា ធ្វើតបដល់មាតានិងបិតាឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មាតានិងបិតា មានឧបការច្រើនដល់បុត្រទាំងឡាយ ព្រោះជាអ្នកថែរក្សាចិញ្ចឹមបង្ហាញនូវលោកនេះ ។

ម្នាលភិក្ខុទាំងឡាយ (បើ) កុលបុត្តណាមួយដឹកនាំមាតានិងបិតា ដែលមិនមានសទ្ធា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យ

តាំងនៅក្នុងសទ្ធាសម្បទា បើទ្រុស្តសីល ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសីលសម្បទា បើកំណាញ់ ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងចាគសម្បទា បើឥតបញ្ញា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងបញ្ញាសម្បទា ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណេះ ទើបហៅថាធ្វើ ឬថា ធ្វើតបដល់មាតានិងបិតាមែន ។

ម្យ៉ាងទៀត គប្បីជ្រាបព្រះសូត្រ ដែលឲ្យសម្រេចសេចក្តីដែលមាតាបិតាជាអ្នកមានឧបការច្រើនដល់បុត្រ មានជាអាទិយ៉ាងនេះថា ការទំនុកបម្រុងមាតាបិតា ការសង្គ្រោះបុត្រ និងភរិយា និងត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការទំនុកបម្រុងមាតាបិតា បណ្ឌិតបញ្ញត្តិ ដូចនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយតទៅ

បទថា វុឌ្ឍរេ បានដល់ ហៅ គឺពោលពាក្យថា **បជាយ អនុកម្បកា** សេចក្តីថា ជាអ្នកអនុគ្រោះ បុត្រទាំងឡាយរបស់ខ្លួន ៗ មែនពិត មាតាបិតាទាំងនោះ ផ្តាច់បង់នូវជីវិត របស់សត្វដទៃ លះបង់នូវទ្រព្យណាមួយ ដែលជារបស់នៃខ្លួនខ្លះ ប្រណិប័តន៍គ្រប់គ្រងនូវបជា (បុត្រ) របស់ខ្លួន ព្រោះដូច្នោះ

ទើបឈ្មោះថា ជាអ្នករក្សាបុត្រ គឺអនុគ្រោះបជា គឺ បុត្រ ។

ពាក្យថា នមស្សេយ្យ សេចក្ដីថា គប្បីធ្វើការនមស្ការ អធិប្បាយថា ទៅកាន់ទីទំនុកបម្រុង ពេលព្រឹកល្ងាច ដោយគិតថា មាតាបិតាទាំងពីរនេះ ជាស្រែបុណ្យដ៏ខ្ពង់ខ្ពស់បំផុតរបស់យើង ។

ពេលនោះ កាលនឹងទ្រង់សម្ដែងសក្ការៈនោះ ទើបបានត្រាស់ពាក្យមានជាអាទិថា **អន្នេន** ដូច្នេះ បណ្ដាបទទាំងនោះ បទថា អន្នេន ដោយយាគូ ភត្ត និងរបស់ទំពាស៊ី ។ បទថា បានេន សេចក្ដីថា ដោយទឹកបានៈ ៨ យ៉ាង, បទថា វត្ថេន សេចក្ដីថា ដោយសំពត់ស្លៀកដណ្ដប់ ។ បទថា **សយនេន** សេចក្ដីថា ដោយទីដេក មានគ្រែតាំងពូកខ្នើយជាដើម, បទថា ឧច្ឆាទនេន សេចក្ដីថា ដោយគ្រឿងអប់ ដែលកំចាត់ក្លិនអាក្រក់ហើយ ធ្វើឲ្យមានក្លិនក្រអូប, បទថា នហាបនេន គឺដោយការស្រោចខ្លួនហើយ ឲ្យងូតដោយទឹកក្ដៅឧណ្ហៗ ក្នុងរដូវរងា ដោយទឹកត្រជាក់ក្នុងរដូវក្ដៅ, បទថា បាទានំ ធោ-វនេន ច គឺដោយការលាងជើង ដោយទឹកត្រជាក់ និងទឹកក្ដៅ

ឧណ្ហ និងដោយលាបដោយប្រេង ។ គប្បីសង្គ្រោះការរីតនួត និងការគក់ប្របាច់ ដែលព្រះមានព្រះភាគ មិនត្រាស់ក្នុងកន្ទះគាថា ដោយ ច ស័ព្ទ ។

## ១.៣ ការទំនុកបម្រុងមាតាបិតា

ការទំនុកបម្រុងមាតាបិតានេះ មិនថាតែគ្រហស្ថទេ សូម្បីតែបព្វជិតដែលជាឧត្តមភេទ ក៏ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យទំនុកបម្រុងមាតាបិតាបានដែរ ដូចមានរឿងក្នុងវិនយបិដកភាគ៨ ទំព័រ១៤៥ ក្នុងចីវរក្ខន្ធកៈជាដើម ទ្រង់អនុញ្ញាតថា “ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឲ្យចីវរដោយគិតថា មាតានិងបិតាដូច្នេះ តថាគតនឹងថាដូចម្តេចបាន” ដូច្នេះ តែបើអ្នកដទៃក្រៅពីមាតាបិតា បព្វជិតមិនមែនចេះតែឲ្យបានទេ ដូចព្រះអង្គទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចីវរដល់មាតានិងបិតាបាន, ម្នាលភិក្ខុទាំងឡាយ តែភិក្ខុមិនត្រូវធ្វើទាន ដែលគេឲ្យដោយសទ្ធា ឲ្យធ្លាក់ចុះឡើយ ភិក្ខុណាធ្វើឲ្យធ្លាក់ចុះ ត្រូវអាបត្តិទុក្កដ” ដូច្នេះ ។

នៅក្នុងគម្ពីរអដ្ឋកថាវិនយ លោកអធិប្បាយទុកថា ៖

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា តែភិក្ខុមិនត្រូវធ្វើទាន ដែលគេឲ្យដោយសទ្ធា ឲ្យធ្លាក់ចុះឡើយ ដូច្នេះ ភិក្ខុកាល ឲ្យដល់ញាតិទាំងឡាយដ៏សេស ឈ្មោះថា ញ៉ាំងសទ្ធាទេយ្យ (របស់ទាយក) ឲ្យធ្លាក់ចុះពិត ។ តែចំណែកមាតានិងបិតា សូម្បីតាំងនៅក្នុងភាពជាព្រះរាជា បើលោកប្រាថ្នាគប្បីឲ្យ (បាយទឹកជាដើម ដោយទំនុកបម្រុង) ។

សេចក្តីនេះ គ្រាន់តែលើកមកបញ្ជាក់ឲ្យឃើញថា សូម្បី តែបព្វជិត ក៏អាចទំនុកបម្រុង បម្រើមាតាបិតាបានដែរ ថែម ទាំងព្រះមានព្រះភាគ សរសើរទៀតផង ។

## ១.៤ បណ្ឌិតបញ្ញត្តសូត្រ

ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ភាគ៤១ ទំព័រ១២២ ត្រង់បណ្ឌិតបញ្ញត្តសូត្រ ព្រះមានព្រះភាគត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះដែលបណ្ឌិត បញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ហេតុ ៣ យ៉ាង តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ **ទានជាគុណជាតដែល**

បណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១ ម្នាលភិក្ខុទាំងឡាយ **បព្វជ្ជា**ជាគុណជាត ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១ **មាតាបិតុបដ្ឋាន** (ការបម្រើមាតាបិតា) ជាគុណជាតដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១ ។

ទានជាគុណជាត ដែលពួកសប្បុរសបញ្ញត្តហើយ ការមិនបៀតបៀន ការសង្រួម ការទូន្មានខ្លួន ជាគុណជាតដែលសប្បុរសបញ្ញត្តហើយ ការបម្រើមាតាបិតា ជាគុណ-ជាត ដែលសប្បុរសបញ្ញត្តហើយ បណ្ឌិតជាអ្នកប្រសើរប្រកបដោយសេចក្តីយល់ឃើញ គួរប្រតិបត្តិនូវហេតុរបស់សប្បុរស ជាអ្នកស្ងប់ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ បណ្ឌិតនោះ រមែងទៅកាន់ទេវលោកជាទីក្សេម ។

## ១.៥ មេត្តសូត្រ

នៅក្នុងគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋៈ លេខ ៥២ ទំព័រ ៥១ ត្រង់មេត្តសូត្រ ព្រះមានព្រះភាគ ទ្រង់ត្រាស់កិច្ចណាដែលព្រះអរិយៈ បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វានបានធ្វើហើយ កិច្ចនោះកុលបុត្រអ្នកឈ្លាសក្នុង

ប្រយោជន៍គួរធ្វើជាដើមទៅ និងមេត្តាភាវនា ក្នុងសូត្រនោះ មានគាថាមួយ ព្រះអង្គទ្រង់សម្តែងដោយឧបមា ថា ៖

មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ
ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ ។

មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ដោយអាយុ (ស្មើដោយជីវិត) យ៉ាងណាមិញ បុគ្គលគួរចម្រើន មេត្តាចិត្ត មិនមានប្រមាណ ចំពោះសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង ។

ក្នុងអដ្ឋកថាបរមត្ថជោតិកា មានពន្យល់គាថានោះថា ៖

គាថានោះមានសេចក្តីថា មាតាគប្បីរក្សាបុត្រក្នុងខ្លួន គឺ បុត្រដែលកើតក្នុងខ្លួន កើតអំពីទ្រូង គប្បីថ្នាក់ថ្នមបុត្រនោះ ដែលមានតែម្នាក់ប៉ុណ្ណោះ ដោយអាយុ (ជីវិត) គឺព្រមលះបង់ សូម្បីជីវិតរបស់ខ្លួន ថ្នមបុត្រនោះ ដើម្បីហាមការពារទុក្ខ មក ដល់បុត្រនោះយ៉ាងណា ភិក្ខុគប្បីធ្វើចិត្ត ដែលប្រកបដោយ មេត្តានេះ ឲ្យចម្រើន គឺឲ្យកើតរឿយៗ ឲ្យពង្រីកទៅ និងញ៉ាំង មេត្តាភាវនានោះចម្រើនមិនមានប្រមាណ ដោយកាន់យកសត្វ មិនមានប្រមាណជាអារម្មណ៍ ឬដោយផ្សាយទៅ មិនមាន សេសសល់ឡើយ សូម្បីតែក្នុងសត្វម្នាក់ ។

## ១.៦ ការបម្រើមាតាបិតាជាមង្គល

នៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ៥៤ ទំព័រ៨៥ ត្រង់មង្គលសូត្រ ព្រះមានព្រះភាគ ត្រាស់ថា ៖

មាតាបិតុ ឧបដ្ឋានំ ឯតម្មង្គលមុត្តមំ : កិរិយាបម្រើមាតានិងបិតា នេះជាមង្គលដ៏ឧត្តម ។

អដ្ឋកថាបរមត្ថជោតិកា លោកពន្យល់ថា អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងបាទគាថានេះថា មាតាបិតុ ឧបដ្ឋានំ ដូចនេះជាដើម ដូចតទៅនេះ មាតាផង បិតាផង ព្រោះហេតុនោះទើបឈ្មោះថា មាតាបិតុ មាតានិងបិតា ។ ការទំនុកបម្រុង ឈ្មោះថា ឧបដ្ឋានំ ការធ្វើឧបការៈដោយការលាងជើង ការគក់ប្របាច់ ការអប់ ការផ្ងូតទឹក និងការជូនបច្ច័យ ៤ ឈ្មោះថា ឧបដ្ឋានៈ ការទំនុកបម្រុង ។

គប្បីជ្រាបអធិប្បាយក្នុងការទំនុកបម្រុង វាក្យនោះដូចតទៅនេះ ព្រោះហេតុតែមាតាបិតា ជាអ្នកមានឧបការៈច្រើនប្រាថ្នាប្រយោជន៍ ជាអ្នកអនុគ្រោះដល់បុត្តទាំងឡាយ កាលលោកឃើញបុត្តពួកនោះ លេងនៅខាងក្រៅ មានខ្លួនប្រលាក់

ធូលីមកហើយ ក៏ជូតធូលីឲ្យ ឱបថើបសរីរៈ ក្បាល និងញាំង សេចក្តីស្រឡាញ់ឲ្យកើតឡើង បុត្តទាំងឡាយចិញ្ចឹមមាតាបិតា ដោយការដាក់លើក្បាល ។ សូម្បីអស់ ១០០ ឆ្នាំ ក៏មិនអាច នឹងតបស្នងឧបការគុណនៃការទំនុកបម្រុងនោះបានឡើយ និង ព្រោះហេតុដែលលោកទាំងពីរនោះ ជាអ្នកទំនុកបម្រុងជាអ្នក រក្សាបុត្ត ជាអ្នកសម្តែងលោកនេះ និងស្មើដោយព្រហ្ម ជា បុព្វាចារ្យដូច្នេះ ការទំនុកបម្រុងមាតាបិតាទាំងពីរនោះ ទើបនាំ មកនូវការសរសើរក្នុងលោកនេះ លះលោកនេះទៅហើយ ក៏នាំសេចក្តីសុខក្នុងសួគ៌មកឲ្យ ព្រះមានព្រះភាគ ត្រាស់ថា ជាមង្គលម្យ៉ាង អ្នកទំនុកបម្រុងមាតាបិតា ដោយការឲ្យជ្រះថ្លា ក្នុងព្រះរតនត្រ័យ ឬដោយឲ្យសមាទានសីល ឬដោយឲ្យ បព្វជ្ជា អ្នកនោះនឹងថា ជាកំពូលរបស់មនុស្សទាំងឡាយ ក្នុង ការទំនុកបម្រុងមាតាបិតាក្នុងលោកនេះ ។

ការទំនុកបម្រុងមាតាបិតានោះ របស់អ្នកនោះ ជាការធ្វើ តបស្នងឧបការគុណ ដែលមាតានិងបិតាធ្វើទុក ព្រះមានព្រះ-ភាគ ត្រាស់ថាជាមង្គល ព្រោះហេតុនៃប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងសម្បរាយភព។

## ១.៧ មាតាបិតាឃើញហេតុ៥យ៉ាងទើបចង់បានបុត្រ

ក្នុងព្រះសុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត លេខ ៤៤ ទំព័រ៨៦ ព្រះមានព្រះភាគ ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ មាតាបិតា ពិចារណាឃើញហេតុ ៥ យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។

ហេតុ ៥ យ៉ាងដូចម្តេចខ្លះ ?

គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ បុត្រនឹងជួយធ្វើកិច្ចការយើង ១ វង្សត្រកូលនឹងស្ថិតនៅយូរ ១ បុត្រប្រតិបត្តិទទួលយកនូវមរតក ១ មួយទៀត បុត្រនឹងឧទ្ទិសទក្ខិណាទានឲ្យដល់យើង ដែលធ្វើមរណកាលទៅកាន់លោកខាងមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតាកាលពិចារណាឃើញហេតុ ៥ យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។

អ្នកប្រាជ្ញទាំងឡាយ កាលបើពិចារណាឃើញហេតុ ទាំង ៥ យ៉ាង រមែងចង់បានបុត្រ គឺបុត្រដែលយើងចិញ្ចឹមហើយនឹងចិញ្ចឹមយើងវិញ នឹងធ្វើកិច្ចការដល់យើង វង្សត្រកូលនឹងស្ថិតនៅយូរ ប្រតិបត្តិគួរដើម្បី

ទទួលមរតក មួយទៀត នឹងឧទ្ទិសទក្ខិណាទានឲ្យដល់យើង ដែលទៅកាន់លោកខាងមុខ ។ អ្នកប្រាជ្ញទាំងឡាយ កាលបើពិចារណាឃើញហេតុទាំង ៥ នេះហើយ រមែងចង់បានបុត្រ ហេតុដូច្នោះ ពួកសប្បុរស អ្នកស្ងប់រម្ងាប់ ជាកតញ្ញូកតវេទីបុគ្គល កាលរលឹកឃើញនូវឧបការគុណ ដែលលោកធ្វើហើយ ក្នុងកាលមុន រមែងចិញ្ចឹមមាតាបិតា រមែងជួយធ្វើកិច្ចការរបស់បុព្វការីទាំងនោះ តាមសមគួរ បុត្រអ្នកធ្វើតាមឱវាទ អ្នកចិញ្ចឹមមាតាបិតា ដែលលោកចិញ្ចឹមហើយ មិនញ៉ាំងវង្សត្រកូលឲ្យសាបសូន្យ ជាអ្នកមានសទ្ធា បរិបូរណ៍ដោយសីល ដែលអ្នកផងគប្បីសរសើរ ។

## ១.៨ មាតាបិតាសង្រ្គោះបុត្រដោយស្ថាន ៥ យ៉ាង

ក្នុងគម្ពីរមង្គលត្ថទីបនី លោកពោលទុកថា ៖

ការទំនុកបម្រុង មានការចិញ្ចឹមជាដើម ឈ្មោះថា "ជាមង្គល" ព្រោះជាហេតុនៃប្រយោជន៍សុខក្នុងបច្ចុប្បន្ន ៥ យ៉ាង ដោយអំណាចការហាមចាកអំពើអាក្រក់ ឲ្យតាំងនៅ

ក្នុងអំពើល្អ ឲ្យរៀននូវសិល្បសាស្ត្រ ដណ្ដឹងកិរិយាស្វាមីសមគួរឲ្យ នឹងឲ្យទ្រព្យមរតក ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ក្នុងសិង្គាលកសូត្រថា "ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដូច្នេះគឺ

១-បាបា និវារេន្តិ ហាមឃាត់កូនចាកអំពើអាក្រក់
២-កល្យាណេ និវេសេន្តិ ឲ្យកូនតម្កល់តែក្នុងអំពើល្អ
៣-សិប្បំ សិក្ខាបេន្តិ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ
៤-បដិរូបេន ទារេន សញ្ញោជេន្តិ ដណ្ដឹងកិរិយាស្វាមីសមគួរឲ្យ
៥-សមយេ ទាយជ្ជំ និយ្យាទេន្តិ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ។

ត្រង់ពាក្យថា **ហាមឃាត់កូនចាកអំពើអាក្រក់** សេចក្ដីថា មាតាបិតាពោលដល់ទោស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយកពរបស់បាណាតិបាតជាដើម ហើយហាមថា "ម្នាល

កូន ឯងកុំធ្វើកម្មមានសភាពយ៉ាងនេះឡើយ” ដូច្នេះ តិះដៀលកូនដែលធ្វើហើយ ។

ត្រង់ពាក្យថា **ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ** សេចក្ដីថា មាតាបិតាសូម្បីឲ្យរង្វាន់ ដូចអនាថបិណ្ឌិកសេដ្ឋី ក៏ញុាំងឲ្យកូនតាំងនៅក្នុងការសមាទានសីលជាដើម ។

ក្នុងពាក្យថា **ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ** សេចក្ដីថា មាតាបិតា ដឹងសេចក្ដីដែលកូនតាំងនៅក្នុងឱវាទរបស់ខ្លួនហើយ ញុាំងកូនឲ្យសិក្សាសិល្បសាស្ត្រ មានមុទ្ទា និងគណនាជាដើម ដែលទៅតាមវង្សត្រកូល ។

ត្រង់ពាក្យថា **ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ** សេចក្ដីថា ឲ្យទ្រព្យក្នុងសម័យ ។ ក្នុងបទនោះ សម័យ ២ យ៉ាងគឺ និច្ចសម័យ ១ កាលសម័យ ១ ។ មាតាបិតាឲ្យដោយពាក្យថា “ឯងចូរខ្មីឃ្មាតកាន់យកវត្ថុដែលគួរកាន់យកនេះ វត្ថុនេះចូរជាស្បៀង (ដើមទុន) របស់ឯង ; ឯងចូរធ្វើកុសលដោយវត្ថុនេះ” ដូច្នេះ ឈ្មោះថា ឲ្យក្នុងនិច្ចសម័យ ឲ្យជានិច្ច ។ មាតាបិតារមែងឲ្យក្នុងសម័យកាត់ជុក រៀបការជាដើម ឈ្មោះថា ឲ្យក្នុងកាលសម័យ ។ ម្យ៉ាងទៀត មាតាបិតា សូម្បីឲ្យដោយពាក្យ ថា

"ឯងចូរធ្វើកុសលដោយទ្រព្យនេះ" ដល់កូនអ្នកដេកលើគ្រែមរណៈ ក្នុងគ្រាចុងក្រោយ ក៏ឈ្មោះថា ឲ្យក្នុងសម័យ ។

## ១.៩ បុត្រសង្គ្រោះមាតាបិតាដោយស្ថាន ៥ យ៉ាង

ក្នុងគម្ពីរមង្គលត្ថទីបនី លោកពោលទុកថា ៖

ការទំនុកបម្រុងនូវមាតាបិតា ដូចបានពោលហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ជាមង្គល" ព្រោះនាំមកនូវឥដ្ឋផលទាំងឡាយ មានការសរសើរជាដើម ក្នុងលោកនេះ ដោយប្រការដូច្នេះឯង ។

សម័យមួយទៀត ការទំនុកបម្រុង ៥ យ៉ាង ដោយអំណាចការចិញ្ចឹម ការជួយធ្វើកិច្ចការងារ ការតាំងវង្សត្រកូល ការប្រព្រឹត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមរតក និងការតាមឲ្យនូវទក្ខិណានុប្បទាន ឈ្មោះថា ការទំនុកបម្រុង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ដល់គហបតិបុត្ត ឈ្មោះសិង្គាលក ទើបទ្រង់ត្រាស់សម្ដែងថា ម្នាលគហបតិបុត្ត មាតាបិតា ជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាង

១-ភតោ នេសំ ភរិស្សាមិ អាត្មាអញ មាតាបិតា

បានចិញ្ចឹងរក្សាហើយ នឹងចិញ្ចឹមមាតាបិតាវិញ

**២-កិច្ចំ នេសំ ករិស្សាមិ** អាត្មាអញ នឹងជួយធ្វើកិច្ចការងាររបស់មាតាបិតា

**៣-កុលវំសំ ឋបេស្សាមិ** អាត្មាអញ នឹងតម្កល់វង្សត្រកូល

**៤-ទាយជ្ជំ បដិបជ្ជាមិ** អាត្មាអញ នឹងប្រព្រឹត្តឲ្យជាអ្នកសមគួរទទួលទ្រព្យមរតកបាន

**៥-អថវា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមិ** ម្យ៉ាងទៀត អាត្មាអញនឹងឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់លោកខាងមុខហើយ ។

ម្នាលគហបតិបុត្ត មាតាបិតា ជាទិសខាងកើត ដែលកូនគប្បីទំនុកបម្រុងដោយឋានទាំងឡាយ ៥ យ៉ាងនេះឯង ។

ត្រង់ពាក្យថា **អាត្មាអញមាតាបិតាបានចិញ្ចឹមហើយ នឹងចិញ្ចឹមមាតាបិតាវិញ** សេចក្តីថា អាត្មាអញ ដែលមាតាបិតាឲ្យផឹកទឹកដោះ ញ៉ាំងដៃនិងជើងឲ្យចម្រើន បឺតសំបោរឲ្យ ឲ្យងូតទឹក តាក់តែងឲ្យ ចិញ្ចឹមនិងបីបាច់, អាត្មាអញនឹងចិញ្ចឹមមាតាបិតាទាំងនោះ ដែលចាស់ ដោយការលាងជើង ងូតទឹក

ឲ្យបបរនិងបាយជាដើម ។

ត្រង់ពាក្យថា **អាត្មាអញនឹងជួយធ្វើការងាររបស់មាតាបិតា** សេចក្ដីថា អាត្មាអញ នឹងផ្អាកការងាររបស់ខ្លួនទៅធ្វើកិច្ចការដែលកើតឡើងក្នុងរាជត្រកូលជាដើម របស់មាតាបិតា ។

ត្រង់ពាក្យថា **អាត្មាអញ នឹងតម្កល់វង្សត្រកូល** សេចក្ដីថា បុត្តមិនធ្វើឲ្យស្រែ វត្ថុ (ចំការ) ប្រាក់និងមាសជាដើម ដែលជារបស់មាតាបិតាឲ្យវិនាស សូម្បីកំពុងរក្សាក៏ឈ្មោះថា តម្កល់វង្សត្រកូល បុត្តធ្វើឲ្យមាតាបិតាវិនាសចាកវង្ស ដែលប្រកបដោយអធម៌ សូម្បីឲ្យតាំងនៅក្នុងវង្សដែលប្រកបដោយធម៌ មិនចូលទៅកាត់សលាកភត្តជាដើមដែលមកដល់ហើយដោយវង្សត្រកូល សូម្បីកំពុងឲ្យប្រព្រឹត្តទៅ ក៏ឈ្មោះថា តម្កល់វង្សត្រកូល ។ លោកពោលបំណងដល់បុត្តនេះ ទើបពោលថា អាត្មាអញនឹងតម្កល់វង្សត្រកូល ។

ត្រង់ពាក្យថា **អាត្មាអញ នឹងប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមរតក** សេចក្ដីថា មាតាបិតាទៅដល់រោងសាលធ្វើទារកអ្នកមិនប្រព្រឹត្តក្នុងឱវាទរបស់ខ្លួន អ្នកប្រព្រឹត្តខុសមិនឲ្យកាន់ថា ជាកូន កូនទាំងនោះ ក៏ជាអ្នកមិនសមគួរទទួល

មរតក តែមាតាបិតា តែងធ្វើទារកអ្នកប្រព្រឹត្តក្នុងឱវាទ ឲ្យជាម្ចាស់របស់ទ្រព្យ ដែលមាននៅក្នុងត្រកូល លោកពោលថា អាត្មាអញ នឹងប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមរតក ដោយបំណងថា អាត្មាអញនឹងប្រតិបត្តិយ៉ាងនេះដូច្នេះ ។

ត្រង់ពាក្យថា **ឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ** សេចក្តីថា យើងនឹងធ្វើទានផ្សាយចំណែកបុណ្យដល់លោកទាំងនោះ ហើយនឹងឧទ្ទិសទានឲ្យតាំងពីថ្ងៃទី ៣ ។

## ១.១០ ភ្លើង ៧ ប្រការ

ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ មហាយញ្ញវគ្គ លេខ៤៧ ទំព័រ ៨៣ (បឋមអគ្គិសូត្រ)

ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ភ្លើង ៣ ប្រការ តើដូចម្តេចខ្លះ ។ ភ្លើងគឺរាគៈ ១ ភ្លើង គឺទោសៈ ១ ភ្លើងគឺ មោហៈ ១ ។

ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺរាគៈនោះ បុគ្គលគួរលះចេញ

គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជារាគៈចរិត ត្រូវរាគៈគ្របសង្កត់ រួបរឹតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ ភ្លើងគឺរាគៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។

ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺទោសៈនោះបុគ្គលគួរលះចេញ គួរចៀសវាងចេញ ។ល។

ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺមោហៈនោះ បុគ្គលគួរលះចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជាមោហៈចរិត ត្រូវមោហៈគ្របសង្កត់ រួបរឹតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយ

វាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ ភ្លើងគឺមោហៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ភ្លើងទាំង ៣ ប្រការនេះឯង បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។

ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះ បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើដោយល្អប្រពៃ ភ្លើង ៣ ប្រការនោះ តើដូចម្តេច ? ភ្លើងគឺអាហុនេយ្យបុគ្គល ១ ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ ១ ភ្លើងគឺទក្ខិណេយ្យបុគ្គល ១ ,

ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺអាហុនេយ្យបុគ្គល តើដូចម្តេច ? ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ ត្រូវជាមាតាឬបិតារបស់បុគ្គលណា ក្នុងលោកនេះ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើងគឺអាហុណេយ្យបុគ្គល (របស់បុគ្គលនោះ) ដំណើរនោះតើព្រោះហេតុអ្វី ?

ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលនោះ ដែលបានឲ្យកើតមកដោយសារមាតានិងបិតានោះ ហេតុនោះ ភ្លើងគឺអាហុណេយ្យ-

បុគ្គលនេះ បុគ្គលគួរធ្វើសក្ការៈ គោរពរាប់អាន បូជា រក្សា បម្រើដោយល្អប្រពៃ ។

ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះតើដូចម្តេច ?

ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ ត្រូវជាកូនឬប្រពន្ធ ឬក៏អ្នកបម្រើរបស់បុគ្គលណា ក្នុងលោកនេះ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ បុគ្គលគួរធ្វើសក្ការៈ គោរពរាប់អាន បូជា រក្សា បម្រើដោយល្អដោយប្រពៃ ។

ម្នាលព្រាហ្មណ៍ ភ្លើងគឺទក្ខិណេយ្យបុគ្គលតើដូចម្តេច ?

ម្នាលព្រាហ្មណ៍ សមណឬព្រាហ្មណ៍ណា ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ ឋិតនៅក្នុងខន្តី និងសោរច្ចៈ ទូន្មាននូវចិត្ត ១ រម្ងាប់នូវចិត្ត ១ រំលត់នូវចិត្ត ១ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើងគឺទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះ ភ្លើងគឺទក្ខិណេយ្យបុគ្គលនេះ បុគ្គលគួរធ្វើសក្ការៈគោរព រាប់អាន បូជា រក្សា បម្រើដោយល្អប្រពៃ ។

ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះឯង បុគ្គលគួរធ្វើសក្ការៈគោរព រាប់អាន បូជា រក្សា បម្រើឲ្យល្អប្រពៃ ។

ម្នាលព្រាហ្មណ៍ ចំណែកភ្លើងឧសនេះសោត បុគ្គលគួរដុតតាមកាលគួរ គួររំលត់តាមកាលគួរ បង្អន់មើលតាមកាលគួរ គួរទុកដាក់តាមកាលគួរ ។

## អដ្ឋកថា បឋមអគ្គិសូត្រ ៣៧,១១១

បទជាដើមថា **អាហុនេយ្យគ្គិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ សក្ការៈ លោកហៅថា អាហុនៈ ជនពួកណារមែងគួរដល់អាហុនៈ ហេតុនោះ ជនទាំងឡាយនោះ ហៅថា អាហុនេយ្យជន អ្នកគួរដល់អាហុនៈ មែនពិត មាតានិងបិតាទាំងឡាយ រមែងគួរដល់អាហុនៈ ព្រោះលោកទាំងពីរជាអ្នកមានឧបការៈគុណច្រើនដល់បុត្តទាំងឡាយ បុត្តទាំងឡាយអ្នកបដិបត្តិខុស ក្នុងមាតានិងបិតាទាំងពីរនោះ រមែងកើតក្នុងអបាយមាននរកជាដើម ព្រោះហេតុនោះ មាតានិងបិតា នឹងមិនបានដុតបំផ្លាញក៏ពិត សូម្បីពេលនោះលោកទាំងពីរ ក៏ជាបច្ច័យដល់ការដុតបំផ្លាញ ព្រោះដូច្នេះ លោកហៅថា **អាហុនេយ្យគ្គិ** ព្រោះអត្ថថា តាមដុតបំផ្លាញនោះឯង, ក៏ម្ចាស់ផ្ទះលោកហៅថា គហបតិ ពិតមែន គហបតិនោះ មានឧបការៈច្រើនដល់មាតុគ្រាម ដោយការប្រគល់ឲ្យទីដេក សំលៀកបំពាក់ និង

គ្រឿងប្រដាប់ជាដើម ដល់មាតុគ្រាម មាតុគ្រាមអ្នកផិតប្តីនេះ រមែងកើតក្នុងអបាយ មាននរកជាដើម ព្រោះហេតុនោះ ស្វាមីសូម្បីនោះ លោកហៅថា **គហបតិគ្គិ** ។

ចំណែកក្នុង **ទក្ខិណេយ្យគ្គិ** នេះ មានវិនិច្ឆ័យដូចតទៅនេះ បច្ច័យ ៤ ឈ្មោះថា ទក្ខិណា ពិតមែន ភិក្ខុសង្ឃនោះ រមែងជាអ្នកមានឧបការៈច្រើនដល់គ្រហស្ថទាំងឡាយ ដោយប្រកបទុកក្នុងកល្យាណធម៌ទាំងឡាយ មានជាដើមយ៉ាងនេះ គឺសរណៈ សីល ៥ សីល ១០ ការទំនុកបម្រុងមាតាបិតា ការទំនុកបម្រុងសមណៈព្រាហ្មណ៍ អ្នកតាំងក្នុងធម៌ គ្រហស្ថអ្នកបដិបត្តិខុសក្នុងភិក្ខុសង្ឃ រមែងកើតក្នុងអបាយទាំងឡាយ មាននរកជាដើម ព្រោះហេតុនោះ ភិក្ខុសង្ឃលោកហៅថា **ទក្ខិណេយ្យគ្គិ** ។

## ១.១១ សេចក្តីវិនាសព្រោះមិនចិញ្ចឹមមាតាបិតា

នៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ៥៤ ទំព័រ ៣៦ ត្រង់បរាភវសូត្រ ទ្រង់ត្រាស់ថា ៖

យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុ សន្តោ ន ភរតិ តំ បរាភវតោ មុខំ ។

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឲ្យវិនាស ។

នៅក្នុងអដ្ឋកថាបរមត្ថជោតិកា ពន្យល់ថា ៖

ស្រីអ្នកឲ្យកើត គប្បីជ្រាបថា មាតា, ប្រុសអ្នកឲ្យកើតនោះឯង គប្បីជ្រាបថា បិតា ។ ឈ្មោះថា អ្នកចាស់ ព្រោះភាពជាអ្នកមានសរីរៈដ៏ចូរ ឈ្មោះថា កន្លងវ័យកំលោះទៅហើយ ព្រោះឈានកន្លងភាពជាកំលោះក្រមុំ គឺមានវ័យ ៨០ ឆ្នាំ ឬ ៩០ ឆ្នាំ អ្នកមិនអាចដើម្បីធ្វើការងារទាំងឡាយដោយខ្លួនឯង ។ បទថា បហុសន្តោ សេចក្តីថា ជាអ្នកអាច គឺមានសេចក្តីសម្រេចហើយ រស់នៅយ៉ាងសប្បាយ ។ បទថា ន ភរតិ គឺមិនចិញ្ចឹមរក្សា ។

ការមិនចិញ្ចឹម គឺការមិនចិញ្ចឹមរក្សា ការមិនទំនុកបម្រុងមាតាបិតាតែម្យ៉ាងប៉ុណ្ណោះ ត្រាស់ថា ជាប្រធាននៃសេចក្តីវិនាស ដោយគាថានេះ ព្រោះអ្នកប្រកបព្រមដោយការមិនចិញ្ចឹមមាតាបិតានោះ រមែងមិនសម្រេចដល់អានិសង្សក្នុងការចិញ្ចឹមមាតាបិតា ដែលទ្រង់ត្រាស់ទុកថា ៖

តាយ នំ ចារិចរិយាយ មាតាបិតូសុ បណ្ឌិតា

ឥធេវ ធំ បសំសន្តិ បេច្ច សគ្គេ បមោទតិ ។

ព្រោះការដែលបានទំនុកបម្រុងមាតាបិតានោះហើយ បាន ជាអ្នកប្រាជ្ញទាំងឡាយ សរសើរនូវបុគ្គលនោះ ក្នុងលោក នេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែង រីករាយក្នុងឋានសួគ៌ ដូច្នេះ ។

រមែងមិនចិញ្ចឹមសូម្បីមាតាបិតាប្រាកដ ដល់ការទិទ្ទា និងការតិះដៀលថា នឹងចិញ្ចឹមអ្នកណាដទៃហ្ន៎ នឹងដល់ទុគ្គតិ ឈ្មោះថា រមែងវិនាសនោះឯង ព្រោះហេតុនោះ ទើបទ្រង់ ត្រាស់ថា ជាប្រធាននៃសេចក្ដីវិនាស ។

## ១.១២ ការប្រតិបត្តិខុសក្នុងមាតាបិតា

ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ អាយាចនវគ្គ ឯកនិបាត លេខ៤០ ទំព័រ២០៣ ព្រះមានព្រះភាគ ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជា អសប្បុរស ប្រតិបត្តិខុស ក្នុងបុគ្គលពីរពួក តែងរក្សាខ្លួន ដែលខ្ញុំនបានជីកគាស់ កំចាត់គុណចោលចេញ ជាអ្នកប្រកប ដោយទោសផង ប្រកបដោយជំនៀលនៃអ្នកប្រាជ្ញទាំងឡាយ ផង តែងបាននូវបាបដ៏ច្រើនផង ។ គឺ មាតា ១ បិតា ១ ។

ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ភណ្ឌគាមវគ្គ លេខ៤២ ទំព័រ៩ ព្រះមានព្រះភាគ ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គលបួនពួក ឈ្មោះថា រក្សាខ្លួន ដែលខ្លួនជីកគាស់ កំចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ?

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងមាតា ឈ្មោះថា រក្សាខ្លួន ដែលខ្លួនជីកគាស់ កំចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលបើប្រតិបត្តិខុសក្នុងបិតា ។ល។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលបើប្រតិបត្តិខុសក្នុងព្រះតថាគត ។ល។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុស ក្នុងសាវករបស់ព្រះតថាគត ។ល។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គលបួនពួកនេះឯង ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់ កំចាត់គុណបោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិត ឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួក នេះឯង ឈ្មោះថា រក្សាខ្លួន ដែលខ្លួនមិនបានជីកគាស់ មិនបានកំចាត់គុណ-បោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

បុគ្គល ៤ ពួកតើដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ គឺ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងមាតា...

ម្នាលភិក្ខុទាំងឡាយ គឺបុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបិតា...

ម្នាលភិក្ខុទាំងឡាយ គឺបុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងតថាគត...

ម្នាលភិក្ខុទាំងឡាយ គឺបុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងសាវករបស់ព្រះតថាគត...

ម្នាលភិក្ខុទាំងឡាយ គឺបុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួកនេះឯង ឈ្មោះជារក្សាខ្លួន ដែលខ្លួនមិនបានជីកគាស់ មិនបានកំចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

នៅក្នុងអដ្ឋកថា មនោរថបូរណី ពោលអធិប្បាយពីពាលនិងបណ្ឌិត ថា បទថា មាតរិ ច បិតរិ ច ជាដើម មិត្តវិន្ទុក ឈ្មោះថា បដិបត្តិខុសក្នុងមាតា ។ ស្តេចអជាតសត្តុ ឈ្មោះថា បដិបត្តិខុសក្នុងបិតា ទេវទត្ត ឈ្មោះថា បដិបត្តិខុសក្នុងព្រះតថាគត កោកាលិក ឈ្មោះថា បដិបត្តិខុសក្នុងសាវករបស់ព្រះតថាគត ។

បទថា ពហុញ្ច ប្រែថា ច្រើន បទថា បសវតិ ប្រែថា រមែងបាន, បទថា តាយ សេចក្ដីថា ដោយសេចក្ដីប្រតិបត្តិ អធម៌ ពោលគឺសេចក្ដីបដិបត្តិខុសនោះ, បទថា បេច្ច គឺទៅអំពីលោកនេះ ។ បទថា អបាយញ្ច គច្ឆតិ គឺលោកនឹងត្រូវកើតក្នុងនរកជាដើម ។

## ១.១៣ អនន្តរិយកម្ម ៥ យ៉ាង

១-មាតុឃាតកោ មនុស្សដែលសម្លាប់មាតា

២-បិតុឃាតកោ មនុស្សដែលសម្លាប់បិតា

៣-អរហន្តឃាតកោ មនុស្សដែលសម្លាប់ព្រះអរហន្ត

៤-សង្ឃភេទកោ មនុស្សដែលបំបែកសង្ឃ

៥-លោហិតុប្បាទកោ មនុស្សដែលធ្វើលោហិតុប្បាទ

ក្នុងអដ្ឋកថា ពន្យល់ថា ៖

ក្នុងពាក្យថា មាតុឃាតកោ ភិក្ខវេ នេះមានវិនិច្ឆ័យថា មាតាបង្កើតដែលជាស្រីមនុស្ស បុគ្គលឯណាសូម្បីខ្លួនឯងក៏ជាជាតិមនុស្សដូចគ្នា ក្លែងផ្ដាច់បង់ចាកជីវិត, បុគ្គលនេះជាអ្នកសម្លាប់មាតា ត្រូវអនន្តរិយមាតុឃាតកកម្ម ។

ក៏បើសូម្បីបុរសជាកូនស្រីពេស្យា, មិនដឹងថា "អ្នកនេះជាបិតារបស់យើង" គេកើតដោយទឹកសម្ភវៈរបស់បុរសឯណា, ឯបុរសនោះដែលគេសម្លាប់ហើយ រមែងដល់នូវសេចក្តីរាប់ថាជាអ្នកសម្លាប់បិតាដូចគ្នា រមែងត្រូវអនន្តរិយកម្មផង ។

សូម្បីបុគ្គលអ្នកសម្លាប់ព្រះអរហន្ត គប្បីដឹងដោយអំណាចព្រះអរហន្តដែលជាមនុស្សដូចគ្នា ។

(សមន្ត. ភាគ៣ ទំព័រ៩០-៩១ / ១៤៥)

នៅក្នុងគម្ពីរសារត្ថទីបនីដីកា ភាគ៣ ទំព័រ៣១៥ ពោលថា កាលផ្តាច់ជីវិតមាតា ឬបិតាសូម្បីអ្នកត្រឡប់ភេទ ក៏រមែងជាអនន្តរិយកម្មមែនពិត ។ ព្រោះថា សូម្បីកាលមានការត្រឡប់ភេទ ការជាប់តគ្នានៃភវង្គនិងការជាប់តគ្នានៃជីវិតិន្ទ្រិយដែលបង្កើតដោយកម្មយ៉ាងណាមួយ ក៏យ៉ាងនោះឯង មិនជាយ៉ាងដទៃទេ ។

ចំណែកបុគ្គលណាខ្លួនឯងជាមនុស្ស ផ្តាច់ជីវិតមាតា ឬបិតាដែលជាសត្វតិរច្ឆាន ឬខ្លួនឯងជាសត្វតិរច្ឆានផ្តាច់ជីវិតមាតា ឬបិតាដែលជាមនុស្ស ឬជាសត្វតិរច្ឆាននោះឯង ផ្តាច់ជីវិតមាតា ឬបិតាជាសត្វតិរច្ឆាន កម្មរបស់បុគ្គលនោះ

មិនចាត់ជាអនន្តរិយកម្ម តែជាកម្មធ្ងន់ តាំងនៅជួបអនន្ត-រិយកម្ម មែនពិត ។ (ចាកដីកាសារត្ថ.)

បុគ្គលឯណា លើកយកពាក្យដែលមិនមែនជាធម៌ មិនមែនជាវិន័យមកអាងថា ជាសាសនៈហើយ ព្យាយាមបំបែកសង្ឃឲ្យបែកគ្នាដោយកម្ម ៤ យ៉ាង កម្មណាមួយ ដូចជាភិក្ខុទេវទត្ត បុគ្គលនេះឈ្មោះថា សង្ឃភេទកៈ អ្នកបំបែកសង្ឃ ។

បុគ្គលឯណាញុំាងពុទ្ធលោហិត សូម្បីមួយចំអែតរុយតូច ១ ក្នុងសរីរៈរបស់ព្រះតថាគតឲ្យពុរពងឡើង ដោយទុដ្ឋចិត្ត គឺវធកចិត្ត ដូចជាភិក្ខុទេវទត្ត បុគ្គលនោះហៅថា លោហិតុប្បាទកៈ អ្នកញុំាងពុទ្ធលោហិតឲ្យពុរពងឡើង ។

ការសម្លាប់មាតាបិតាជាដើម ឈ្មោះថា ជីករំលើងគុណធម៌របស់ខ្លួនចេញ ដូចជាព្រះបាទអជាតសត្តុ ។

## ១.១៤ រឿងព្រះបាទអជាតសត្តុ

នៅក្នុងព្រះសុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ក្នុងសាមញ្ញផលសូត្រ ភាគ ១៤ ត្រង់ទំព័រ ២១៣ ព្រះមានព្រះភាគ ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ជីក

រំលើងគុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើព្រះរាជាអង្គនេះ មិនផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតា ដែលជាព្រះធម្មរាជប្រកបដោយធម៌ទេ ធម្មចក្ខុ គឺសោតាបត្តិ-មគ្គ ដែលប្រាសចាកធូលី ប្រាសចាកមន្ទិលនឹងកើតដល់ព្រះរាជាអង្គនោះ លើអាសនៈនេះមិនខានឡើយ ។

## ១.១៥ ទោសព្រោះការសម្លាប់មាតាបិតា

សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ភាគ៦១ ទំព័រ៥៨

បុរសលាមកណាសម្លាប់បិតា ព្រោះតែលោភៈ ឬព្រោះទោសៈ តែបុរសលាមកនោះ រមែងធ្លាក់នៅក្នុងនរកកាឡ-សុត្តនរក អស់កាលជាយូរអង្វែង ។

បុរសបែបនោះ រមែងឆេះនៅក្នុងលោហកុម្ភីនរក ពួកនិរយបាល (នាំចេញ) នូវសាច់ដ៏ធ្អិន ធ្វើមិនឲ្យមានស្បែក ហើយចាក់ដោយលំពែងទាំងឡាយ ធ្វើឲ្យខ្វាក់ ឲ្យស៊ីនូវមូត្រនិងលាមក ហើយជ្រមុជជនបែបនោះទៅក្នុងទឹកខារ (ទឹកទន់ដែង) ។ ពួកនិរយបាល (ញ៉ាំងសត្វនរកឲ្យស៊ីនូវលាមក) កំពុងពុះនិងដុំដែកដ៏ក្តៅ ហើយយកបណ្តាញដ៏វែង ដែលកំដៅអស់កាលយូរមកបើកមាត់ (ហើយបោះសន្ទូចដែក) ដែលចង

ដោយខ្សែ (ទាញអណ្តាតចេញហើយបោះដុំដែក) ទៅក្នុងមាត់ដែលប្រឈមនោះ ។ ពួកឆ្កែក្រហម ឆ្កែពពាល ពួកត្មាត ពួកក្អែក និងពួកសត្វស្លាប (ឯទៀតច្រើនពួក) មានចំពុះដែក នាំគ្នាមកចោមរោមចឹកជញ្ជែង ស៊ីនូវអណ្តាត (នៃពួកសត្វនរក) ដែលញាប់ញ័រ (ដូចជាស៊ី) នូវរំពាព្រមទាំងឈាម មានឈាមកំពុងហូរចេញ ។ ពួកនិរយបាល វាយសំពងសត្វនរកនោះ ដែលភ្លើងកំពុងឆេះ មានខ្លួនរយះរយាយ ដោយតម្រេករបស់ពួកនិរយបាលនោះ ចំណែកខាងសត្វនរកទាំងឡាយក្រៅនេះ ក៏ដល់នូវសេចក្តីទុក្ខវេទនា ពួកជនណានីមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់បិតា ពួកជននោះតែងទៅនៅក្នុងនរកបែបនោះ ។

កូនសម្លាប់មាតា លុះទៅអំពីលោកនេះ ទៅកាន់លំនៅរបស់យមរាជ កាន់យកនូវផលនៃកម្មរបស់ខ្លួន ក៏ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំង ។ ពួកអមនុស្ស (និរយបាល) ព្រហើនក្រៃលែង យកសរសៃដែក (មករុំ) នូវបុគ្គលអ្នកសម្លាប់មាតាហើយគាប (ដោយឃ្នាបដែក) រឿយៗ ។ ពួកនិរយបាលញុំាងបុគ្គលអ្នកសម្លាប់មាតានោះ ឲ្យផឹកនូវឈាមក្តៅ ដែលហូរចេញមកពីកាយរបស់ខ្លួន ដូចជាទឹកទន្លេដែងរលាយ ។ បុគ្គល

សម្លាប់មាតានោះ ចុះទៅឋិតនៅក្នុងរណ្តៅគូថទ្ធើម ដូចជាអសុរក មានក្លិនស្អុយ មានលាមក ជាភក់ មានក្លិនអាក្រក់ ប្រហែលគ្នា ដោយខ្ទះនឹងឈាម ។ ក្នុងនរកនោះ មានពួកដង្កូវ មានខ្លួនធំ មានមាត់ដូចម្ជុលដែក រុកត្បុលចូលទៅក្នុងសាច់ និងឈាម ទម្លាយស្បែកសម្បុរថ្ងៃ ហើយស៊ីសត្វនរកនោះ (ទាំងខួរក្នុងឆ្អឹង) បុគ្គលអ្នកសម្លាប់មាតានោះ ធ្លាក់ទៅក្នុងនរកនោះ ជ្រមុជ(ក្បាល) ចុះទៅ ចំនួនមួយរយជួរបុរស សាកសពដ៏ស្អុយ ក៏ផ្សាយទៅ កាន់ទីចម្ងាយមួយរយយោជន៍ជុំវិញ ។ ព្រោះថា សូម្បីជន មានចក្ខុ ធុញទ្រាន់ដោយក្លិននោះ ព្រោះអាស្រ័យចក្ខុ បពិត្រ ព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសម្លាប់មាតា តែងបានសេចក្តី ទុក្ខបែបនេះ ។

## ១.១៦ កូនជាអសប្បុរស

នៅក្នុងសុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ៣០ ទំព័រ១២៤ ក្នុងមហាសាលសូត្រ ថា ៖

សាវត្ថីនិទាន គ្រានោះ ព្រាហ្មណ៍មហាសាលម្នាក់ មានខ្លួនសៅហ្មង មានសំពត់ដណ្តប់ដ៏សៅហ្មង ចូលទៅរក ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ

ជាមួយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ លុះព្រាហ្មណ៍មហាសាលអង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលព្រាហ្មណ៍ អ្នកឯងមានខ្លួនសៅហ្មងមានសំពត់ដណ្ដប់ដ៏សៅហ្មង តើព្រោះហេតុអ្វី ? ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមានកូន ៤ នាក់ ក្នុងទីនេះកូនទាំងនោះ ក៏សមគំនិតគ្នានឹងប្រពន្ធទាំងឡាយហើយបណ្ដេញខ្ញុំព្រះអង្គចេញពីផ្ទះ ។

ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូលរៀននូវគាថាទាំងឡាយនេះ ហើយសូត្រក្នុងរោងជាទីប្រជុំ នៅវេលាដែលពួកមហាជនប្រជុំគ្នាផង នៅវេលាដែលកូនទាំង-ឡាយរបស់អ្នកអង្គុយហើយផងថា ៖

ខ្ញុំត្រេកអរដោយកូនទាំងឡាយណា ដែលកើតហើយផង ប្រាថ្នានូវសេចក្ដីចម្រើនដល់កូនទាំងឡាយណាផង កូនទាំងនោះក៏សមគំនិតគ្នានឹងប្រពន្ធទាំងឡាយ ហើយបណ្ដេញខ្ញុំ ដូចជាឆ្កែដេញជ្រូក ក៏កូនទាំងឡាយជាអសប្បុរស លាមក គ្រាន់តែហៅខ្ញុំថា បិតា បិតា ប៉ុណ្ណោះទេ ប៉ុន្តែកូនទាំងនោះ ដូចអារក្សទឹក

ដែលមកដោយរូបជាកូន លះបង់នូវខ្ញុំដែលមានអាយុចូលដល់បច្ចិមវ័យហើយ បិតាចាស់របស់បុគ្គលពាលទាំងឡាយ តែងសូមទានប្របផ្ទះនៃជនដទៃ ដូចជាសេះចាស់ប្រើប្រាស់មិនបាន គេនាំចេញចាកចំនី ឈើច្រត់របស់ខ្ញុំប្រសើរ កូនទាំងឡាយដែលមិនស្តាប់បង្គាប់ មិនប្រសើរដូចឈើច្រត់ឡើយ ព្រោះឈើច្រត់រមែងការពារគោកាចក៏បាន ការពារឆ្កែកាចក៏បាន ប្រត់ក្នុងខាងមុខក្នុងទីងងឹតក៏បាន ស្ទង់ក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់អើលគង់ទប់វិញបាន ដោយអានុភាពនៃឈើច្រត់ ។

លំដាប់នោះ ព្រាហ្មណមហាសាលនោះ បានរៀននូវគាថាទាំងឡាយនេះ ក្នុងសំណាក់ព្រះមានព្រះភាគ ហើយពោលក្នុងរោងជាទីប្រជុំ នៅវេលាដែលពួកមហាជនប្រជុំគ្នាផង នៅវេលាដែលកូនទាំងឡាយ អង្គុយហើយផង ថា ៖

ខ្ញុំត្រេកអរដោយកូនទាំងឡាយណា ដែលកើតហើយផង ប្រាថ្នានូវសេចក្តីចម្រើនដល់កូនទាំងឡាយណាផង ។បេ។ ស្ទង់ក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់អើលគង់ទប់វិញបាន ដោយអានុភាពនៃឈើច្រត់ ។

លំដាប់នោះ កូនទាំងឡាយ នាំទៅកាន់ផ្ទះ ហើយឲ្យងូតទឹក ឲ្យស្លៀកដណ្ដប់ ដោយគូសំពត់មួយគូម្នាក់ៗ ។ ទើបព្រាហ្មណមហាសាលនោះ យកសំពត់មួយគូ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណមហាសាលនោះ អង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំ ព្រះអង្គជាព្រាហ្មណ៍ ស្វែងរកនូវទ្រព្យសម្រាប់អាចារ្យ (មកប្រគេន) ដល់អាចារ្យ សូមព្រះគោតមដ៏ចម្រើនជាអាចារ្យ ទទួលយកនូវចំណែកអាចារ្យរបស់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ទទួលយក ដោយសេចក្ដីអនុគ្រោះ ។

លំដាប់នោះ ព្រាហ្មណមហាសាលនោះ ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

## ១.១៧ រឿងរាមៈ អ្នកចិញ្ចឹមមាតា

ក្នុងអតីតកាល ព្រះពោធិសត្វ ជាបុត្ររបស់បុរោហិត នៃព្រះរាជាក្រុងពារាណសី បានឈ្មោះថា**ជោតិបាល** ព្រោះអាវុធគ្រប់យ៉ាង បានកើតឡើងភ្លឺរុងរឿង ក្នុងថ្ងៃដែលកូននោះកើតហើយ ។ ក្រោយមក ជោតិបាលនោះ បានសម្តែងនូវសិល្បៈធ្នូ មានប្រការផ្សេងៗ ថ្វាយដល់ព្រះរាជា ដោយន័យដែលបានពោលហើយ ក្នុងអដ្ឋកថាសរភង្គជាតក តាំងពីពេលនោះមក ទើបបានប្រាជ្ញកឈ្មោះថា "*សរភង្គ*" ។

ថ្ងៃមួយ សរភង្គពោធិសត្វនោះ មិនឲ្យអ្នកណាដឹង ចូលទៅព្រៃតែម្នាក់ឯងគត់ ហើយបួសជាតាបសឥសី ក្នុងអាស្រម ដែលសក្កទេវរាជប្រទានឲ្យ ក្នុងព្រៃខ្ទិត មានទំហំប្រវែង ៣០ យោជន៍ ក្បែរមាត់ស្ទឹងគោធាវរី បានញ៉ាំងឈានទិងអភិញ្ញាឲ្យកើតឡើងហើយ ក្នុងថ្ងៃទី ៧ ។ ក្រោយមក ព្រះរាជាទាំងឡាយ មានព្រះរាជាក្រុងពារាណសីជាដើម ក៏បួសក្នុងសំណាក់នៃសរភង្គតាបសនោះ ព្រមជាមួយនឹងអ្នកដែន ។ អាស្រមព្រៃ

ខិត ពេញអស់ហើយ ។

គ្រានោះ អន្តេវាសិកជាច្បង របស់សរភង្គតាបសម្នាក់ឈ្មោះថា **កិសវច្ឆះ** ប្រាថ្នានៅស្ងប់ស្ងាត់ ទើបទៅអំពីទីនោះ ហើយអាស្រ័យនៅនគរនៃព្រះរាជា**ទណ្ឌកី** ឈ្មោះ**កុម្ភវតីបុរៈ** ក្នុង**កលិង្គរដ្ឋ** ជាអ្នកគឺសេនាបតីទំនុកបម្រុងហើយ នៅក្នុងព្រះរាជឧទ្យាន ។

ក្នុងកាលនោះ ព្រះរាជាព្រះនាមទណ្ឌកី ទ្រង់ត្រាស់បញ្ជាឲ្យដកនូវឋានន្តរស័ក្តិ នៃស្រីពេស្យាម្នាក់ ។ តាំងពីពេលនោះមក ស្រីពេស្យានោះ ធ្វើសន្ធវកិច្ច ជាមួយនឹងបុរសនោះៗ ស្វែងរកនូវឋានន្តរស័ក្តិ ថ្ងៃមួយ ទៅកាន់ព្រះរាជឧទ្យាន បានជួបនឹងតាបសនោះ ហើយពោកថា "អញបានជួបបុរសកាឡកណ្ណិនេះ, អ្នកទាំងឡាយចូរនាំទឹកមក, ខ្ញុំនឹងលាងភ្នែកទាំងពីរ" ដូច្នេះហើយ ទំពានូវឈើស្ទន់ហើយ ស្តោះដុំទឹកមាត់លើសរីរៈនៃតាបស បោះឈើស្ទន់ទៅលើកំពូលនៃជដា ស្រោចស្ទូឭទឹកខ្ពុរមាត់លើសិរសីនៃតាបសនោះ ហើយដើរចេញទៅ ។

ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់បញ្ជាឲ្យព្រះរាជទាន ឋានន្តរស័ក្តិដើមនោះឯង ដល់ស្រីពេស្យានោះ ។ នាងសម្គាល់ ឋានន្តរស័ក្តិដែលនាងបានហើយ ព្រោះអាស្រ័យនូវកុសល ដែលខ្លួនបានធ្វើហើយក្នុងកាលមុន ថា "អាត្មាអញបានឋានន្តរ-ស័ក្តិ ព្រោះការញ៉ាំងដុំទឹកមាត់ឲ្យធ្លាក់លើសរីរៈនៃតាបស" ។ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ អំពីថ្ងៃនោះ ព្រះរាជាទ្រង់ យកនូវឋានន្តរស័ក្តិ នៃបុរោហិត ។ បុរោហិតនោះ ចូលទៅ រកស្រីពេស្យានោះហើយ សួរថា "នាងបានធ្វើកម្មអ្វី ទើបបាន ឋានន្តរស័ក្តិត្រឡប់មកវិញ ? " ដូច្នេះហើយ បានស្តាប់ថា "ធ្វើកម្មឈ្មោះនេះ" ហើយទៅក្នុងទីនោះ បានធ្វើហើយយ៉ាង ដូច្នោះឯង ក៏ត្រឡប់បាននូវឋានន្តរស័ក្តិជាប្រក្រតី ក្នុងថ្ងៃនោះ ដូចគ្នាដែរ ។ ឯបុរោហិតនោះ បានហើយនូវឋានន្តរស័ក្តិ ដោយ ផលនៃបុណ្យ ទើបសម្គាល់ថា "ខ្លួនបានហើយ ព្រោះការញ៉ាំង ដុំទឹកមាត់ឲ្យធ្លាក់ចុះ" ។ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ អំពី ថ្ងៃនោះទៅ បច្ចន្តជនបទនៃព្រះរាជា បះបោរហើយ ។ ព្រះរាជា ទ្រង់មានព្រះបំណងនឹងបង្ក្រាបនូវបច្ចន្តជនបទ ឲ្យស្ងប់សុខ

ទ្រង់ជឿពាក្យបុរោហិតហើយ ទ្រង់ត្រាស់បញ្ជាមនុស្សទាំងអស់ថា "ពួកអ្នកទាំងឡាយ ចូរស្តោះទឹកមាត់លើសរីរៈនៃជដិលកោងនុ៎ះ" ។ មនុស្សទាំងអស់នោះ ព្រមទាំងព្រះរាជាបានធ្វើហើយដូច្នោះឯង ។ របស់បដិកូលទាំងឡាយ មានទឹក-មាត់ជាដើម បានស្រោចពាសពេញហើយទូទាំងសរីរៈរបស់តាបស ។ ឯសេនាបតី បានស្តាប់ ខាងក្រោយនៃជនទាំងពួងទើបប្រញាប់ទៅកាន់ឧទ្យាន បោសនូវវត្ថុដែលមិនស្អាតទាំងអស់នោះចេញ ឲ្យតាបសងូតទឹកហើយ ពោលថា "បពិត្រលោកម្ចាស់ កម្មមិនគួរដែលជនទាំងនោះធ្វើហើយ ផលបែបណា នឹងមានដល់ជនទាំងនុ៎ះ ?" ។ តាបសពោលថា "សេចក្តីប្រទូស្តរ៉ាយនៃចិត្តរបស់អាត្មាភាព មិនមានឡើយ, ចំណែកទេវតា ក្រោធខឹងខ្លាំងណាស់, ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះទៅទេវតាទាំងឡាយ នឹងធ្វើនូវរដ្ឋទាំងមូល មិនឲ្យទៅជារដ្ឋ, ព្រោះហេតុនោះ ចូរអ្នកទៅខាងក្រៅរដ្ឋជានី ក្នុងរវាង ៧ ថ្ងៃចុះ" ។ សេនាបតីនោះ បានធ្វើហើយយ៉ាងដូច្នោះ ។ ចំណែកព្រះរាជា

គ្រាន់តែស្តេចយាងទៅដល់ប៉ុណ្ណោះ ក៏បង្ក្រាបជនបទឲ្យបានស្ងប់ហើយ ទើបស្តេចយាងមកកាន់ព្រះនគរវិញ ។ ក្នុងថ្ងៃនោះឯង ទេវតាទាំងឡាយ ញុំាងភ្លៀងឲ្យធ្លាក់ចុះហើយ ។ មនុស្សទាំងឡាយ បានមានចិត្តរីករាយហើយថា "តាំងពីពេលដែលពួកយើងបៀតបៀនចំពោះជដិលកោងមក សេចក្តីចម្រើន ក៏កើតមានដល់ព្រះរាជាតែម្យ៉ាង, ក្នុងថ្ងៃដែលព្រះអង្គ ស្តេចបង្ក្រាបជនបទ ឲ្យស្ងប់សុខហើយ ស្តេចយាងមកទុំះឯង ភ្លៀងក៏បានធ្លាក់ចុះមកហើយ" ។ លំដាប់នោះ ពួកទេវតាទាំងឡាយញុំាងភ្លៀងផ្កាម្ទិស ភ្លៀងមាសកៈ ភ្លៀងកហាបណៈ និងភ្លៀងគ្រឿងប្រដាប់ ដែលគេធ្វើហើយ សម្រាប់ប្រដាប់ដៃ-ជើងជាដើម ឲ្យធ្លាក់ចុះហើយ ។ ព្រោះហេតុនោះ មនុស្សទាំងឡាយមានចិត្តត្រេកអរយ៉ាងក្រៃលែង បញ្ចេញវាចា ដោយចិត្តរីករាយ មានសេចក្តីត្រេកអរតាម ក្នុងបាបដែលព្រះរាជាទ្រង់បានធ្វើហើយ ។

ក្នុងកាលនោះ ទេវតាទាំងឡាយ ញុំាងភ្លៀងសាស្ត្រាវុធដែលមុតតែម្ខាងជាដើម ភ្លៀងរងើកភ្លើង ដែលមិនមានផ្សែង

ភ្លៀងដុំថ្មប្រមាណប៉ុនផ្ទះកំពូល និងភ្លៀងដីខ្សាច់ ឲ្យធ្លាក់ចុះហើយ ធ្វើរដ្ឋធានីឲ្យទួលកំពស់ ៨០ ហត្ថ ។ ក៏កាលបើរដ្ឋធានីមិនទាន់វិនាសសាបសូន្យនៅឡើយ, សរភង្គតាបស ដឹងរឿងនោះហើយ ក៏បញ្ជូនតាបសដែលក្មេងៗ ២ រូបទៅ ឲ្យនាំកិស-**វច្ឆតាបសមក** តាមផ្លូវអាកាស ដោយគ្រែស្នែង ។ ឯសេនាបតីចេញទៅហើយ ដោយខ្លួនឯងតែម្នង ។ ក៏ទឹកផឹកនិងស្មៅសម្រាប់ពួកសត្វតិរច្ឆាន ដែលមិនបាននិយមតាម ក្នុងកម្មនោះមិនបានមានឡើយ ។ សត្វតិរច្ឆានទាំងនោះ ក៏ទៅតាមទឹកផ្ទៃដែលមានទឹកផឹកនិងស្មៅ, កាលបើថ្ងៃទី ៧ មិនទាន់មកដល់នុ៎ះឯង, ក៏បានទៅដល់ខាងក្រៅរដ្ឋធានី ។ ក៏បុរសម្នាក់ ឈ្មោះ **រាមៈ** គឺពួកទេវតា ជួយនាំចេញ យកមកខាងក្រៅនៃរដ្ឋធានីនោះ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ជយទិសជាតក ក្នុងតឹសនិបាត លោកពោលហើយថា “បានឮមកថា បុរសអ្នករស់នៅក្នុងក្រុងពារាណសីម្នាក់ ជាអ្នកចិញ្ចឹមមាតា ទំនុកបម្រុងមាតាបិតា ទៅហើយដើម្បីលក់ដូរ ដល់នគរឈ្មោះ**កុម្ភវតីបុរៈ**ក្នុងរដ្ឋធានីនៃព្រះរាជាទ្រង់ព្រះនាមទណ្ឌកីហើយ, កាលបើរដ្ឋ-

ជានីទាំងមូល ត្រូវភ្លៀងទាំង ៩ ប្រការ ធ្វើឲ្យវិនាស, ក៏បាន រឭកដល់គុណនៃមាតាបិតា ។ គ្រានោះ ទេវតាទាំងឡាយ បាន នាំបុរសដែលចិញ្ចឹមមាតានោះ ទៅប្រគល់ឲ្យដល់មាតា ដោយ សុវត្ថិភាព ព្រោះផលនៃកម្ម គឺការទំនុកបម្រុងមាតា" ។ ចំណែកជនបទដទៃទៀតក្រៅពីនោះ បានដល់ហើយនូវសេចក្តី វិនាស ដូច្នេះឯង ។

រឿងបុរសឈ្មោះរាមៈ អ្នកចិញ្ចឹមមាតា មកក្នុងអដ្ឋកថា ឧបាលិសូត្រ មជ្ឈិមបណ្ណាសកៈ និងអដ្ឋកថាសរភង្គជាតក ។

ចប់ រឿងបុរសឈ្មោះរាមៈ ។

ព្រោះហេតុនោះ ធម្មតាបុត្រ គប្បីជាអ្នកមានចិត្តរឹងប៉ឹង ស្ថិតថេរ ក្នុងកម្ម គឺការទំនុកបម្រុង ដូចជាឧបាសកអ្នកចិញ្ចឹម មាតា ។ ម្យ៉ាងទៀត បុត្រគប្បីប្រតិបត្តិ ដោយប្រការដែលខ្លួន គប្បីបាន ដើម្បីទំនុកបម្រុងមាតាបិតា ឲ្យដូចជានន្ទបណ្ឌិត ។

# ១.១៨ សោណនន្ទជាតក

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតាមួយរូប ត្រាស់ព្រះធម៌ទេសនានេះ មានពាក្យចាប់ផ្តើមថា ***ទេវតា នុសិ*** ដូច្នេះ ។

សាច់រឿងរបស់ជាតកនេះ ដូចក្នុងរឿងសាមជាតក ។ ក៏ក្នុងកាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកកុំតិះដៀលភិក្ខុរូបនេះឡើយ បណ្ឌិតទាំងឡាយពីដើម សូម្បីបានរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងអស់ ក៏នៅតែមិនព្រមទទួលយករាជសម្បត្តិនោះ រមែងចិញ្ចឹមតែមាតាបិតាតែប៉ុណ្ណោះ ហើយទ្រង់នាំអតីតនិទានមកត្រាស់ថា ៖

***អតីតេ ពារាណសី ព្រហ្មវឌ្ឍនំ នាម នគរំ អហោសិ ។ តត្ថ មនោជោ នាម រាជា រជ្ជំ ការេសិ ។*** ក្នុងអតីតកាល ក្រុងពារាណសី ជាព្រះនគរដែលមានឈ្មោះថាព្រហ្មវឌ្ឍន៍ ។ ព្រះរាជាទ្រង់ព្រះនាមថា មនោជៈ សោយរាជសម្បត្តិនៅក្នុងព្រះនគរនោះ ។ មានព្រាហ្មណ៍មហាសាលម្នាក់ មានទ្រព្យ-សម្បត្តិប្រមាណ ៨០ កោដិ តែមិនមានបុត្រ អាស្រ័យនៅ

ក្នុងព្រះនគរនោះ នាងព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍នោះ កាលព្រាហ្មណ៍ជាស្វាមីនោះពោលថា នែនាងដ៏ចម្រើន នាងចូរប្រាថ្នាបុត្រចុះ ដូច្នេះ ក៏បានប្រាថ្នាហើយ ។ គ្រានោះ ព្រះ-ពោធិសត្វ ស្តេចចុតិចាកព្រហ្មលោក ទ្រង់កាន់បដិសន្ធិក្នុងគភ៌របស់ព្រាហ្មណីនោះ ។ កាលកុមារនោះកើតហើយ មាតាបិតាទើបដាក់ឈ្មោះថា **សោណកុមារ** ក្នុងកាលសោណកុមារនោះដើរបាន សូម្បីសត្វដទៃក៏ចុតិចាកព្រហ្មលោក កាន់បដិសន្ធិក្នុងគភ៌របស់នាងព្រាហ្មណីនោះទៀត មាតាបិតាដាក់ឈ្មោះកុមារនោះថា **នន្ទកុមារ** កាលកុមារទាំង ២ នាក់នោះ រៀនវេទ ដរាបដល់ចប់ការសិក្សាសិល្បសាស្ត្រទាំងអស់ហើយ ព្រាហ្មណ៍ជាបិតាមើលឃើញរូបសម្បត្តិដែលចម្រើនវ័យ ទើបហៅនាងព្រាហ្មណីមកហើយនិយាយថា នែនាងដ៏ចម្រើន យើងនឹងចងសោណកុមារកូនប្រុសរបស់យើងទុក ដោយគ្រឿងចងគឺផ្ទះ នាងទទួលថា ល្អហើយ ហើយប្រាប់សេចក្តីនោះ ដល់បុត្រឲ្យជ្រាប ។ សោណកុមារនោះ ទើបនិយាយថា កុំឡើយម៉ែ រឿងការនៅគ្រប់គ្រងផ្ទះសម្រាប់ខ្ញុំ ខ្ញុំនឹងបដិបត្តិលោក (មាតា

និងបិតា) ដរាបដល់អស់ជីវិត កាលលោក (មាតានិងបិតា) កន្លងទៅហើយ ក៏នឹងចូលព្រៃហិមពាន្តបួស ។ នាងព្រាហ្មណី ទើបប្រាប់សេចក្តីនោះដល់ព្រាហ្មណ៍ឲ្យជ្រាប ។ អ្នកទាំង ២ នាក់នោះ សូម្បីពោលរឿយៗ ក៏មិនបានសេចក្តីយល់ព្រមពី សោណកុមារនោះ ទើបហៅនន្ទកុមារមកហើយ និយាយថា កូនអើយ បើយ៉ាងនោះ អ្នកឯងចូរគ្រប់គ្រងទ្រព្យសម្បត្តិចុះ កាលនន្ទកុមារនិយាយថា ខ្ញុំនឹងដាក់សីសៈ ទៅទទួលដុំទឹកមាត់ ដែលបងប្រុសស្តោះចោលហើយ មិនបានទេ សូម្បីខ្ញុំឯង កាល កន្លងទៅនៃ(មាតាបិតា)ហើយ ក៏នឹងចេញបួស ព្រមជាមួយ នឹងបងប្រុសដូចគ្នា ស្តាប់ពាក្យរបស់កូនប្រុសទាំងពីរនាក់នោះ ហើយ ទើបនាំគ្នាគិតថា កូនប្រុសទាំងពីរនាក់នេះ កំពុងនៅក្មេង កំលោះយ៉ាងនេះ ក៏លះបង់កាមារម្មណ៍ទាំងឡាយចេញបាន នឹង ចាំបាច់ពោលទៅថ្វីដល់យើងទាំងពីរនាក់ហ្ន៎ ពួកយើងនាំគ្នាបួស ទាំងអស់គ្នាចុះ ទើបនិយាយចំពោះបុត្រទាំងពីរនាក់ថា នែកូន កាលមាតានិងបិតាកន្លងទៅ (មិនមានជីវិត)ហើយ ការបួស របស់អ្នកទាំងពីរនឹងមានប្រយោជន៍អ្វី យើងទាំងអស់ចេញបួស

ព្រមជាមួយគ្នា ក្នុងឥឡូវនេះចុះ ហើយក្រាបទូលចំពោះព្រះរាជា លះបង់ទ្រព្យទាំងអស់ចុះក្នុងផ្លូវទាន ធ្វើជនជាទាសឲ្យជាអ្នកជា (គ្មានបំណុល) ឲ្យជញ្ជូនរបស់ដែលសមគួរឲ្យដល់ពួកញាតិ ព្រមគ្នាទាំង ៤ នាក់ បេញចាកព្រហ្មវឌ្ឍន-នគរ សាងអាស្រមនៅក្នុងដងព្រៃដែលគួររីករាយចិត្ត អាស្រ័យស្រះដែលពេញទៅដោយផ្កាបទុមពណ៌ប្រាំ ក្នុងហិមវន្តប្រទេស ហើយបព្វជ្ជាអាស្រ័យនៅក្នុងអាស្រមនោះៗ សុម្បីព្រះសោណៈនិងព្រះនន្ទៈទាំង ២ នោះ ក៏ជួយគ្នាបដិបត្តិមាតាបិតា ភ្ញាក់អំពីព្រឹក ក៏ចាត់ចែងឈើស្ទន់ និងទឹកសម្រាប់លុបមុខឲ្យដល់លោកទាំង ២ ហើយទៅបោសបណ្ណសាលា និងបរិវេណអាស្រម តម្កល់ទឹកឆាន់ទុកស្រេចហើយ នាំគ្នាទៅជ្រើសរើសផ្លែឈើតូចធំ ដែលមានរសឆ្ងាញ់មកពីព្រៃ នាំមកឲ្យមាតាបិតាបានបរិភោគ ដល់ពេលក្ដៅ ក៏រកទឹកត្រជាក់មកឲ្យងូត ជម្រះផ្ទះសក់ឲ្យស្អាត ធ្វើការបរិកម្មជាដើម ដល់មាតាបិតាទាំងពីរនាក់នោះ ។

ដោយការបដិបត្តិយ៉ាងនេះ វេលាកន្លងទៅយូរ គ្រាមួយ នន្ទបណ្ឌិតត្រិះរិះថា យើងនឹងឲ្យមាតាបិតាបានបរិភោគផ្លែឈើតូចធំដែលយើងរកមកបានមុន ។ លោកទើបប្រញាប់ទៅកន្លងមុខបងប្រុសអំពីព្រឹកព្រលឹម រកផ្លែឈើតូចធំ ដែលល្មមនឹងរកបានមកអំពីកន្លែងដែលខ្លួនធ្លាប់រក្សា កាលថ្ងៃម្សិលខ្លះ កាលថ្ងៃម្សិលម្ងៃខ្លះ ហើយប្រញាប់នាំមកឲ្យមាតាបិតាបរិភោគមុន ។ មាតាបិតាបរិភោគផ្លែឈើហើយ ខ្ពុរមាត់ សមាទានឧបោសថ ។ ចំណែកសោណបណ្ឌិត ទៅកាន់ទីឆ្ងាយៗ ជ្រើសរើសរកផ្លែឈើតូចធំ ដែលមានរសដ៏ឆ្ងាញ់ កំពុងទុំជារល្អ ហើយនាំចូលទៅឲ្យ ។ លំដាប់នោះ មាតាបិតា ទើបពោលនឹងសោណបណ្ឌិតនោះថា កូនអើយ យើងបានបរិភោគផ្លែឈើ ដែលប្អូនប្រុសរបស់អ្នក រកមកឲ្យរៀបរយហើយអំពីព្រឹក (ឥឡូវនេះ) សមាទានឧបោសថហើយ ឥឡូវនេះ យើងមិនមានសេចក្តីត្រូវការ ។ ផ្លែឈើល្អៗ របស់សោណតាបសនោះ មិនមានអ្នកណាបានបរិភោគឡើយ ក៏វិនាសស្អុយទៅដោយប្រការដូច្នេះ ។ សូម្បីក្នុងថ្ងៃបន្ទាប់ៗមក ក៏ដូច្នោះទៀតដូចគ្នា

ព្រះសោណតាបសនោះ អាចទៅកាន់ស្ថានទីឆ្ងាយៗ ហើយនាំផ្លែឈើមកបានដោយអាការយ៉ាងនេះ ព្រោះលោកបានអភិញ្ញា ៥ ។ តែមាតាបិតាក៏មិនបានបរិភោគ ។

លំដាប់នោះ ព្រះមហាសត្វទើបគិតថា មាតាបិតារបស់យើងជាសុខុមាលជាតិ ប្អូនននុះទៅរកផ្លែឈើតូចធំ ខ្ចីខ្លះ ទុំខ្លះ មកឲ្យលោកបរិភោគ កាលជាដូច្នេះ លោកទាំងពីរនេះ ក៏នឹងមិនអាចរស់នៅយ៉ាងនេះ បានរហូតដល់អស់កាលយូរ យើងនឹងហាមលោក ។ លំដាប់នោះ សោណបណ្ឌិត ទើបហៅប្អូនប្រុសនោះមកហើយប្រាប់ថា នែប្អូន ចាប់ដើមតាំងពីនេះទៅកាលប្អូនរកផ្លែឈើមកបានហើយ ចូររង់ចាំឲ្យបងត្រឡប់មកសិន យើងទាំងពីរនាក់នឹងឲ្យមាតាបិតាបរិភោគព្រមៗគ្នា ។ សូម្បីកាលព្រះមហាសត្វពោលយ៉ាងនេះហើយ ព្រះននុះ ក៏ប្រាថ្នាតែសេចក្តីល្អរបស់ខ្លួនតែម្យ៉ាង ទើបមិនបានធ្វើតាមពាក្យរបស់បងប្រុស ។ លំដាប់នោះ ព្រះមហាសត្វគិតថា ប្អូនននុះមិនធ្វើតាមពាក្យរបស់យើង ធ្វើនាទីដែលមិនសមគួរ នឹងត្រូវបណ្តេញលោកចេញអំពីនេះ យើងតែម្នាក់ប៉ុណ្ណោះ នឹង

បដិបត្តិមាតាបិតា ទើបផ្ចាត់ម្រាមដៃបណ្តេញនន្ទតាបស ដោយវាចាថា "នែនន្ទៈ អ្នកឯងជាមនុស្សដែលមិននៅក្នុងពាក្យមិនធ្វើតាមឱវាទរបស់បណ្ឌិតទាំងឡាយ យើងជាបងប្រុសរបស់អ្នក មាតាបិតាជាភារៈរបស់យើងតែម្នាក់ យើងតែមួយប៉ុណ្ណោះនឹងបដិបត្តិមាតាបិតា អ្នកឯងនឹងមិនបានដើម្បីនៅក្នុងទីនេះ ចូរទៅក្នុងទីដទៃ" ។

នន្ទបណ្ឌិតនោះ ត្រូវសោណបណ្ឌិតបងប្រុសនោះបណ្តេញ មិនអាចនឹងនៅក្នុងសំណាក់របស់បងប្រុសបាន ទើបថ្វាយបង្គំបងប្រុស ហើយចូលទៅរកមាតាបិតា ប្រាប់សេចក្តីនោះឲ្យស្តាប់ ថ្វាយបង្គំមាតាបិតាហើយ ចូលទៅកាន់បណ្ណសាលារបស់ខ្លួន សម្លឹងមើលកសិណជាអារម្មណ៍ ក្នុងថ្ងៃនោះឯង ក៏ញុំាងអភិញ្ញា ៥ និងសមាបត្តិឲ្យកើតឡើងបាន ហើយគិតថា យើងនឹងនាំខ្សាច់កែវ (**រតនវាលុក**) មកពីជើងភ្នំសិនេរុពេយចុះក្នុងបរិវេណបណ្ណសាលានៃបងប្រុសរបស់យើង ក៏ជាការត្រឹមតែល្មមឲ្យបងប្រុសអភ័យទោសយើងបាន សូម្បីការធ្វើយ៉ាងនេះនឹងមិនល្អ , យើងក៏នឹងនាំទឹកមកពីស្រះអនោតត្ត

ស្រោចចុះក្នុងបរិវេណបណ្ណសាលានៃបងប្រុសរបស់យើង ក៏ល្មមញ៉ាំងបងប្រុសឲ្យអភ័យយើងបាន សូម្បីការធ្វើយ៉ាងនេះនឹងមិនល្អ , បើយើងគប្បីធ្វើបងប្រុសរបស់យើងឲ្យអភ័យយើងបាន ដោយអំណាចទេវតាទាំងឡាយ យើងនឹងនាំស្តេចមហារាជទាំង ៤ និងស្តេចសក្កៈមក ក៏ល្មមញ៉ាំងបងប្រុសឲ្យអភ័យទោសបាន សូម្បីយ៉ាងនេះនឹងនៅមិនល្អ , យើងនឹងទៅនាំព្រះរាជាទាំងឡាយ មានព្រះបាទមនោជៈដែលជាព្រះរាជាដ៏ប្រសើរ ក្នុងជម្ពូទ្វីបទាំងអស់នេះ ទៅជាប្រធាន ក៏ល្មមនឹងឲ្យបងប្រុសអភ័យទោសយើងបាន កាលជាដូច្នេះគុណសេចក្តីល្អនៃបងប្រុសរបស់យើង ក៏នឹងផ្សាយទូទៅក្នុងជម្ពូទ្វីបទាំងអស់ នឹងប្រាកដដូចជាព្រះចន្ទ្រ និងព្រះអាទិត្យដូច្នេះ ។

ខណៈនោះ ព្រះនន្ទតាបសនោះ ក៏ហោះទៅដោយឫទ្ធិចុះទៀបទ្វារព្រះរាជនិវេសន៍របស់ព្រះរាជានោះ ក្នុងព្រហ្មវឌ្ឍននគរ បង្គាប់ឲ្យរាជបុរសក្រាបទូលចំពោះព្រះរាជាថា បានឮថាព្រះតាបសមួយអង្គ ត្រូវការចូលគាល់ព្រះអង្គ ។ ព្រះរាជា ទ្រង់ត្រិះរិះថា យើងឃើញបព្វជិតនឹងបានប្រយោជន៍អ្វី ប្រហែលជា

បព្វជិតរូបនោះគង់នឹងមកដើម្បីត្រូវការអាហារដោយពិត ទើបចាត់ចែងបញ្ជូនកត្តាហារទៅថ្វាយ។ ព្រះតាបស មិនប្រាថ្នាកត្ត ។ ព្រះអង្គទើបបញ្ជូនអង្ករទៅថ្វាយ ព្រះតាបសនោះ ក៏មិនបានប្រាថ្នាអង្ករ ។ ទើបទ្រង់បញ្ជូនសំពត់ទៅថ្វាយ ព្រះតាបសក៏មិនបានទទួលសំពត់ ។ ទើបទ្រង់បញ្ជូនម្ជុរស្លាទៅថ្វាយ ។ ព្រះតាបសនោះ ក៏មិនបានទទួលម្ជុរស្លា ។ លំដាប់នោះ ព្រះអង្គទើបទ្រង់បញ្ជូនទូតទៅកាន់សំណាក់របស់ព្រះតាបសនោះ ថាលោកម្ចាស់មកហើយ ដើម្បីប្រាថ្នាប្រយោជន៍អ្វី ព្រះតាបសកាលត្រូវសួរទើបប្រាប់ថា យើងមកដើម្បីឧបដ្ឋាកព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទើបទ្រង់បង្គាប់ឲ្យមនុស្សទៅប្រាប់ថា "ពួកអ្នកឧបដ្ឋាករបស់យើងមានច្រើនណាស់ហើយ លោកតាបសចូរបំពេញនាទីតាបសរបស់ខ្លួនចុះ" ។ ព្រះតាបសស្តាប់ពាក្យនោះហើយ ទើបពោលថា យើងនឹងកាន់យករាជសម្បត្តិក្នុងជម្ពូទ្វីបទាំងអស់ ដោយកម្លាំងរបស់យើងហើយថ្វាយដល់ព្រះរាជារបស់លោកទាំងឡាយ ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ ទើបទ្រង់ត្រិះរិះថា "ធម្មតាថា បព្វជិតទាំងឡាយជាបណ្ឌិត គង់នឹងជ្រាបឧបាយយ៉ាងណាមួយ" ទើបទ្រង់បង្គាប់ឲ្យនិមន្តព្រះតាបសនោះចូលមក ឲ្យគង់លើអាសនៈ ទ្រង់ថ្វាយបង្គំហើយត្រាស់សួរថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន បានឮថា ព្រះគុណម្ចាស់នឹងកាន់យករាជសម្បត្តិក្នុងជម្ពូទ្វីបទាំងអស់ហើយ លើកឲ្យដល់ខ្ញុំម្ចាស់ឬ ។ ព្រះតាបសទូលថា ពិតដូច្នោះមហាបពិត្រ ព្រះរាជាត្រាស់ថា លោកម្ចាស់នឹងកាន់យកបានយ៉ាងណា ។ ព្រះតាបសទូលថា "មហាពិត្រ អាត្មាភាពនឹងមិនឲ្យលោហិត ដោយហោចទៅសូម្បីត្រឹមតែរុយតូចផឹកបាន ឲ្យកើតឡើងដល់អ្នកណាមួយឡើយ ទាំងមិនធ្វើការបំណាយស្បៀងនៃព្រះរាជទ្រព្យរបស់ព្រះអង្គផង នឹងកាន់យកដោយឫទ្ធិរបស់អាត្មាភាពហើយ លើកថ្វាយចំពោះព្រះអង្គ ក៏ប៉ុន្តែថា មិនគួរធ្វើការបង្អែបង្អង់តែម្យ៉ាងប្រញាប់ស្ដេចចេញទៅក្នុងថ្ងៃនេះឯង ។ ព្រះរាជា ទ្រង់ជឿពាក្យរបស់នន្ទតាបសនោះ ហែហមទៅដោយពួកសេនង្គនិករស្ដេចចេញចាកព្រះនគរ បើថាក្ដៅកើតឡើងដល់សេនា នន្ទ-

បណ្ឌិត ក៏និម្មិតឲ្យមានស្រមោលធ្វើឲ្យមានម្ចប់ ត្រជាក់ដោយ ឫទ្ធិរបស់ខ្លួន កាលភ្លៀងធ្លាក់ ក៏មិនបានធ្លាក់ចុះខាងលើពួក សេនា ហាមការក្តៅនិងត្រជាក់ចេញបាន បណ្តាលឲ្យអន្តរាយ ទាំងអស់ជាដើមថា ចំរូង បន្លា និងគល់ឈើក្នុងចន្លោះផ្លូវ ឲ្យអន្តរធានបាត់ទៅអស់ ធ្វើផ្លូវឲ្យរៀបរយ ដូចជាមណ្ឌល នៃកសិណ សូម្បីខ្លួនឯង ក្រាលចម្មខណ្ឌអង្គុយលើបល្ល័ង្កមាន ពួកសេនាហែហមហើយ ហោះបណ្តែតទៅក្នុងអាកាស ។

ព្រះនន្ទបណ្ឌិតនោះ នាំពួកសេនាទៅដោយអាការយ៉ាង នេះ លុះដល់ដែនកោសលជាដំបូង ទើបបង្គាប់ឲ្យកងទ័ពឈប់ តាំងបន្ទាយមិនឆ្ងាយពីក្រុង ហើយបញ្ជូនទូតចូលទៅ ទូល ព្រះបាទកោសលរាជថា នឹងឲ្យការច្បាំងដល់ពួកយើង ឬថា នឹងឲ្យស្វេតឆត្រ ។ ព្រះបាទកោសលរាជនោះ ទ្រង់បានស្តាប់ ពាក្យរបស់ទូតក៏ទ្រង់ពិរោធត្រាស់ថា យើងមិនមែនព្រះរាជាឬអ្វី យើងនឹងឲ្យការច្បាំង ទ្រង់ធ្វើសេនាខាងមុខ ស្តេចលើកពល ចេញទៅ ។ សេនាទាំងពីរផ្នែកប្រារពនឹងច្បាំងគ្នា ។ លំដាប់ នោះ នន្ទបណ្ឌិតទើបនិម្មិតស្បែកខ្លា ដែលជាអាសនៈទីអង្គុយ

របស់ខ្លួនឲ្យធំសម្បើម ទើបទុកក្នុងចន្លោះកងទ័ពទាំង ២ ហើយទទួលកូនសរដែលពួកសេនាទាំង ២ ផ្នែក បាញ់គ្នាទៅមកដោយផែនស្បែកនោះឯង ។ សេនាសូម្បីត្រឹមតែអ្នកណាម្នាក់ដែលឈ្មោះថា កូនសរចាក់ហើយ មិនមានឡើយ ។ កងទ័ពសូម្បីទាំង ២ ផ្នែកនោះក៏អស់ សេចក្តីឲ្យស្វាហ៍ (ព្យាយាម) ឈរនៅព្រងើយ ព្រោះកូនសរដែលនៅក្នុងដៃអស់ទាំង ២ ផ្នែក នន្ទបណ្ឌិត ទើបទៅកាន់សំណាក់របស់ព្រះបាទមនោជរាជ ទូលលួងលោមព្រះទ័យថា ព្រះអង្គកុំទ្រង់ខ្លាចឡើយមហាបពិត្រ ហើយទៅកាន់សំណាក់របស់ព្រះបាទកោសលរាជ ទូលថា ព្រះ-អង្គកុំទ្រង់ខ្លាចឡើយ មហាបពិត្រ អន្តរាយនឹងមិនមានដល់ព្រះ-អង្គទេ រាជសម្បត្តិរបស់ព្រះអង្គ ក៏នៅជារបស់ព្រះអង្គដដែល សូមឲ្យព្រះអង្គ ទ្រង់ឱនលំទោនដល់ព្រះបាទ មនោជរាជ តែម៉្យាងប៉ុណ្ណោះ ព្រះបាទកោសលរាជ ទ្រង់ជឿ នន្ទបណ្ឌិតនោះក៏ទ្រង់ទទួលថា សាធុ (ប្រពៃហើយ) ដូច្នេះ ។ លំដាប់នោះ នន្ទបណ្ឌិត ទើបនាំស្តេចទៅកាន់សំណាក់របស់ ព្រះបាទមនោជ-រាជ ហើយទូលថា មហាបពិត្រព្រះបាទកោសលរាជ ទ្រង់ព្រម

ឱនលំទោនចំពោះព្រះអង្គ តែសូមឲ្យរាជសម្បត្តិរបស់ព្រះបាទ-កោសលរាជនេះ ចូរនៅជារបស់ទ្រង់ដូចដើមចុះ ។ ព្រះបាទ-មនោជរាជទ្រង់ទទួលថាសាធុ ទ្រង់ធ្វើព្រះបាទកោសលរាជ-អង្គនោះ ឲ្យនៅក្នុងអំណាចរបស់ព្រះអង្គ ហើយលើកពល សេនាទាំង ២ ផ្នែក ស្តេចទៅកាន់ដែនអង្គៈ បានដែនអង្គៈហើយ តពីនោះក៏ទៅកាន់ដែនមគធ បានដែនមគធ ដោយឧបាយយ៉ាង នេះ ទ្រង់ធ្វើព្រះរាជាទាំងឡាយក្នុងជម្ពូទ្វីបទាំងអស់ ឲ្យធ្លាក់នៅ ក្នុងអំណាចរបស់ព្រះអង្គបានទាំងអស់ តអំពីនោះ ក៏ជាអ្នកមាន ព្រះរាជាទាំងនោះជាបរិវារ ស្តេចទៅកាន់ព្រហ្មវឌ្ឍននគរតែម្តង ក៏ព្រះបាទមនោជរាជនេះ ទ្រង់កាន់យករាជសម្បត្តិដល់ទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបស្រេចរៀបរយ ។ ព្រះបាទមនោជរាជនោះ បង្គាប់ឲ្យព្រះរាជាទាំងនោះនាំរបស់ទំពា និងរបស់បរិភោគមាន ប្រការផ្សេងៗ អំពីរាជធានីរបស់ខ្លួនគ្រប់ៗនគរ ទ្រង់នាំព្រះរាជា ទាំង ១០១ ព្រះអង្គទាំងនោះ បបួលគ្នាផឹកគ្រឿងផឹកដ៏ធំ ព្រះរាជាទាំងនោះ រហូតដល់អស់ ៧ ថ្ងៃ ។

នន្ទបណ្ឌិតគិតថា ព្រះរាជានៅសោយសេចក្តីសុខដែលកើតពីភាពជាធំជរាបណា យើងនឹងមិនសម្តែងខ្លួនដល់ស្តេចជរាបនោះ ទើបត្រាច់ទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីបហើយ ទៅនៅក្នុងកញ្ចនគុហា (ល្អាងមាស) ក្នុងហិមវន្តប្រទេស ៧ ថ្ងៃ ។ សូម្បីព្រះបាទមនោជរាជ ក្នុងថ្ងៃទី ៧ ទ្រង់ក្រឡេកមើលសិរីរាជសម្បត្តិដ៏ធំក្រៃលែងរបស់ព្រះអង្គ ក៏ទ្រង់រលឹកដល់នន្ទ-បណ្ឌិតតាបសថា "ឥស្សរិយយសទាំងអស់នេះ មាតាបិតារបស់យើងមិនបានឲ្យទេ ពួកជនដទៃក៏មិនបានឲ្យដល់យើងដែរ កើតឡើងព្រោះអាស្រ័យនន្ទបណ្ឌិតតាបស ក៏យើងមិនបានឃើញលោកអស់ ៧ ថ្ងៃក្នុងថ្ងៃនេះហើយ ឥឡូវលោកឲ្យឥស្សរិយយសដល់យើង នៅក្នុងទីណាហ្ន៎ ។ នន្ទបណ្ឌិតនោះបានជ្រាបថា ស្តេចរលឹកដល់ខ្លួន ទើបហោះមកឈរក្នុងអាកាសត្រង់ព្រះភ័ក្ត្រព្រះរាជា ។ ព្រះរាជានោះ ទតព្រះនេត្រឃើញនន្ទតាបសមកឈរ ទើបទ្រង់ព្រះតម្រិះយ៉ាងនេះថា យើងមិនទាន់ជ្រាបថា ព្រះតាបសនេះជាទេវតា ឬមនុស្ស បើលោកជាទេវតា យើងនឹងធ្វើគ្រឿងសក្ការៈសម្រាប់ទេវតា ដល់ លោក

។ ព្រះរាជាអង្គនោះ កាលទ្រង់សាកសួរនន្ទបណ្ឌិតនោះឲ្យជ្រាបច្បាស់ ទើបត្រាស់ព្រះគាថាជាបឋមថា

លោកជាទេវតា ឬជាគន្ធព្វ ជាសក្កបុរិន្ទទៈ ឬជាមនុស្សមានឫទ្ធិ ធ្វើដូចម្ដេចយើងនឹងស្គាល់លោកបាន ។

នន្ទតាបសនោះ ស្ដាប់ពាក្យរបស់ព្រះរាជានោះហើយកាលនឹងទូលតាមសេចក្ដីពិត ទើបពោលគាថាទី ២ ថា ៖

អាត្មាភាពមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ អាត្មាភាព ជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជាទ្រទ្រង់នូវភារៈ(ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។

នន្ទបណ្ឌិតហៅព្រះរាជាព្រះអង្គនោះយ៉ាងនេះថា ភារថដូច្នេះ ក្នុងគាថានោះ ព្រោះព្រះអង្គជាអ្នកទ្រង់ទុកនូវភារៈរបស់ដែន ។

ព្រះរាជាទ្រង់បានស្ដាប់ពាក្យនោះហើយ ទើបទ្រង់ព្រះ-តម្រិះថា បានឮថា ព្រះតាបសនេះជាមនុស្ស លោកមានឧបការៈច្រើនយ៉ាងនេះដល់យើង យើងនឹងឲ្យលោកឆ្អែតគ្រប់គ្រាន់ដោយឥស្សរិយយស ទើបត្រាស់ថា

ការខ្វល់ខ្វាយបម្រើ មានភាពដែលលោកដ៏ចម្រើនធ្វើហើយ នេះជាការមិនមែនតិច កាលដែលភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចម្រើនអាចធ្វើមិនឲ្យមានភ្លៀងបាន ។ តអំពីនោះមក លោកដ៏ចម្រើនអាចធ្វើឲ្យម្លប់ដ៏ត្រជាក់បាន ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ខ្លាំង តពីនោះមក លោកដ៏ចម្រើនអាចធ្វើភ្លៀងការពារព្រួញ ក្នុងកណ្តាលនៃសត្រូវទាំងឡាយបាន ។ តពីនោះមក លោកដ៏ចម្រើនអាចធ្វើដែនទាំងឡាយដ៏សម្បូរណ៍ (ទីង) អ្នកដែនទាំងនោះឲ្យលុះក្នុងអំណាច (របស់យើងខ្ញុំ) តពីនោះមក លោកដ៏ចម្រើនអាចធ្វើក្សត្រិយ៍ ១០១ ឲ្យជាចំណុះ (នៃយើងខ្ញុំបាន) ។ យើងខ្ញុំត្រេកអរនឹងលោកដ៏ចម្រើន លោកចង់បានរតនៈ (ណា) ចូរទទួលយករតនៈនោះចុះ យើងខ្ញុំប្រគេនយានដំរី រថ សេះ ពួកនាងនារីដែលប្រដាប់ស្រេចទាំងលំនៅគួរឲ្យត្រេកអរទាំងឡាយ ដល់លោកដ៏ចម្រើន ។ មួយទៀត យើងខ្ញុំប្រគេនដែនអង្គៈ ឬមគធៈ ដល់លោកដ៏ចម្រើន មួយទៀត យើងខ្ញុំសប្បាយចិត្តប្រគេនដែនអស្សកៈ ឬដែនអវន្តិដល់លោក ។ យើងខ្ញុំប្រគេនរាជ្យពាក់កណ្តាលដល់

លោកដ៏ចម្រើន បើលោកត្រូវការដោយរាជ្យ លោកចង់បានរបស់ណា (គ្រប់យ៉ាងដែលខ្ញុំពោលមកហើយទាំងនេះ) សូមត្រួតត្រារបស់នោះ (ចូរប្រាប់ គឺចូរបង្គាប់វត្ថុនោះដល់ខ្ញុំ)ចុះ ។

នន្ទបណ្ឌិតតាបស បានស្តាប់ព្រះតម្រាស់នោះហើយ កាលនឹងចង្អុលបង្ហាញ សេចក្តីប្រាថ្នារបស់ខ្លួនឲ្យជាក់ច្បាស់ ទើបទូលថា "អាត្មាភាព មិនត្រូវការដោយរាជ្យ ដោយនគរ ឬដោយទ្រព្យ ទាំងមិនត្រូវការដោយជនបទទេ" ។

នន្ទបណ្ឌិតទូលតទៅថា ម្នាលមហាបពិត្រ បើព្រះអង្គមានសេចក្តីស្រឡាញ់ក្នុងអាត្មាភាព សូមបានទ្រង់ធ្វើតាមពាក្យរបស់អាត្មាភាពត្រឹមតែម្យ៉ាង ហើយទូលជាគាថាថា "ក្នុងព្រៃ ក្នុងដែនជាអាណាខេត្តរបស់ព្រះអង្គដ៏ចម្រើន មានអាស្រមមួយ មាតាបិតារបស់អាត្មាភាពទាំងពីរនាក់ នៅក្នុងអាស្រមនោះ ។ អាត្មាភាព មិនបានធ្វើបុណ្យចំពោះបុព្វាចារ្យទាំងនោះ យើងធ្វើព្រះអង្គដ៏ចម្រើនឲ្យប្រសើរលើសលុប ឲ្យសមនូវការរួបរួមជាមួយនឹងសោណបណ្ឌិតតាបស" ។

លំដាប់នោះ ព្រះរាជាត្រាស់ចំពោះនន្ទតាបសនោះថា ៖

បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោក ដែលលោកពោលនឹងខ្ញុំ សូមលោកប្រាប់ហេតុនោះដល់យើង ខ្ញុំតើឲ្យពួកជនប៉ុន្មាននាក់ ជាអ្នកជួយអង្វរករ ។

នន្ទបណ្ឌិតតាបសទូលថា ៖

ពួកគហបតិមហាសាលជាងមួយរយ ពួកព្រាហ្មណ៍មហាសាលជាងមួយរយ នឹងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិដ៏ខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើន ទើបល្មមជាអ្នកជួយអង្វរករ ។

លំដាប់នោះ ព្រះរាជាត្រាស់ចំពោះនន្ទបណ្ឌិតនោះថា ៖

ពួកអ្នករក្សាដំរី ពួកអ្នករក្សាសេះ ចូរនាំគ្នាចាត់ចែងនូវពួកដំរីពួកសេះ ម្នាលសារថី អ្នកចូរជ្រាបរថ អ្នកទាំងឡាយ ចូរយកគ្រឿងប្រដាប់សម្រាប់ចង (ឯដំរីសេះរថ) ជនទាំងឡាយ ចូរលើកទង់ជ័យត្រង់ជើងទង់ជ័យដែលតម្កល់លើរថ អញនឹងទៅកាន់អាស្រមជាទីនៅនៃកោសិយគោត្ត ។

ព្រះសាស្តា កាលនឹងទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា ៖

**លំដាប់ពីនោះមក ព្រះរាជាបានយាងទៅ ដោយសេនាប្រកបដោយអង្គ ៤ ទ្រង់ស្តេចទៅកាន់អាស្រមជាទីរីករាយជាទីនៅនៃកោសិយគោត្ត ។**

នេះជាគាថា ដែលព្រះសម្មាសម្ពុទ្ធត្រាស់ ។

បណ្តាបទទាំងនោះ បទថា **តតោ ច** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាព្រះអង្គនោះ គ្រាត្រាស់យ៉ាងនេះហើយក្នុងលំដាប់នោះ ទើបទ្រង់នាំពួកក្សត្រ ១០១ ព្រះអង្គ ហែហមដោយសេនាដ៏ធំ ឲ្យព្រះតាបសនន្ទបណ្ឌិតនាំមុខ ស្តេចចេញចាកព្រះនគរ ។ បទថា **ចតុរង្គិនិ** សេចក្តីថា ស្តេចទៅកាន់អាស្រមព្រមដោយចតុរង្គសេនា ។ សូម្បីស្តេចកំពុងប្រថាប់នៅក្នុងចន្លោះផ្លូវ លោកក៏ពោលទុកយ៉ាងនេះ ព្រោះស្តេចត្រូវទៅយ៉ាងពិតប្រាកដ នន្ទបណ្ឌិតតាបស ធ្វើដំណើរទៅព្រមដោយពួកពលសេនាប្រមាណបាន ២៤ អក្ខោភិណី និម្មិតផ្លូវដែលមានទទឹង ៨ ឧសភៈ ឲ្យរៀបរយដោយអានុភាពនៃឫទ្ធិ

ហើយក្រាលកម្រាលស្បែកក្នុងអាកាសនោះឯង គង់ចម្រើនសមាធិលើកម្រាលស្បែកនោះ មានសេនាហែហមហើយពោលពាក្យដែលប្រកបដោយធម៌ មួយអន្លើដោយព្រះរាជាដែលប្រថាប់លើ-កដីរ ដែលប្រថាប់ហើយ ស្តេចទៅដោយហាមនូវអន្តរាយមានគ្រជាក់និងក្តៅជាដើម បានទៅហើយ ។

ក្នុងថ្ងៃដែលទន្ទុតាបសនោះ មកដល់អាស្រម សោណ-បណ្ឌិតតាបស រំពឹងថា ប្អូនប្រុសរបស់យើងចេញទៅយូរដល់ទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃហើយ ទើបពិចារណាមើលដោយទិព្វចក្ខុញាណថា ឥឡូវនេះ លោកទៅនៅទីណាហ្ន៎ ក៏ឃើញថាប្អូនប្រុសរបស់យើងកំពុងនាំព្រះរាជា ១០១ អង្គ ព្រមដោយបរិវារប្រមាណ ២៤ អក្ខោភិណី មកដើម្បីនឹងឲ្យយើងលើកលែងទោសពិតប្រាកដ ទើបត្រិះរិះតទៅថា ក្សត្រទាំងនេះ ព្រមទាំងបរិស័ទបានឃើញបាដិហារ្យរបស់ប្អូនប្រុស យើងជាច្រើនតែមិនទាន់បានជ្រាបអានុភាពរបស់យើង ក៏នឹងនាំគ្នាមកចរចាគ្របសង្កត់ គម្រាម មើលងាយយើងថា អ្នកនេះឯងជាជដិល-កោង មិនដឹងប្រមាណខ្លួនឯងឡើយ នឹងមកប្បាំងជាមួយព្រះ-

គុណម្ចាស់របស់យើងទាំងឡាយ ដូច្នេះ ទាំងអស់គ្នា ក៏នឹងគប្បីមាននរកអវិចីជាទីទៅក្នុងខាងមុខ យើងនឹងសម្ដែងឥទ្ធិបាដិហារ្យដល់ពួកក្សត្រ និងបរិស័ទទាំងនេះ ព្រះសោណបណ្ឌិតតាបសនោះ ទើបដាក់ដងរែកសម្រាប់រែកទឹកក្នុងអាកាស ដោយមិនឲ្យត្រូវស្មាប្រមាណ ៤ ធ្នាប់ ហើយហោះទៅផ្លូវអាកាស ក្នុងទីមិនឆ្ងាយពីព្រះរាជា ដើម្បីនឹងនាំយកទឹកមកពីស្រះអនោតត្តនន្ទបណ្ឌិតតាបស លុះឃើញបងប្រុសហោះមក មិនអាចនឹងសម្ដែងខ្លួនបាន ទើបអន្តរធានទៅក្នុងទីអង្គុយនោះឯង គេចជៀសចេញ ចូលទៅកាន់ព្រៃហិមវន្ត ព្រះបាទនោរាជ ទតព្រះនេត្រឃើញព្រះសោណបណ្ឌិតតាបសនោះ ហោះមកដោយភេទឥសីដែលគួរជ្រះថ្លា ទើបត្រាស់ព្រះគាថាថា ៖

ដងរែក ជាវិការៈនៃឈើក្ដុម្ពរបស់អ្នកណា ដែលទៅដងទឹក ហើយមិនប៉ះពាល់ស្មាទៅលើអាកាសចំនួន ៤ ធ្នាប់ ។

សូម្បីកាលព្រះរាជាត្រាស់យ៉ាងនេះហើយ ព្រះមហាសត្វទើបពោលគាថា ២ គាថាថា ៖

បពិត្រមហារាជ អាត្មាភាពជាតាបស ឈ្មោះសោណៈ

ប្រកបដោយវត្ត (គឺជាអ្នកបរិបូរណ៍ដោយសីល និងមារយាទ) មិនខ្ជិលប្រអូស ចិញ្ចឹមមាតាបិតាទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស អាត្មាភាព រលឹកឃើញឧបការដែលមាតាបិតាធ្វើក្នុងកាលមុនហើយ ក៏យកផ្លែឈើនិងមើមឈើក្នុងព្រៃមកចិញ្ចឹមមាតាបិតា ។

ព្រះរាជា ទ្រង់បានស្តាប់ពាក្យនោះហើយ មានព្រះប្រាថ្នានឹងទតព្រះនេត្រមើលអាស្រម ព្រមដោយព្រះពោធិសត្វនោះទើបបានត្រាស់គាថាដែលជាលំដាប់តទៅថា ៖

យើងខ្ញុំចង់ទៅកាន់អាស្រម ជាទីនៅរបស់កោសិយ-គោត្ត បពិត្រព្រះសោណៈ សូមលោកម្ចាស់ប្រាប់ផ្លូវដល់យើង យើងនឹងទៅកាន់អាស្រម ។

លំដាប់នោះ ព្រះមហាសត្វ ទើបនិម្មិតផ្លូវសម្រាប់ទៅកាន់អាស្រមបទដោយអានុភាពរបស់ខ្លួន ហើយទូលចំពោះព្រះបាទមនោរាជនោះថា ៖

បពិត្រព្រះរាជា ផ្លូវដើរចុះតែជើង ១ នេះ មានព្រៃមានពណ៌ដូចជាផ្ទៃមេឃ ដេរដាសដោយដើមរលួសគ្គុធន្ទុះ ជាទី

នៅរបស់កោសិយគោត្ត ។

សេចក្តីនៃពាក្យដែលជាគាថានោះ មានដូចតទៅនេះ មហាបពិត្រផ្លូវនេះ ជាផ្លូវដើងសម្រាប់ដើរទៅបានត្រឹមតែម្នាក់ សូមអញ្ជើញព្រះអង្គស្តេចទៅ ដោយទិសាភាគដែលពួកឈើដែលដេរដាសដោយដើមរលួសផ្អុង មានផ្ការីកល្អហើយ មានពណ៌ដូចជាផ្ទៃមេឃប្រាកដនេះ ។ បិតារបស់អាត្មាភាពកោសិយគោត្រ នៅក្នុងអាស្រមនេះ នោះគឺអាស្រមនៃបិតារបស់អាត្មាភាព ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា : លុះមហាឥសីពោលពាក្យនេះ ទូលប្រាប់ពួកក្សត្រិយ៍ហើយ ប្រញាប់ប្រញាល់ចៀសចេញទៅ (កាន់ស្រះអនោតត្ត) តាមអាកាសវេហាស៍ មហាឥសី ក៏បោសសំអាតអាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលា ហើយជំរាបបិតាឲ្យជ្រាបថា បពិត្រមហាឥសី ព្រះរាជាទាំងនេះ មានជាតិខ្ពស់ មានយស យាងមក សូមព្រះបិតាចេញអំពីអាស្រមមក គង់ចាំទទួល ។ មហាឥសីឮពាក្យនោះរបស់កូននោះហើយ ក៏ប្រញាប់

ប្រញាល់ចេញអំពីអាស្រមមកអង្គុយជិតទ្វារ ។

នេះជាព្រះគាថា ដែលព្រះសម្មាសម្ពុទ្ធត្រាស់ ។

បណ្ដាបទទាំងនោះ បទថា បក្កាមិ បានដល់ ទៅកាន់ស្រះអនោតត្ត ។ បទថា អស្សមំ បរិមជ្ជិត្វា សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ឥសីនោះប្រញាប់ទៅកាន់ស្រះអនោតត្តដោយឆាប់រហ័ស ។ ហើយដងទឹកផឹកមក កាលព្រះរាជាទាំងនោះ មិនទាន់ទៅដល់អាស្រមនុ៎ះឯង ក៏ត្រឡប់មកមុនចាត់ចែងតម្កល់ទឹកផឹកទុកក្នុងរោងទឹក ហើយអប់ទឹកដោយផ្កាឈើក្នុងព្រៃទាំងឡាយ ដោយគិតថា មហាជននឹងបានផឹកទឹក ហើយកាន់យកឈើអំបោសមកបោសអាស្រម ចាត់ចែងអាសនៈរបស់បិតាត្រង់ទ្វារបណ្ណសាលាហើយ ចូលទៅប្រាប់ឲ្យបិតាបានជ្រាប ។ បទថា ឧច្ចារិសិ បានដល់ អង្គុយលើអាសនៈខ្ពស់ ។

ចំណែកមាតារបស់ព្រះពោធិសត្វ អង្គុយលើអាសនៈទាបជាងបិតា ដែលតាំងនៅខាងក្រោយ ។ ព្រះពោធិសត្វអង្គុយនៅលើអាសនៈក្រោម ក្នុងចំណែកមួយខាង ។

ចំណែកទន្ទបណ្ឌិតតាបស ក្នុងវេលាដែលព្រះពោធិសត្វទៅដងទឹកផឹកមកពីស្រះអនោតត្ត ត្រឡប់មកកាន់អាស្រមហើយ ទើបទៅកាន់សំណាក់ព្រះរាជា ឲ្យកងទ័ពឈប់សម្រាកក្នុងទីជិតអាស្រម ។ លំដាប់នោះ ព្រះបាទមនោជរាជ ទ្រង់ស្រង់(ទឹក) ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង មានក្សត្រិយ៍ ១០១ ព្រះអង្គ ហែហមជាបរិវារ នាំទន្ទបណ្ឌិតស្តេចចូលទៅកាន់អាស្រម ដោយភាពជាអ្នកប្រសើរលើសដោយសេចក្តីល្អនៃសិរីដ៏ធំក្រៃលែង ដើម្បីសូមឲ្យព្រះពោធិសត្វលើកលែងទោស ។ លំដាប់នោះ បិតាព្រះពោធិសត្វឃើញព្រះរាជានោះស្តេចមកដូចនោះ ទើបសួរព្រះពោធិសត្វ សូម្បីព្រះពោធិសត្វក៏បានពោលដល់ការប្រព្រឹត្តិទៅទាំងអស់ឲ្យបិតាបានជ្រាប ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា : កោសិយគោត្តតាបស ឃើញស្តេចនោះដូចជារុងរឿងដោយតេជ មានពួកក្សត្រិយ៍ហែហមកំពុងយាង ហើយបានពោលពាក្យនេះថា ស្គរសម្ភោរ ស័ង្ខ ស្គរតូច និងមហោរធឹករបស់អ្នកណា ញុំាងស្តេចជាបុគ្គលប្រសើរលើរថឲ្យរីករាយទៅ

ខាងមុខ ៗ (ទីបំផុតថ្វាស) នៃអ្នកណា (បិទបាំង) ដោយដំបារ
មាសដ៏ធំ មានពណ៌ដូចជាផ្កាកបន្ទោរ ប្រសកំលោះណា សៀត
បំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក ៗ អ្នកណាមាន
មុខរុងរឿងភ្លឺចាំង ដូចជាមាសភ្លឺចិញ្ចាចត្រង់មាត់បាវ ស្រដៀង
នឹងរងើកភ្លើងនៃឧសគគីរ រុងរឿងដោយសិរី ហើយដើរមក ៗ
អ្នកណា បាំងឆត្រព្រមទាំងឆ្អឹង ជាទីរីករាយនៃចិត្ត ការពារ
រស្មីព្រះអាទិត្យ អ្នកណារុងរឿងដោយសិរី ហើយដើរមក ៗ
ពួកជនបិទបាំងជុំវិញខ្លួននៃអ្នកណា ដែលមានបុណ្យដ៏ប្រសើរ
កំពុងជិះលើកនៃដំរី ដោយផ្ទិតពោមសត្វដ៏ឧត្តមហើយដើរមក ៗ
ពួកឆត្រស និងពួកអាជានេយ្យ ប្រដាប់ដោយក្រោះខ្នាន់ខ្នាប់
ជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរី ហើយដើរមក ៗ
ពួកក្សត្រិយ៍មួយរយមួយ សុទ្ធតែមានយស ជាស្តេចចំនុះ ដើរ
ហែហមជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរីដើរមក ៗ
ពួកសេនាប្រកបដោយអង្គ ៤ គឺដំរី ១ សេះ ១ រថ ១
ពលថ្មើរជើង ១ ដើរហែហមជុំវិញ (នៃអ្នកណា) អ្នកណា
រុងរឿងដោយសិរី ដើរមក ៗ សេនាដ៏ធំនេះ មិនមានអ្នក

ណាមួយឲ្យរំភើបបាន មិនមានទីបំផុតដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា ។

ព្រះមហាសត្វ កាលនឹងប្រាប់ព្រះនាមរបស់ព្រះបាទមនោជរាជនោះ ទើបបានពោលគាថា ២ គាថាទាំងនេះថា ៖

ព្រះបាទមនោជៈ ជាព្រះរាជាប្រសើរ ជាងពួកព្រះរាជា ដូចជាព្រះឥន្ទ្រជាធំជាងពួកទេវតា ក្នុងឋានត្រៃត្រិង្ស ដែលមានជ័យជំនះ បានដល់នូវភាពជាបរិស័ទនៃនន្ទតាបស មកកាន់អាស្រមនៃពួកព្រហ្មចារីបុគ្គល (ដើម្បីខមាទោសនឹងយើង) ។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយ ឲ្យរំភើបបាន មិនមានទីបំផុតដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃព្រះបាទមនោជៈនោះ ។

បទថា **កញ្ចនបដ្តេន** សេចក្តីថា ព្រះតាបសដែលជាបិតាសួរថា នៃកូន ទីបំផុតនៃថ្ងាស់របស់អ្នកណា ពាក់ហើយដោយជំបារមាស គឺឧណ្ហិស្សដែលធ្វើដោយមាស មានពណ៌ដូចជាផ្លេកបន្ទោរ ។ បទថា **យុវា** បានដល់ កំលោះ ។ បទថា **កលាបសន្នទ្ធោ** បានដល់ មានបំពង់ព្រួញ កូនសរដែល

ចងស៊ីកស្រេចហើយ ។

បទថា **អក្ខោភណី** បានដល់ មិនអាចរាប់បាន ។ បទថា **សាគរសេរ្យូវ** បានដល់ រកទីបំផុតមិនបាន ដូចជាលេកក្នុងមហាសមុទ្រដូច្នោះ ។ បទថា **រាជាភិរាជា** សេចក្តីថា ឈ្មោះថាជាព្រះរាជាភិរាជ ព្រោះជាអ្នកដែលព្រះរាជាទាំង ១០១ អង្គបូជា ហើយ ឬថា ជាព្រះរាជាដ៏ក្រៃលែងជាងព្រះរាជាទាំងនោះ ។ បទថា **ជយតំ បតិ** សេចក្តីថា ជាអ្នកចម្រើនបំផុត **អជ្ឈាវរំ** សេចក្តីថា ជាងទេវតាជាន់តាវត្តិង្សទាំងឡាយ ដែលដល់នូវជំនះហើយ ។ បទថា **ព្រះរាជាព្រះអង្គនោះ** ចូលដល់គាព ជាបរិស័ទរបស់នន្ទតាបស ដើម្បីខមាទោសនឹងយើង ។

ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ពួកព្រះរាជាទាំងអស់ លាបស្រឡាបដោយខ្លឹមចន្ទន៍ទ្រង់កាសិកព័ស្ត្រដ៏ឧត្តម (ដែលមកពីដែនកាសី) បានផ្គងអញ្ចូលីចូលទៅរកពួកឥសី ។

លំដាប់នោះ ព្រះបាទមនោជរាជ ទ្រង់នមស្សការបិតារបស់ព្រះពោធិសត្វនោះហើយ ប្រថាប់គង់ក្នុងចំណែកមួយ

កាលនឹងទ្រង់ធ្វើបដិសណ្ឋារ ទើបត្រាស់គាថា ២ គាថាថា ៖

លោកដ៏ចម្រើន មានសេចក្តីសុខស្រួលទេឬ លោក-ដ៏ចម្រើន មានអនាម័យទេឬ លោកទាំងឡាយចិញ្ចឹមជីវិតដោយការស្វែងរកឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូស ពស់ មានតិចតួចដែរឬ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ ។

ព្រះតាបសបិតារបស់ព្រះពោធិសត្វ ពោលនឹងព្រះបាទមនោជរាជ ថា ៖

បពិត្រព្រះរាជា អាត្មាភាព មានសេចក្តីស្រួលទេ បពិត្រព្រះរាជា មួយទៀត អាត្មាភាព មិនមានសេចក្តីឈឺចាប់ទេ អាត្មាភាព ចិញ្ចឹមជីវិតដោយការស្វែងរក(ផលាផល) ស្រួលទេ ទាំងមើមឈើនិងផ្លែឈើក៏មានច្រើន ។ មួយទៀត ពួករបោម មូស ពស់ ក៏មានតិចតួចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគ-សាហាវ ក៏មិនបៀតបៀនអាត្មាភាពទេ ។ អាត្មាភាព មកនៅក្នុងអាស្រមនេះ អស់ប្រជុំនៃឆ្នាំជាច្រើន មិនដែលស្គាល់អាពាធមិនជាទីត្រេកអរនៃចិត្តកើតឡើងទេ ។ បពិត្រមហារាជ ព្រះអង្គ

យានមកល្អហើយ មួយទៀត ព្រះអង្គ មិនមែនយានមកអាក្រក់ទេ ព្រះអង្គជាឥស្សរៈ យានមកដល់ហើយវត្ថុណាមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល ។ បពិត្រព្រះរាជាសូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែស្រគំ ផ្លែមាក់ជោកមានរសឆ្ងាញ់ពិសា ដូចជាទឹកឃ្មុំ ។ ទឹកត្រជាក់នេះ អាត្មាភាពបានដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹកនោះចុះ ប្រសិនបើទ្រង់ត្រូវការ ។

(ព្រះរាជា...) របស់ណា ដែលលោកឲ្យហើយ (របស់នោះ)ឈ្មោះថា យើងខ្ញុំទទួលហើយ ទាំងបានធ្វើឲ្យជាជំនូនដល់ជនទាំងពួង លោកទាំងឡាយ ចូរស្តាប់ពាក្យនទបណ្ឌិតតាបសលោកនឹងនិយាយឥឡូវនេះ ពួកយើងជាបរិស័ទនៃនទបណ្ឌិតតាបសបានមកកាន់សំណាក់នៃលោកដ៏ចម្រើន សោណៈ-បណ្ឌិតដ៏ចម្រើន ចូរស្តាប់ពាក្យនៃយើងផង នៃបរិស័ទរបស់នទបណ្ឌិតតាបសផង ។

បទថា សព្វស្ស អគ្ឃិយំ សេចក្តីថា ខ្ញុំទាំងឡាយសួរហើយដោយវត្ថុណា វត្ថុនោះឈ្មោះថា ជាការដែលខ្ញុំទាំង-

ឡាយទទួលហើយ មួយទៀត ឈ្មោះថា វត្ថុនោះ ជារបស់ដែលព្រះគុណម្ចាស់ឲ្យហើយតែម្តង អធិប្បាយថា ព្រះគុណម្ចាស់ធ្វើឲ្យជារបស់ដល់ជននេះទាំងអស់ ដោយការធ្វើមានប្រមាណត្រឹមតែប៉ុណ្ណោះ គឺធ្វើវត្ថុទាំងអស់ដល់ខ្ញុំទាំងឡាយមុន ។ បទថា ឆន្ទស្សាមិ សេចក្តីថា ព្រះគុណម្ចាស់ធ្វើវត្ថុទាំងអស់ដល់ខ្ញុំទាំងឡាយមុនហើយ ឥឡូវនេះ នន្ទបណ្ឌិត ប្រាថ្នានឹងពោលពាក្យបន្តិចបន្តួច សូមព្រះគុណម្ចាស់ ចូរស្តាប់ពាក្យរបស់លោកសិន ។ បទថា អជ្ឈាវរម្ហា សេចក្តីថា ព្រះរាជាត្រាស់ថា យើងខ្ញុំទាំងឡាយ មកហើយដោយហេតុដទៃក៏ទេ ក៏ខ្ញុំទាំង-ឡាយជាបរិស័ទរបស់នន្ទបណ្ឌិតមកហើយ ដើម្បីនឹងញ៉ាំងលោកទាំងឡាយឲ្យលើកលែងទោស ។ បទថា ភវំ សេចក្តីថា ព្រះគុណម្ចាស់ដែលមានឈ្មោះថា សោណបណ្ឌិត ចូរស្តាប់ចុះ ។

កាលព្រះបាទមនោជរាជ ត្រាស់យ៉ាងនេះហើយ នន្ទ-បណ្ឌិត ទើបក្រោកចាកអាសនៈថ្វាយបង្គំមាតាបិតា និងបង-ប្រុស កាលចរចាជាមួយបរិស័ទ ទើបពោលថា ៖

ពួកគហបតិមហាសាលជាងមួយរយ ពួកព្រាហ្មណ៍

មហាសាលជាងមួយរយ និងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើន សូមជ្រាបតាមសំដីរបស់អាត្មាភាពចុះ ។ ពួកជនដែលមកជួបជុំគ្នា ពួកយក្ស ពួកភូតនិងទេវតា ក្មេងមានក្នុងអាស្រមក្នុងព្រៃនេះ ចូរស្តាប់នូវពាក្យរបស់អាត្មា ។ អាត្មា ធ្វើនមស្ការដល់ពួកភូតហើយ នឹងនិយាយចំពោះឥសី (ឈ្មោះសោណបណ្ឌិត) ដែលមានវត្តល្អថា ខ្ញុំនោះហើយដែលកោសិយគោត្ត សន្មតថាជាដើមដៃស្តាំរបស់លោក ។ បពិត្រអ្នកមានព្យាយាម ការទំនុកបម្រុងមាតាបិតានេះ ជាបុណ្យរបស់ខ្ញុំដែលជាអ្នកប្រាថ្នាចិញ្ចឹមបិតានិងមាតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូមលោកកុំឃាត់ខ្ញុំឡើយ ។ ការទំនុកបម្រុងមាតាបិតានុ៎ះ ពួកសប្បុរសបានដឹងហើយ សូមលោកលះនូវការទំនុកបម្រុងមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ(កុសល) ដោយការខ្នះខ្នែង និងការបម្រើយូរយារណាស់មកហើយ (ឥឡូវនេះខ្ញុំចង់ធ្វើ) បុណ្យទាំងឡាយដល់មាតានិងបិតា សូមលោកប្រគល់សួគ៌ទេវលោកដល់ខ្ញុំ ។ បពិត្រឥសី លោកដឹងផ្លូវទៅកាន់សួគ៌ ទេវលោក

យ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ ក្នុងធម៌ ក៏យ៉ាងនោះដែរ ។ កិរិយានាំមកនូវសេចក្ដីសុខដល់មាតាបិតា ដោយការខ្នះខ្នែងនិងការបម្រើ ឥឡូវនេះ ជន(សោណបណ្ឌិត) ហាមឃាត់ខ្ញុំនោះចាកបុណ្យ ឈ្មោះថា ជាអ្នកពាំងផ្លូវដ៏ប្រសើរ (បានសួគ៌) ។

បណ្ដាបទទាំងនោះបទថា អរញ្ញេ ភូតភព្យានិ សេចក្ដីថា ភូតទាំងឡាយផង ទេវតាទាំងឡាយអ្នកដល់ហើយនូវដែននៃសេចក្ដីចម្រើនផង និងទេវតាកំលោះទាំងឡាយផង ពួកណា ។ ក្នុងព្រៃហិមវន្តប្រទេសនេះ ទេវតាទាំងអស់នោះ ចូរស្ដាប់ពាក្យរបស់ខ្ញុំ ។ បទថា ឆមោ កាត្វាន សេចក្ដីថា ព្រះនន្ទ-បណ្ឌិតនោះ កាលឲ្យសញ្ញានេះ ដល់បរិស័ទហើយ ធ្វើការនមស្ការដល់ទេវតាទាំងឡាយ ដែលកើតហើយក្នុងដងនៃព្រៃនោះនុ៎ះឯង ទើបបានពោលហើយ ។ សេចក្ដីនៃពាក្យនោះ មានអធិប្បាយថា ក្នុងថ្ងៃនេះឯង ទេវតាដែលនៅក្នុងហិមវន្តប្រទេសទាំងឡាយជាច្រើន គប្បីមកប្រជុំគ្នាដើម្បីនឹងស្ដាប់ធម្មកថារបស់បងប្រុសយើង ព្រោះហេតុនោះ នន្ទបណ្ឌិត ទើបបាន

ពោលថា ក៏ការនមស្ការនេះជាការនមស្ការដល់លោកទាំងឡាយ សូមលោកទាំងឡាយចូរជាសម្លាញ់របស់ខ្ញុំ ។ នន្ទបណ្ឌិតនោះ ផ្គងអញ្ជលីដល់ទេវតាទាំងឡាយ ញុំាងបរិស័ទឲ្យជ្រាបហើយ ទើបពោលពាក្យជាដើមថា ខ្ញុំនឹងពោលចំពោះឥសី ដូច្នេះ ។ ពាក្យថា ឥសិ ក្នុងគាថានោះ លោកពោលសំដៅដល់ សោណបណ្ឌិត ។ បទថា សម្មតោ សេចក្តីថា ធម្មតាថា បងប្រុសទាំងឡាយ រមែងជាអ្នកស្មើដោយរាងកាយ ព្រោះ ដូច្នោះ ព្រះនន្ទបណ្ឌិតនោះ ទើបសន្មតយកថា ខ្ញុំនោះជាដៃស្តាំ របស់លោក ទើបសម្តែងថា លោកទាំងឡាយ ទើបគួរដើម្បី លើកលែងទោសឲ្យដល់ខ្ញុំ ដោយហេតុនោះ ។ បទថា វីរ បានដល់ បពិត្របង អ្នកមានសេចក្តីព្យាយាម អ្នកមានសេចក្តី ប្រឹងប្រែងច្រើន ។ បទថា បុញ្ញមិទំ ឋានំ សេចក្តីថា នន្ទបណ្ឌិតពោលថា ដែលឈ្មោះថា ការទំនុកបម្រុងមាតាបិតា នេះ ជាបុណ្យ គឺជាហេតុញុំាងពួកសត្វឲ្យប្រព្រឹត្តទៅព្រមដើម្បី កើតក្នុងសួគ៌ ព្រោះដូច្នោះ លោកកុំហាមខ្ញុំ អ្នកធ្វើបុណ្យ នោះឡើយ ។ បទថា សត្ពិហោតំ សេចក្តីថា ពិតមែន ធម្មតា

ការទំនុកបម្រុងមាតាបិតានេះ បណ្ឌិតទាំងឡាយសរសើរ ហើយគឺចូលទៅដឹងហើយនិងពណ៌នាហើយ ។ បទថា មមេតំ ឧបនិស្សជ្ជ សេចក្តីថា សូមលោកចូរអនុញ្ញាត គឺចូរលះបង់ចូរឲ្យការទំនុកបម្រុងមាតាបិតានេះដល់ខ្ញុំចុះ ។ បទថា ឧដ្ឋានចាធចរិយាយ បានដល់ ដោយសេចក្តីព្យាយាម ជាហេតុឲ្យក្រោកឡើង និងដោយការបម្រើជើង ។ បទថា គតំ បានដល់លោកធ្វើកុសលទុកហើយអស់កាលយូរ ។ បទថា បុញ្ញានិ សេចក្តីថា ឥឡូវនេះ ខ្ញុំប្រាថ្នានឹងធ្វើបុណ្យក្នុងមាតាបិតាទាំងពីរ ។ បទថា មម លោកឧនោ សេចក្តីថា នន្ទបណ្ឌិត ពោលថា សូមលោកចូរឲ្យលោកសួគ៌ដល់ខ្ញុំនោះ ព្រោះថា ខ្ញុំធ្វើវត្ត គឺការទំនុកបម្រុងមាតាបិតាទាំង ២ នោះ នឹងបានឥស្សរិយយសប្រមាណមិនបានក្នុងទេវលោក សូមលោកចូរជាទាយករបស់ខ្ញុំនោះចុះ ។ បទថា តថេវ សេចក្តីថា លោករមែងដឹងដោយប្រការណា សូម្បីជនពួកដទៃដែលមាននៅក្នុងបរិស័ទនេះ ជនទាំងនោះ រមែងពោលនូវធម៌ទាំងឡាយមានប្រការផ្សេងៗ គឺចំណែកនៃធម៌ ពោលគឺភាពជាអ្នកប្រព្រឹត្តឱនលំទោន

ចំពោះបុគ្គលដែលចម្រើនបំផុតនេះ ដូច្នោះដែរ ។ សួរថា ជនទាំងនោះពោលយ៉ាងណា, ឆ្លើយថា ជនទាំងនោះពោលថា ធម៌គឺការទំនុកបម្រុងមាតាបិតានេះជាផ្លូវនៃសួគ៌ ។ បទថា សុខាវហំ សេចក្ដីថា នាំសេចក្ដីសុខមកឲ្យដល់មាតាបិតា ដោយការក្រោកឡើងនិងដោយការបម្រើ ។ បទថា តំ មំ សេចក្ដីថា សោណបណ្ឌិតជាបងប្រុស រមែងហាមគឺជំទាស់ខ្ញុំនោះ សូម្បីអ្នកបដិបត្តិប្រពៃយ៉ាងនេះ ចាកបុណ្យនោះ ។ បទថា អរិយ-មគ្គាវរោ សេចក្ដីថា រមែងហាមនូវផ្លូវនៃទេវលោកពោលគឺអរិយមគ្គ ។ នរៈនោះ ហាមនូវបុណ្យយ៉ាងនេះ គឺនរៈនេះឈ្មោះថា រមែងជាអ្នកហាមនូវផ្លូវនៃទេវលោកពោលគឺអរិយ-មគ្គ ដើម្បីសម្ដែងនូវសេចក្ដីស្រឡាញ់ដល់ខ្ញុំ ។

កាលនន្ទបណ្ឌិតពោលយ៉ាងនេះហើយ ព្រះមហាសត្វទើបប្រកាសថា លោកទាំងឡាយបានស្ដាប់ពាក្យរបស់នន្ទ-បណ្ឌិតនេះមុនហើយ ឥឡូវនេះ សូមអញ្ជើញស្ដាប់ពាក្យរបស់ខ្ញុំខ្លះ ដូច្នេះហើយ ទើបពោលថា ៖

លោកដ៏ចម្រើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ

សូមស្តាប់ពាក្យរបស់ខ្ញុំ បពិត្រមហារាជ អ្នកណាមិនប្រព្រឹត្តធម៌ចំពោះបុគ្គលជាច្បងទាំងឡាយ ញ៉ាំងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស ពួកជនណាឈ្លាសវៃក្នុងធម៌ (ជេដ្ឋាបចាយនធម៌) ជាប្រវេណីអំពីបុរាណ ព្រមទាំងបរិបូរណ៍ដោយសណ្តាប់ធ្នាប់ ពួកជននោះ រមែងមិនទៅកាន់ទុគ្គតិទេ ។ បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវបន្ទុក (ផែន) សូមព្រះអង្គជ្រាបយ៉ាងនេះថា មាតាបិតា បងប្អូនប្រុសស្រី ញាតិ និងផៅពង្សទាំងអស់នោះ ជាភារៈរបស់កូនច្បង ។ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ អាត្មាភាពដូចជានាយសំពៅ អាចនាំយកនូវភារៈដ៏ធ្ងន់ អាត្មាភាព ពុំប្រមាទនូវជេដ្ឋាបចាយនធម៌ទេ ព្រោះអាត្មាភាពជាច្បង ។

បណ្តាបទទាំងនោះ បទថា ភាតរជ្ឈាវរា មម សេចក្តីថា លោកដ៏ចម្រើនទាំងឡាយ គឺ ព្រះរាជាទាំងឡាយទាំងអស់ដែលជាបរិស័ទនៃប្អូនប្រុសរបស់ខ្ញុំ នាំគ្នាមកហើយ ចូរស្តាប់ពាក្យរបស់ខ្ញុំមុនខ្វះ ។ បទថា បរិហាបយំ បានដល់ ឲ្យសាប-

សូន្យជុំវិញ ។ បទថា ធម្មស្ស បានដល់ ធម៌គឺការប្រព្រឹត្តិឱនលំទោនចំពោះអ្នកធំ គឺធម៌ដែលជាប្រពៃណី ។ បទថា កុសលា បានដល់ ឈ្លាសវៃ ។ បទថា ចារិត្តេន ច បានដល់ ជាអ្នកបរិបូរណ៍ដោយមារយាទនិងសីល ។ បទថា ភារា សេចក្ដីថា ជននោះទាំងអស់ ដែលបងប្រុសច្បងគប្បីនាំទៅគឺគប្បីបដិបត្តិ ព្រោះដូច្នោះ ជនទាំងនោះទើបឈ្មោះថា ជាភារៈរបស់បងប្រុសច្បងនោះ ។

បទថា នាវិកោ វិយ សេចក្ដីថា ដូចយ៉ាងថា នាយសំពៅទទួលភារៈធ្ងន់ បន្ទុកចុះក្នុងទូកហើយ ក៏ត្រូវឧស្សាហ៍ព្យាយាមដែលនឹងនាំទូកទៅក្នុងកណ្ដាលមហាសមុទ្រ ដោយសិរីសួស្ដី ទំនិញនិងជនទាំងអស់ព្រមទាំងទូក រមែងជាភារៈរបស់នាយសំពៅនោះម្នាក់ យ៉ាងណា ញាតិទាំងអស់ រមែងជាភារៈរបស់ខ្ញុំតែម្នាក់ និងខ្ញុំអាចបដិបត្តិចិញ្ចឹមរក្សាជនទាំងនោះបាន ដូច្នោះដែរ ខ្ញុំទើបមិនលះបង់ជេដ្ឋាបចាយនធម៌នោះមួយទៀត ខ្ញុំជាបងប្រុសច្បងរបស់ជនត្រឹមប៉ុណ្ណោះ ប៉ុណ្ណោះក៏ទេ ខ្ញុំជាបងប្រុសច្បងរបស់លោកសូម្បីទាំងអស់ទៀតផង

ព្រោះដូច្នោះ ខ្ញុំទើបសមគួរហើយដែលនឹងបដិបត្តិមាតាបិតា ព្រមទាំងប្អូននន្ទៈផង ។

ព្រះរាជាទាំងនោះសូម្បីទាំងអស់ បានទ្រង់សណ្តាប់ពាក្យនោះហើយ ក៏នាំគ្នាសប្បាយព្រះទ័យ ត្រាស់ថា យើងទាំងឡាយដឹងហើយក្នុងថ្ងៃនេះឯងថា បានឮថា នាទីគឺការបដិបត្តិមាតាបិតាទាំងឡាយដ៏សេស រមែងជានាទីរបស់បងប្រុសច្បង ទើបនាំគ្នាលះបង់ចោលនន្ទបណ្ឌិត ចូលទៅអាស្រ័យព្រះមហាសត្វ កាលទ្រង់ធ្វើសេចក្តីសរសើរព្រះមហាសត្វនោះ ទើបត្រាស់គាថា ២ គាថាថា :

ពួកយើងបានញាណ ដូចបុគ្គលបានអណ្តាតភ្លើងអំពីភ្លើងក្នុងទីងងឹត កោសិយតាបសដ៏ចម្រើន បានផ្ចុះបញ្ចាំងធម៌ដល់ពួកយើងយ៉ាងនេះឯង ។ ព្រះអាទិត្យដែលបំភ្លឺនូវទ្រព្យ ធ្វើពន្លឺកាលរះឡើងតែងផ្ចុះបញ្ចាំងនូវរូបល្អ អាក្រក់ ដល់សត្វទាំងឡាយយ៉ាងណា កោសិយៈដ៏ចម្រើន បានផ្ចុះបញ្ចាំនូវធម៌ដល់ពួកយើង ក៏យ៉ាងនោះដែរ ។

បទថា អតិតតម្ហា សេចក្តីថា ក្នុងកាលមុនអំពីនេះ ខ្ញុំទាំងឡាយធ្លាក់នៅក្នុងសេចក្តីងងឹត ដែលបិទបាំងនូវជេដ្ឋាបចាយនធម៌ ទើបមិនដឹងធម៌នោះ ខ្ញុំទាំងឡាយបានកើតសេចក្តីដឹងឡើងក្នុងថ្ងៃនេះឯង ដូចពន្លឺប្រទីបបំភ្លឺ ផ្ទះបញ្ជាំង ដូច្នោះ ។ បទថា ឯវមេវ នោ សេចក្តីថា ភ្លើងដែលឆេះសន្ធោសន្ធៅនៅលើកំពូលភ្នំដែលងងឹត ភ្លឺស្វាងដោយជុំវិញ រមែងសម្តែងរូបទាំងឡាយឲ្យប្រាកដបានយ៉ាងណា ព្រះឥសី កោសិយគោត្រដ៏ចម្រើន ក៏សម្តែងធម៌ដល់ពួកយើងដូច្នោះដែរ ។ បទថា វាសុទេវោ សេចក្តីថា ទេវតាជាម្ចាស់នៃពន្លឺ ជាអ្នកភ្លឺស្វាង និងជាអ្នកប្រកាសធម៌ ។

ព្រះមហាសត្វ ទម្លាយសេចក្តីជ្រះថ្លានទ្ធបណ្ឌិតនោះ ហើយញុំាងព្រះរាជាទាំងនោះ ដែលមានព្រះទ័យជ្រះថ្លាក្នុងលោក ព្រោះបានឃើញបាដិហារ្យទាំងឡាយរបស់នទ្ធបណ្ឌិត រហូតអស់កាលត្រឹមតែប៉ុណ្ណោះ ឲ្យត្រឡប់មកកាន់យកពាក្យរបស់ខ្លួនហើយ បានធ្វើឲ្យព្រះរាជាទាំងអស់ទុំះឯង នាំគ្នាសម្លឹងមើលមុខរបស់ខ្លួន ដោយកម្លាំងនៃញាណរបស់ខ្លួន ដោយប្រការ

ដូច្នេះ ។

លំដាប់នោះ **នន្ទបណ្ឌិត** គិតថា បងប្រុសរបស់យើង ជាបណ្ឌិត ជាធម្មកថិកឈ្លាសវៃ បានចែកព្រះរាជារបស់យើង សូម្បីទាំងអស់ ធ្វើឲ្យជាបក្ខពួករបស់ខ្លួនបាន វៀរបងប្រុសរបស់យើងនេះចេញហើយ អ្នកដទៃដែលនឹងជាទីពឹងរបស់យើងបានមិនមានឡើយ យើងនឹងត្រូវអង្វរបងប្រុសរបស់យើងនេះតែម្នាក់ចុះ ទើបពោលគាថានេះថា ៖

កាលបើខ្ញុំអង្វរយ៉ាងនេះហើយ លោកនៅតែមិនទទួលអញ្ជលី ខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រឹងបម្រើលោក។

សេចក្តីនៃពាក្យដែលជាគាថានោះ មានដូចតទៅនេះ សូម្បីបងនឹងមិនព្រមទទួលគឺ មិនទទួលអញ្ជលីរបស់ខ្ញុំ ដែលអង្វរយ៉ាងនេះ ដែលខ្ញុំផ្គងដើម្បីត្រូវការឲ្យបងលើកលែងទោស បងចូរទំនុកបម្រុងមាតាបិតាចុះ ចំណែកខ្ញុំក៏នឹងប្រព្រឹត្តតាមពាក្យរបស់បង គឺនឹងជាអ្នកធ្វើតាមពាក្យ នឹងតាំងចិត្តទំនុក-បម្រុងដោយភាពជាអ្នកមិនខ្ជិលច្រអូស រាល់យប់និងថ្ងៃ គឺខ្ញុំនឹងបដិបត្តិទំនុកបម្រុងបង ។

សូម្បីតាមប្រក្រតីព្រះមហាសត្វ មិនបានប្រកាន់ទោស ឬចងពៀរវេរាក្នុងនន្ទបណ្ឌិតក៏ដោយ តែកាលនន្ទបណ្ឌិតនោះ ពោលពាក្យដែលរឹងប៉ឹង រឹងរុះដ៏ក្រៃលែង ទើបបានធ្វើដូចនោះ ក៏ដើម្បីនឹងគ្របសង្កត់ឲ្យលោកលះបង់មានះចេញ គ្រាមក ឥឡូវនេះ បានស្តាប់ពាក្យរបស់លោក ទើបមានចិត្តត្រេកអរ កើតសេចក្តីជ្រះថ្លាក្នុងលោក ពោលថា ម្នាលនន្ទៈ ឥឡូវនេះ បងលើកលែងទោសឲ្យដល់លោកហើយ លោកនឹងបាន បដិបត្តិមាតាបិតា កាលនឹងប្រកាសគុណរបស់នន្ទបណ្ឌិតនោះ ទើបពោលថា :

ម្នាលនន្ទ អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្ម ដែលពួក-សប្បុរសសម្តែងហើយមែន អ្នកជាមនុស្សល្អ មានឫកពាល្អ ត្រូវចិត្តយើងហើយ ។ ខ្ញុំសូមនិយាយនឹងបិតាដ៏ចម្រើន និង មាតាដ៏ចម្រើន សូមលោកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំ ភារៈ នេះមិនមែនគ្រាន់តែភារៈរបស់ខ្ញុំក្នុងកាលម្តងៗទេ ។ នន្ទៈធ្វើ នូវខ្ញុំដែលជាអ្នកបម្រើ នាំមកនូវសេចក្តីសុខដល់មាតានិងបិតា នោះ ឲ្យជាធំហើយសូមដើម្បីការបម្រើដែរ ។ បណ្ដា (មាតា

និងបិតា) ជាព្រហ្មចារី បើលោកណាម្នាក់ចង់បាន សូមលោកទទួលយកនន្ទះ តាមប្រាថ្នាចុះ តើឲ្យនន្ទះបម្រើលោកណា ។

បទថា ឆាយំ ភារោ សេចក្ដីថា ភារៈគឺការបដិបត្តិមាតាបិតានេះ នឹងជាត្រឹមតែជាភារៈរបស់ខ្ញុំ ក្នុងកាលខ្លះក៏ទេ ។ បទថា តំ មំ សេចក្ដីថា លោកទាំងឡាយ បានសម្គាល់ថាការទំនុកបម្រុងមាតាបិតានោះ ជាភារៈខ្ញុំម្នាក់ ក៏ចិញ្ចឹមរក្សាលោកទាំងឡាយបាន ។ បទថា ឧបដ្ឋាឆាយ យាចតិ សេចក្ដីថា នន្ទះបានមកអង្វរយើង ដើម្បីសូមទំនុកបម្រុងលោកទាំងពីរខ្លះ ។ បទថា យោ ចេ ឥច្ឆតិ សេចក្ដីថា ព្រោះថា ខ្ញុំមិនសមគួរនឹងនិយាយថា លោកចូរទំនុកបម្រុងមាតា ឬបិតារបស់បង តែបណ្ដាលោកទាំងពីរ អ្នកស្ងប់រម្ងាប់ហើយ អ្នកប្រព្រឹត្តព្រហ្មចរិយៈ បើលោកណាម្នាក់ប្រាថ្នា ខ្ញុំនឹងប្រាប់លោកនោះ បណ្ដាលោកទាំងពីរ សូមឲ្យលោកជ្រើសរើសយកនន្ទះតាមសេចក្ដីប្រាថ្នាចុះ លោកទាំងឡាយ រមែងពេញចិត្តនន្ទះប្អូនប្រុសរបស់ខ្ញុំនោះ ក្នុងបណ្ដាលោកទាំងពីរ នន្ទះនេះ

សមគួរនឹងទំនុកបម្រុងអ្នកណា ព្រោះថា យើងទាំងពីរនាក់ក៏ជាបុត្ររបស់លោកទាំះឯង ។

លំដាប់នោះ មាតាទើបក្រោកចាកអាសនៈពោលថា នែសោណបណ្ឌិតអើយ ប្អូនប្រុសរបស់អ្នកចាកចេញទៅយូរហើយ សូម្បីលោកមកហើយពីទីឆ្ងាយយ៉ាងនេះ ក៏មិនអាចនឹងអង្វរបាន ព្រោះថា យើងទាំងពីរនាក់ បានអាស្រ័យអ្នកហើយ តែឥឡូវនេះ អ្នកអនុញ្ញាតហើយ ម្តាយក៏នឹងបានឱបក្រសោបកូននន្ទៈ អ្នកប្រព្រឹត្តព្រហ្មចរិយៈនេះ ដោយដៃទាំងពីរហើយ គប្បីបានការថើបក្បាល កាលនឹងប្រកាសសេចក្តីនេះ ទើបពោលគាថា ៖

នែសោណៈកូន យើងអាស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ គួរបានដើម្បីចូលទៅថើបក្បាលនន្ទៈជាព្រហ្មចារី ។

លំដាប់នោះ ព្រះមហាសត្វ និយាយថា បពិត្រម៉ែ បើយ៉ាងនោះកូនព្រមអនុញ្ញាត ម៉ែចូរទៅឱបក្រសោបនន្ទៈកូនប្រុសរបស់ម៉ែ ហើយចូរឱបនិងថើបនូវក្បាលនន្ទៈ ចូរធ្វើសេចក្តីសោកខាងក្នុងចិត្តរបស់ម៉ែឲ្យរលត់ទៅចុះ ។ មាតាព្រះពោធិសត្វនោះ

ទើបទៅរកនន្ទះនោះហើយឱបក្រសោប នន្ទបណ្ឌិត ក្នុងកណ្ដាលបរិស័ទតែម្ដង ហើយឱបនិងថើបនន្ទះនោះ ត្រង់សីសៈ រលត់សេចក្ដីសោកក្នុងដួងចិត្តចេញឲ្យបាត់ហើយ កាលនឹងចរចាជាមួយព្រះមហាសត្វ ទើបពោលថា ៖

ដួងហឫទ័យរបស់ម្ដាយរំជួល ព្រោះខានឃើញនន្ទះអស់កាលយូរហើយ ដូចជាស្លឹកខ្ទិរបស់អស្សត្ថព្រឹក្ស ដែលត្រូវខ្យល់បក់ ។ វេលាណា ម្ដាយដេកលក់ យល់សប្តិឃើញនន្ទះមក ក៏មានចិត្តត្រេកអរ មានចិត្តរីករាយ (ដោយគិតថា) នន្ទះរបស់យើងនេះមកហើយ ។ វេលាណាម្ដាយភ្ញាក់ឡើង មិនឃើញនន្ទះមកទេ សេចក្ដីសោក និងទោមនស្សជាច្រើន រឹងរឹតតែបណ្ដាលឡើង ។ យូរណាស់ហើយ ស្រាប់តែក្នុងថ្ងៃនេះ ម្ដាយនោះឃើញនន្ទះមកដល់ នន្ទះជាទីស្រឡាញ់នៃស្វាមីរបស់ម្ដាយផង នៃម្ដាយផង បានចូលមកកាន់ផ្ទះរបស់ពួកយើង ។ នន្ទះជាទីស្រឡាញ់ក្រៃលែងរបស់បិតា កុំឲ្យនន្ទះ ទៅប្រាសចេញអំពីផ្ទះ នៃកូន ឯនន្ទះ (ចង់បានអ្នកណា) ចូរបានអ្នកនោះចុះ នន្ទះចូរបម្រើនូវអញចុះ ។

បទថា មាលុតេរិតំ សេចក្ដីថា មាតារបស់ព្រះមហាសត្វ ពោលថា ស្លឹករបស់អស្សត្ថព្រឹក្ស ត្រូវខ្យល់បក់ហើយ រមែងយោលទៅមកយ៉ាងណា ក្នុងថ្ងៃនេះបេះដូងរបស់ម៉ែ ក៏រមែងញាប់ញ័រ ព្រោះបានឃើញកូននន្ទៈ ដែលចាកចេញទៅយូរ ដូច្នោះដែរ ។ បទថា សុត្តា សេចក្ដីថា នែសោណៈកូន កាលណាម៉ែដេកលក់ហើយយល់សប្ដិឃើញនន្ទៈមក សូម្បីក្នុងកាលនោះ ម្ដាយមានចិត្តត្រេកអរហួសប្រមាណ ។ បទថា ភត្តុ ច បានដល់ រមែងជាទីស្រឡាញ់នៃស្វាមីរបស់ម្ដាយផង នៃម្ដាយផង ។ បទថា ឆន្ទោ នោ ធាវិសី ឃរំ សេចក្ដីថា នែសោណៈកូន នន្ទៈកូនប្រុសរបស់ម្ដាយ ចូរចូលទៅកាន់បណ្ណសាលា ។ បទថា យំ សេចក្ដីថា ព្រោះហេតុដែលនន្ទៈនោះ រមែងជាទីស្រឡាញ់យ៉ាងស្និទ្ធរបស់បិតា ព្រោះដូច្នោះ នន្ទៈនោះ ទើបមិនត្រូវចេញចាកពីផ្ទះនេះទៅទៀត ។ បទថា ឆន្ទោ តំ សេចក្ដីថា នែសោណៈកូន នន្ទៈប្រាថ្នាវត្ថុណា ចូរបានវត្ថុនោះចុះ ។ បទថា មំ ឆន្ទោ សេចក្ដីថា នែសោណៈកូន

អ្នកចូរទំនុកបម្រុងបិតារបស់អ្នកចុះ ចំណែកនន្ទះ ចូរទំនុកបម្រុងម្តាយ ។

លំដាប់នោះ ព្រះមហាសត្វទទួលពាក្យរបស់មាតាថា ចូរប្រព្រឹត្តទៅតាមពាក្យនិយាយរបស់មាតាយ៉ាងនេះចុះ ដូច្នេះហើយ ទើបពោលទូន្មានប្អូនប្រុសថា ម្នាលប្អូននន្ទះ ប្អូនបានចំណែករបស់បងហើយ ធម្មតាថា មាតាជាអ្នកធ្វើគុណទុកក្រៃលែងណាស់ ប្អូនកុំប្រមាទ គប្បីតាំងចិត្តបដិបត្តិលោកចុះ កាលនឹងប្រកាសគុណរបស់មាតា ទើបបានពោលគាថា ២ គាថាថា ៖

*ម្នាលឥសី មាតាជាអ្នកឈើឆ្អាល ជាទីពឹង ជាអ្នកឲ្យរស់ (ទឹកក្សីរ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោកចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រង ដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវលោក ម្នាលឥសី មាតាចង់បានអ្នក ។*

បណ្តាបទទាំងនោះ បទថា អនុកម្បកា បានដល់ជាអ្នកមានចិត្តទោរទន់ ។ បទថា បុត្តេ រសទទី បានដល់

ជាអ្នកឲ្យសេគឺទឹកដោះរបស់ខ្លួន ជាដំបូងតែម្តង ។ បទថា មាតា តំ សេចក្តីថា មាតារបស់យើងមិនប្រាថ្នាយើង លោកជ្រើសរើសអ្នក គឺប្រាថ្នាអ្នក ។ បទថា គោត្តិ បានដល់ជាអ្នកគ្រប់គ្រងថែរក្សា ។ បទថា បុញ្ញូបសំហិតា បានដល់ជាទីអាស្រ័យនៃបុណ្យ ជាអ្នកឲ្យនូវបុណ្យ ។

ព្រះមហាសត្វ កាលបានពណ៌នាគុណសេចក្តីល្អរបស់មាតាដោយគាថា ២ គាថាយ៉ាងនេះហើយ លុះមាតាត្រឡប់មកអង្គុយក្នុងអាសនៈពីដើម ទើបពោលទូន្មានប្អូនទៀតថា ម្នាលប្អូនទន្ធៈ មាតាជាអ្នកធ្វើកិច្ចដែលធ្វើបានលំបាកទុកហើយ សូម្បីយើងទាំងពីរនាក់ មាតាលោកក៏បានប្រដាប់តុបតែងមកដោយលំបាក ឥឡូវនេះ ប្អូនកុំប្រមាទ ចូរព្យាយាមបដិបត្តិមាតាចុះ ប្អូនកុំឲ្យលោកបរិភោគផ្លែឈើតូចធំទាំងឡាយដែលមិនឆ្ងាញ់ទៀត កាលនឹងប្រកាសថា មាតាបានជាអ្នកធ្វើកិច្ចដែលសែនលំបាក ដែលអ្នកដទៃនឹងធ្វើបាន ក្នុងកណ្តាលបរិស័ទនុ៎ះឯង ទើបពោលថា ៖

មាតាកាលប្រាថ្នាចង់បានផ្លែ គឺកូន តែងនមស្ការទេវតា

សួរទុក្ខត្តប្ញក្សទាំងឡាយផង សួរវេដូវនិងឆ្នាំទាំងឡាយផង ។ កាលមាតានោះ មានវេដូវលោងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌ស៊ប់ ដោយហេតុនោះ មាតាជាស្ត្រីមានសេចក្ដីចាញ់ផ្ទៃ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **សុហទា** (មានដួង-ហឫទ័យល្អ) ។ មាតារក្សា (ផ្ទៃ) អស់មួយឆ្នាំ ឬថយពី មួយឆ្នាំ ហើយទើបប្រសូតបុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា **ជនយន្ដីផង ជនេត្តីផង** (អ្នកបង្កើតកូន) ។ មាតាញុំាងកូនដែលកំពុងយំ ឲ្យត្រេកអរដោយទឹកក្សីរផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **តោសេន្ដី** (អ្នកញុំាងកូនឲ្យត្រេកអរ) ។ តអំពីនោះមក មាតាធ្វើនូវសេចក្ដីស្រឡាញ់រាប់អានហើយ ក្រឡេកមើលទារកដែលនៅពុំទាន់ដឹងក្ដី ក្នុងទីមាន ខ្យល់និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិត ហៅថា **បោសេន្ដី** (អ្នកចិញ្ចឹមកូន) ។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាគ្រប់គ្រងទ្រព្យទាំងពីរចំណែកនុ៎ះ ដើម្បីកូននោះ (ដោយបំណងថា) ទ្រព្យនេះ ត្រូវមានដល់បុត្រ

របស់យើង ។ មាតា រមែងលំបាកដោយការបង្ហាត់បង្រៀនកូន ដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាទក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ) ឯណោះ ។ កាលបើកូនមានវ័យចម្រើនឡើងហើយ មាតាបានដឹងថា កូនប្រមាទក្នុងប្រពន្ធនៃអ្នកដទៃ ក្នុងពេលអធ្រាត្រហើយមិនត្រឡប់មក ក្នុងពេលល្ងាច ក៏រមែងលំបាកចិត្ត ដូច្នេះ ។

សត្វដែលមាតា ចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើមាតា ប្រព្រឹត្តខុសក្នុងមាតានោះ តែងទៅកើតក្នុងនរក ។ សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើក្នុងបិតាប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាក ព្រោះមិនបម្រើមាតា ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាក ព្រោះមិនបម្រើបិតា ។ បណ្ឌិតបម្រើមាតា គប្បីបាននូវសុខទុំះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗ

កាល ។ បណ្ឌិតបម្រើបិតា គប្បីបាននូវសុខទាំង៤ គឺសេចក្តីត្រេកអរក្នុងកាយ ការសើចលេងសព្វៗកាល ។ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តិជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ក្នុងជេដ្ឋាបចាយនធម៌នោះៗ តាមសមគួរ ១ ។ សង្គហធម៌ទាំង៤នុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោកដូចជាក្រឡៅនៃកង់រថដែលវិលទៅ បើសង្គហធម៌ទាំង៤នុ៎ះមិនមានទេ មាតាមិនត្រូវបានសេចក្តីរាប់អាន និងការបូជាព្រោះហេតុនៃកូន ទាំងបិតាក៏មិនត្រូវបាននូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ។ ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ទាំង៤នុ៎ះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វ គឺបុត្រ បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យផងរបស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូត និងការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការ

បម្រើចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

បណ្ដាបទទាំងនោះបទថា **បុត្តផលំ** ប្រែថា ផ្លែគឺបុត្រ ។ បទថា **ទេវតាយ នមស្សតិ** សេចក្ដីថា រមែងធ្វើការនមស្ការបួងសួងទេវតាថា សូមឲ្យបុត្រចូរកើតមានដល់ខ្ញុំ ។

បទថា នក្ខត្តានិ ច បុច្ឆតិ សេចក្ដីថា និងរមែងសួរដល់នក្ខតឫក្សទាំងឡាយយ៉ាងនេះថា បុត្រកើតហើយដោយនក្ខត្តឫក្ស យាមណា ទើបមានអាយុវែង កើតដោយនក្ខត្តឫក្ស យាមណា មានអាយុខ្លី ។

បទថា ឧតុសំវច្ឆរានិ ច សេចក្ដីថា មួយទៀត មាតារមែងសួរដល់រដូវ និងឆ្នាំទាំងឡាយយ៉ាងនេះថា បុត្រដែលកើតក្នុងរដូវណា ក្នុងបណ្ដារដូវទាំង ៦[១] ទើបមានអាយុវែង

---

[១] **ហេមន្តោ សិសិរមុត្ដូ ឆ វា វស្សន្តោ ច គិម្ហវស្សានា សរទោតិ កមា មាសា ទ្វេ ទ្វេ វុត្តានុសារេន** : រដូវទាំង ៦ គឺ **ហេមន្តៈ** រដូវត្រជាក់ **សិសិរ** រដូវរងារ **វសន្តៈ** រដូវឈើលាស់ស្លឹក **គិម្ហៈ** រដូវក្ដៅ **វស្សានៈ** រដូវភ្លៀង **សរទៈ** រដូវដែលមានខ្យល់ភ្លៀងនិងទឹកសន្សើម, រដូវមួយ ២ ខែ១ រៀងលំដាប់រាប់តាមសេចក្ដីដែលពោលហើយនោះ ។ (ចាកអភិធានប្បទីបិកា)

កើតក្នុងរដូវណាទើបមានអាយុខ្លី ឬកាលមាតាមានអាយុ
ប៉ុនណា បុត្រកើតមកទើបនឹងមានអាយុវែង កាលមាតាមាន
អាយុប៉ុនណា បុត្រកើតមកទើបមានអាយុខ្លី ។ បទថា ឧតុសិ
ឆហាតាយ បានដល់ កាលរដូវកើតឡើងហើយ ឈ្មោះថា
ងូតទឹកក្នុងព្រោះរដូវ (មាតាឈ្មោះថាមានរដូវ) ។ បទថា
អវក្កមោ សេចក្តីថា ការតាំងគភ៌ រមែងមានព្រោះការប្រជុំ
ព្រមនៃហេតុ ៣ ប្រការ គភ៌ទើបតាំងឡើងក្នុងផ្ទៃ ។

បទថា តេន សេចក្តីថា មាតានោះ រមែងចាញ់ផ្ទៃ ព្រោះ
គភ៌នោះ ។ បទថា តេន សេចក្តីថា ក្នុងកាលនោះ មាតា ទើប
កើតសេចក្តីស្រឡាញ់ក្នុងបុត្រធីតា ដែលជាបជាគឺកូន កើតក្នុង
ផ្ទៃរបស់ខ្លួន ព្រោះហេតុនោះ លោកទើបហៅថា **សុហទា** ស្រី
មានចិត្តល្អ ។ បទថា តេន សេចក្តីថា ព្រោះហេតុនោះ លោក
ទើបហៅថា **ជនយន្តិខ្វះ ជនេត្តិខ្វះ** អ្នកញុំាងបុត្រឲ្យកើត ។ បទថា
អង្គ័ចាវុរណោឆ ច សេចក្តីថា ដោយការឲ្យបុត្រដេក
ក្នុងចន្លោះដោះទាំង ២ ញុំាងសម្ផស្សនៃសរីរៈឲ្យផ្សាយទូទៅ
ហើយ ទើបឲ្យកក់ក្តៅដោយគ្រឿងគ្របគឺអវយវៈនុំះឯង ។

បទថា គោសេដ្ឋី បានដល់ ឲ្យរលឹកដឹង ឲ្យរីករាយ ។ បទថា មម្មំ កត្វា ឧធិក្ខតិ សេចក្តីថា មាតាធ្វើការក្រឡេកមើល-យ៉ាងនេះថា ឱហ្ន៎ ខ្យល់បក់ កំដៅថ្ងៃជុតពោលខាងលើបុត្រ របស់យើង រមែងសម្លឹងមើលដោយទឹកចិត្តដែលស្រឡាញ់ ។ បទថា ឧភយម្បេតស្ស សេចក្តីថា មាតារមែងមិនត្រូវការនឹង ឲ្យទ្រព្យសម្បត្តិទាំង ២ ចំណែកនេះ ដល់ពួកជនដទៃ រក្សាទុក ក្នុងបន្ទប់ដែលខ្ទាប់ខ្ទួនជាដើម ដើម្បីប្រយោជន៍ដល់បុត្រនេះ ។ បទថា ឯវំ បុត្ត អទុំ បុត្ត សេចក្តីថា មាតាឲ្យបុត្រសិក្សាជានិច្ច ថា ម្នាលកូន ឯងចូរជាអ្នកមិនប្រមាទក្នុងរាជត្រកូលជាដើម យ៉ាងនេះ មួយទៀត អ្នកឯងចូរធ្វើកម្មឯណោះ មាតារមែង លំបាក ដោយប្រការដូច្នេះ ។ បទថា ឥតិ មាតា វិហញ្ញតិ បានដល់ រមែងនឿយហត់ ។ បទថា បត្តយោព្វនេ សេចក្តីថា កាលបុត្រដល់នូវភាពជាអ្នកកំលោះ ឬជាក្រមុំ កំពុងជោជន់ មាតា ដឹងថាបុត្រស្រវឹង ក្នុងកិរិយាអ្នកដទៃដរាបយប់ងងឹត ក៏មិនទាន់ត្រឡប់មក ទើបសម្លឹងមើលកូនដោយនេត្រាដែល

សើមជោកដោយទឹកភ្នែក ។ បទថា វិហញ្ញតិ ប្រែថា នឿយ-ហត់ ។ បទថា កិច្ឆាភតោ បានដល់ បុត្រដែលមាតាចិញ្ចឹមរក្សាមក គឺទំនុកបម្រុងមកដោយការលំបាក ។ បទថា មិច្ឆាចរិត្វាន បានដល់ មិនបដិបត្តិមាតា ។ បទថា ធនាបិ គឺទ្រព្យសម្បត្តិទាំងអស់ ។ ម្យ៉ាងទៀត បាលីក៏ជាយ៉ាងនេះដូចគ្នា ។ មានពាក្យដែលលោកពោលអធិប្បាយទុកថា ខ្ញុំបានស្តាប់មកថា សូម្បីទ្រព្យដែលកើតឡើងដល់បុត្រអ្នកចង់បានទ្រព្យ តែមិនបានបដិបត្តិមាតា រមែងវិនាសវិនាសទៅ ។ បទថា កិច្ចំ វា សោ សេចក្តីថា ទ្រព្យរបស់គេ រមែងវិនាសទៅខ្លះ គេរមែងចូលដល់សេចក្តីលំបាកខ្លួនឯងខ្លះ ដោយប្រការដូច្នេះ ។ បទថា លព្ភមេតំ សេចក្តីថា សេចក្តីសុខមានសេចក្តីរីករាយជាដើមក្នុងលោកនេះ និងលោកខាងមុខ បណ្ឌិតអ្នកដឹងច្បាស់គប្បីបានព្រោះការទំនុកបម្រុងមាតា គឺបណ្ឌិតប្រាកដដូច្នោះអាចបាន ។ បទថា ធានញ្ច សេចក្តីថា បុត្រគប្បីឲ្យទានដល់មាតាបិតាទាំង ២ គប្បីចរចាពាក្យដែលជាទីស្រឡាញ់ គប្បីប្រព្រឹត្តប្រយោជន៍ ដោយអំណាចការធ្វើតាមកិច្ច ដែលកើត

ឡើងហើយឲ្យសម្រេច ។ បទថា ធម្មេសុ សេចក្តីថា ភាពជាអ្នកមានខ្លួនស្មើក្នុងធម៌ គឺភាពជាអ្នកប្រព្រឹត្តឱនលំទោនចំពោះបុគ្គលដែលចម្រើន ដែលបុត្រគប្បីធ្វើក្នុងទីនោះៗ គឺត្រង់កណ្តាលបរិស័ទ ឬក្នុងទីកំបាំង ដោយអំណាចការក្រាបថ្វាយបង្គំជាដើម បុត្រនឹងធ្វើការអភិវាទជាដើម ក្នុងទីកំបាំងហើយ មិនព្រមធ្វើក្នុងបរិស័ទមិនសមគួរឡើយ គប្បីជាអ្នកប្រព្រឹត្តស្មើក្នុងទីទាំងអស់តែម្តង ។ បទថា ឯតេ ច សង្គហានាស្សុ សេចក្តីថា បើថាសង្គហវត្ថុទាំង ៤ ប្រការនេះ នឹងមិនគប្បីមានសោត ។ បទថា សមបេក្ខន្តិ សេចក្តីថា បណ្ឌិតទាំងឡាយ រមែងសម្លឹងឃើញដោយន័យ ដោយហេតុ ដោយប្រពៃ ។ បទថា មហត្តំ ប្រែថា ភាពជាអ្នកប្រសើរ ។ បទថា ព្រហ្មា បានដល់ មាតាបិតាទាំងឡាយ ជាអ្នកខ្ពង់ខ្ពស់បំផុត ជាអ្នកប្រសើរបំផុត ស្មើដោយព្រះព្រហ្ម របស់ពួកបុត្រ ។ បទថា បុព្វាចរិយា បានដល់ ជាអាចារ្យដំបូង ។ បទថា អាហុនេយ្យា បានដល់ ជាអ្នកគួរទទួលរបស់កំនាប់ គឺជាអ្នក

សមគួរដល់សក្ការៈគ្រប់យ៉ាង ។ បទថា អន្នេន អថោ បានដល់ទាំងបាយទាំងទឹក ។ បទថា បេច្ច សេចក្តីថា ក្នុងទីបំផុតនៃការធ្វើកាលកិរិយា បុត្រនោះទៅអំពីលោកនេះហើយរមែងរីករាយក្នុងសុគតិសួគ៌ ។

ព្រះមហាសត្វ បានសម្តែងធម៌ចប់ ដូចកាលវិលទៅនៃភ្នំសិនេរុ ដោយប្រការដូច្នេះ ។ ព្រះរាជាទាំងនោះ និងពួកពលកាយសូម្បីទាំងអស់ បានស្តាប់ព្រះធម៌ទេសនានោះហើយក៏នាំគ្នាជ្រះថ្លាហើយ ។ លំដាប់នោះ ព្រះមហាសត្វ ទើបឲ្យឱវាទព្រះរាជាទាំងនោះ ឲ្យតាំងនៅក្នុងសីល ៥ ហើយទូន្មានថា សូមមហាបពិត្រទាំងឡាយ ចូរជាអ្នកមិនប្រមាទក្នុងបុណ្យមានទានជាដើមចុះ ហើយបញ្ជូនព្រះរាជាទាំងនោះ ត្រឡប់ទៅវិញ ។ ព្រះរាជាទាំងនោះសូម្បីទាំងអស់ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ក្នុងវេលាអស់ព្រះជន្មាយុ ក៏ទ្រង់ធ្វើទេវនគរឲ្យពេញ ។ សោណបណ្ឌិតនិងនន្ទបណ្ឌិតតាបស ២ នាក់ បងប្អូន បានបដិបត្តិទំនុកបម្រុងមាតាបិតាដរាបដល់អស់អាយុ ក៏បានទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុអ្នកចិញ្ចឹមមាតាបិតា បានតាំងនៅក្នុងសោតាបត្តិផលហើយ ទើបទ្រង់ប្រជុំជាតកថា មាតាបិតារបស់យើងក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងបច្ចុប្បន្ន ព្រះបាទមនោជរាជក្នុងកាលនោះ បានមកជាសារីបុត្ត ។ ព្រះរាជា ១០១ ព្រះអង្គ បានមកជាព្រះអសីតិមហាថេរៈ និងមកជាព្រះសាវកដទៃៗ ។ ពួកពលនិកាយ ២៤ អក្ខោភិណី ក៏បានមកជាពុទ្ធបរិស័ទ ។ នន្ទបណ្ឌិតបានមកជាព្រះអានន្ទ ចំណែកសោណបណ្ឌិត ក៏គឺយើងតថាគតនុ៎ះឯង ដូច្នេះឯង ។

ចប់ សោណានន្ទជាតក ។

# II. អត្ថបទកំណាព្យ

## ១-កតញ្ញុតា (ភារៈនៃអ្នកដឹងគុណ)

កតញ្ញុតា មានន័យប្រាប់ថា ជនកតញ្ញូ
ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះជាគ្រូ
ប្រាប់ឱ្យតបគុណ ។

មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ
ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ
ដែលត្រូវសាបព្រោះ ។

បណ្ដុះពូជបុណ្យ ក្នុងស្រែជាគុណ កុំឱ្យមានមោះ
បុណ្យនឹងអើតអើន ចម្រើនឥតច្នោះ ត្រូវមានចិត្តស្មោះ
កុំលុបគុណចោល ។

កុំគ្រាន់តែថា មាតាបិតា មានគុណជាគោល
មាត់ថាត្រូវតប- គុណកុំច្បោល១ ធ្វើដែរស្រោល១
សោះតែគេថា ។

ជនអ្នកតបគុណ ព្រះពុទ្ធមានបុណ្យ ទ្រង់ត្រាស់ទេសនា
សរសើរញឹកញូយ មានក្នុងសាស្ត្រា គម្ពីរដីកា

គួរយើងចងចាំ ។

ចេះចាំហើយធ្វើ ចិត្តយើងអើពើ ឱ្យស៊ប់ឱ្យស៊ាំ
ឱ្យស្ថិទ្ធនឹងគុណ គុណតែងថែទាំ ពុំមែនខ្ជេចខ្ជាំ
ព្រោះតបគុណទេ ។

ជនមានចិត្តខ្សោយ ច្រើនតែធ្វេសធ្វោយ រមិលគុណគេ
អាងព្រេងសំណាង ពីក្នុងបុព្វេ ប្រហែសធ្វេសធ្វេ
ព្រងើយកន្តើយ ។

អ្នកប្រាជ្ញប្រាប់ថា ជនប្រុសស្រីណា លុបគុណចោលហើយ
ជនប្រុសស្រីនោះ ពុំមានសុខឡើយ យូរប៉ុន្មានឡើយ
រែងតែធ្លាក់ខ្លួន ។

កំពុងបានសុខ ស្រាប់តែមានទុក្ខ ចេញមុខផ្ទួនៗ
ឱ្យផលកំណាច ឃោរឃៅឥតស្ងួន ទោសមកពីខ្លួន
រមិលគុណគេ ។

ទេព្តាគេខឹង ព្រោះខ្លួនរឹងត្អឹង អាងបុណ្យបុព្វេ
ទោសបច្ចុប្បន្ន ជិះជាន់ឥតល្ហែ ភ័ព្វព្រេងបុព្វេ
បើមានក៏ផ្អាក ។

ទោសរមិលគុណ រារាំងមុខបុណ្យ- ព្រេងឱ្យសម្រោក

បង្អង់ឈប់សិន បាបថ្មីវិបាក ឱ្យផលឥតស្រាក

ព្រោះបានឱកាស ។

បុណ្យបាបចាស់ថ្មី តែងតែរំពៃ ពុំមែនផ្ដេសផ្ដាស
កាលមានចន្លោះ ត្រូវពេលសស្រាស ហាក់ដូចប្រកាស

ប្រាប់ថាត្រូវអញ ។

ចេញមុខឱ្យផល សុខទុក្ខឱ្យដល់ ជនដែលកកាញ់
កសាងបង្កើត កំណើតជាអញ អញជាសម្លាញ់

ត្រូវអញឱ្យផល ។

វិបុណ្យឬបាប ដែលមានសភាព ជាកម្មតែងផ្ដល់
សុខទុក្ខឱ្យជន អ្នកធ្វើឱ្យដល់ នូវក្ដីសល់វល់

ឬក្ដីសុខសាន្ត ។

បាបតែងរារាំង បុណ្យឱ្យនៅតាំង ផ្អាកសិនពុំបាន
ចេញមុខឱ្យផល ជាសុខសម្រាន្ត អ្នកធ្វើតែងបាន

ទទួលរងទុក្ខ ។

បុណ្យក៏រារាំង បាបឱ្យនៅតាំង ផ្អាកពុំចេញមុខ
ព្រោះមានឱកាស បុណ្យផ្ដល់ក្ដីសុខ សុទ្ធតែមានមុខ

ទីទៃពីគ្នា ។

ហេតុនោះគួរជន កុំនៅទម្រន់ ក្នុងក្តីខ្ជីខ្ជា
គួររកសាងបុណ្យ មានគុណមហិមា ទើបបានឈ្មោះថា
អ្នកស្រឡាញ់ខ្លួន ។

## ២_អកតញ្ញូឥតមានគ្រូប្រដៅកើត

អកតញ្ញុស្ស ពោសស្ស និច្ចំ វិវរទស្សិនោ
សព្វំ ចេ បថវឹ ទជ្ជា នេវនំ អភិរាធយេ ។

ប្រសិនបើគេឱ្យផែនដីទាំងមូលដល់បុរសអកតញ្ញូ ជាអ្នកឃើញទោស
ជានិច្ច ក៏មិនគប្បីញ៉ាំងបុរសអកតញ្ញូនោះ ឱ្យត្រេកអរបានឡើយ ។

### ពាក្យកាព្យ ៧ ឱ្យងាយចាំ

អកតញ្ញូលុបលាងគុណ ឃោរឃៅជ្រុលស៊ុនឥតដឹងអ្វី
ទោះបីគេលើកយកផែនដី រដ្ឋរាជបុរីឱ្យក៏ដោយ ។
វាក៏ឥតនឹកគុណតិចតួច វាចេះតែផ្ចួចរករឿងញួយ
ព្យាបាទផ្តន្ទាពុំថយក្រោយ វាឱ្យទុក្ខព្រួយវិញតបគុណ ។
ព្រះពុទ្ធប្រាប់ថាជនចិត្តទ្រុស្ត វាកាន់ក្តីខុសជ្រុលហួសស៊ុន
ឥតគ្រូប្រដៅឱ្យដឹងគុណ ទោះអ្នកមានបុណ្យក៏ទាល់ប្រាជ្ញ ។

ស្ដីថ្មីចម្លោះជនល្ងង់ខ្លៅ ត្រូវពោលសំដៅជនអង់អាច
ដែលលើកឱ្យរស់ខ្ពស់ត្រដាច ក៏វាមិនខ្លាចតិចតួចឡើយ ។

## បទកាកគតិ

អកតញ្ញូ លុបលាងគុណគ្រូ មាតាបិតា
ទោះបីវាទៅ នៅក្នុងទីណា ឥតមានទេវតា
ណាជួយវាឡើយ ។
ផលទោសអាក្រក់ ឃោរឃៅតក់ម៉ក់ តែផ្ដល់បង្ហើយ
ឱ្យវាលិចលង់ ភ័ន្តផុងឥតស្បើយ ឥតមានកោះត្រើយ
ពឹងពួនជ្រកកោន ។
មានតែរងទុក្ខ គ្រប់បែបគ្រប់មុខ ខ្លួនវាក្រញោន
ទុក្ខចាប់ក្រញិច តត្រុនកំប្រោន ទីពឹងទីកោន
នៃវាគឺទុក្ខ ។
គួរសាធុជន តាំងចិត្តឱ្យធ្ងន់ យកគុណជាមុខ
កុំធ្វើលៃលន កុំស៊ុកគ្រលុក គុណជាជម្រុក
នៃក្ដីសុខសាន្ត ។

## មួយយ៉ាងថា

អកតញ្ញូ ពុំដឹងគុណគ្រូ មាតាបិតា
និងអ្នកមានគុណ ឯទៀតណា១ ចិត្តវាហានក្លា
រករឿងចាប់ទោស ។

ទោះអ្នកមានគុណ មានចិត្តជាបុណ្យ អត់ឱនសន្តោស
សង្គ្រោះឱ្យវា រួចចាកទុក្ខទោស វានៅតែកោស-
រួសរករឿងទៀត ។

ទោះលើកផែនដី ទាំងមូលឱ្យក្តី វានៅតែឆ្លៀត
រករឿងរ៉ាងវិញ ដោយការជ្រែកជ្រៀត នាំជនឯទៀត
ឱ្យចូលដៃផង ។

នេះគឺជនពាល គំនិតរោលរាល អាក្រក់កន្លង
ទោះព្រះសម្ពុទ្ធ វិសុទ្ធឥតហ្មង ក៏អាចចម្លង
វាពុំបានឡើយ ។

(ពាក្យកាព្យនេះ ជាស្នាព្រះហស្ត
សម្តេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ)។

# ៣.នាមជាប់ដោយគុណ

នាមជាប់ដោយគុណមានច្រើនបែបយ៉ាង ខ្ញុំមានសំណោងសិក្សាធមិអាចិ
យល់ក្នុងព្រះគុណមាតាបិតា គុណច្រើនណាស់ណាដូចចន្ទ្រស្រទន់ ។
ក្នុងព្រះធម្មាបានប្រាប់ច្បាស់ថា មាតាបិតាលោកមានគុណធ្ងន់
ឱ្យកូនបានរស់ សង្គ្រោះពេកពន់ ប្រសើរលើសលន់ទឹកចិត្តថ្លៃថ្លា ។
ព្រះពុទ្ធត្រាស់ថាមានព្រហ្មវិហារ ព្រះទ័យល្អជាមេត្តាករុណា
រាប់អានអាណិត ទាំងមុទិតា និងឧបេក្ខា លើកូនប្រុសស្រី ។
ម្យ៉ាងវិញទៀតនោះ គាត់ជាទេព្តា ជាបុព្វាចារ្យ ទឹកចិត្តប្រណី
ណែនាំសព្វគ្រប់ ជានិច្ចរាល់ថ្ងៃ ខំប្រឹងកែខៃមិនគិតនឿយហត់ ។
អាហុនេយ្យ-បុគ្គលមែនពិត កូនត្រូវចូលជិតដោយចិត្តអំណត់
គោរពបូជាឱ្យបានហ្មត់ចត់ បានបុណ្យប្រាកដក្រៃលែងណាស់ណា ។
បើកូនទាំងឡាយប្រព្រឹត្តតបគុណ ឱ្យបានលើសលន់នឹងបានផល្លា
បានជាបារមីប្រសើរថ្លៃថ្លា ដែលព្រះសម្មាសម្ពុទ្ធសរសើរ ។
អ្នកដឹងគុណហើយបើបានធ្វើតប តែងបានប្រកបទៅតាមដំណើរ
ដែលព្រះសាស្តាព្រះអង្គធ្លាប់ដើរ រែងបានប្រសើរត្រាស់ដឹងសច្ចៈ ។

ដោយ ភិក្ខុ ភ.ស.វ. សុវណ្ណជោតោ

# ៤_ផលតបស្នងសងគុណ

ក្នុងពុទ្ធសាសនាបានថែងច្បាស់ថា មាតាបិតាលោកមានគុណធ្ងន់
មានម្ហូមចំណីជូនលោកជាមុន  នឹងបានជាទន់សោយផលខាងក្រោយ ។
ព្រោះគាត់ជាព្រហ្មជាបុព្វាចារ្យ និងជាទេព្តាឱ្យកូនបានស្បើយ
ជួយឱ្យកូនសុខមិនមានកន្តើយ  មិនបានបណ្តោយទៅតាមវាសនា ។
វិសុទ្ធិទេព ពិតប្រាកដណាស់     ព្រះអង្គទ្រង់ត្រាស់ មានក្នុងដីកា
ជាអរហន្តលើបុត្តធីតា            គួរមានបញ្ញាយល់ត្រូវតាមពិត ។
លោកគួរទទួលវត្ថុទាំងឡាយ   ទោះទឹកឬបាយ មកពីឆ្ងាយជិត
ដែលកូនបូជាដល់គាត់ពិត។      ចូរអ្នកកុំគិតខ្លាចក្រែងថាអស់ ។
ទោះជានឿយហត់លំបាកម្តេចម្តា កូនត្រូវឧស្សាដោយចិត្តស្ម័គ្រស្មោះ
លះពេលវេលាព្រមទាំងរបស់  មិនមែនសូន្យសោះទទេឡើយណា ។
ផលការតបគុណកូនត្រូវចងចាំ  សិក្សាចំណាំតាមច្បាប់តម្រា
បណ្ឌិតសរសើរនៅក្នុងលោកា   ចុតិពេលណា ឋានសួគ៌ប្រាកដ ។
ម្យ៉ាងបច្ចុប្បន្នតែងបានសុខជា   ចម្រើនភោគាច្រើនលើលកំណត់
ព្រោះផលតបគុណដ៏យ៉ាងម៉ត់ចត់ នឹងមិនក្រក្សត់ទុគ្គតសោកកា ។
ម្យ៉ាងឈ្មោះថាបានសាងជាបារមី តាមព្រះជិនស្រីជាព្រះសាស្តា

ប្រសើរពេកក្រៃនៅក្នុងលោកា  មកពីផល្លាតបស្នងសងគុណ ។

ដោយ ភិក្ខុ ភ.ស.វ. សុវណ្ណជោតោ

## ៥.កូនត្រូវចិញ្ចឹមមាតាបិតា

កូនមានជីវិតរស់បានក្នុងលោក  មានជ័យមានជោគនៅក្នុងលោកា
អ្នកត្រូវដឹងចុះដោយគុណករុណា មាតាបិតាពិតណាស់ជាក់ស្តែង ។
ដូច្នេះអ្នកត្រូវគិតគូពិចារ  កបដោយបញ្ញាគោរពកោតក្រែង
ដល់អ្នកមានគុណតាមព្រះសម្តែង រៀបចំចាត់ចែងបច្ច័យទាំងឡាយ ។
សំពត់ខោអាវសម្រាប់ស្លៀកពាក់  ទឹកក្តៅត្រជាក់លាងជម្រះកាយ
ផ្លែឈើតូចធំម្ហូបចំណីបាយ  ឱ្យគាត់សប្បាយចិត្តកាយសុខស្រួល ។
រៀបចំទីនៅនិងទីសម្រាន  ឱ្យបានថ្កើងថ្កានត្រូវរៀបសម្រួល
សំអាតជូតលាងដោយការទទួល ភារៈដូចឈ្នួលក៏ត្រូវឃ្នាតខ្ចី ។
ពេលមានជម្ងឺគិតគូព្យាលបាល  ទោះទាំងកណ្តាលយប់អធ្រាត្រក្តី
ត្រូវនាំទៅពេទ្យមិនត្រូវពោលស្តី  លំបាកម្តេចក្តីឱ្យបានសក្តិសម ។
ទោះអស់ប្រាក់ខែកម្លាំងកាយចិត្ត  កូនអើយកុំគិតថាមិនសំណំ
ត្រូវប្រឹងតស៊ូស្នារតីរួមផ្សំ  អ្នកនឹងឧត្តមវិសេសវិសាល ។

ដោយ ភិក្ខុ ភ.ស.វ. សុវណ្ណជោតោ